អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Nov-2012, 16:00
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ

**សាធារណៈ**

**ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី១៣០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក សេង ប៊ុនឃាង

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្តើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Christine MARTINEAU)*

លោកស្រី នូស៊ីន សាកាវ៉ាទី
*(Ms. Nushin SAKARATI)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ហ្សាស្តេ ប៉ៅ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉េន ពៅ | ខ្មែរ |
| លោកស្រី នូស៊ីន សាកាវ៉ាទី | អង់គ្លេស |
| លោក មឿន សុវណ្ណ (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោក ប៉េជុយ ជីបសែ (TCW-507) | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី: លោក ម៉េដុយ ជីបសៃ** (TCW-507)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ ........ ទំព័រ ៤៥

សួរដោយលោក សេង ប៊ុនឃាង ផ្ដើមពី៖ ........ ទំព័រ ៤៩

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី៖ ........ ទំព័រ ៦១

សួរដោយលោក វ៉េន ពៅ ផ្ដើមពី៖ ........ ទំព័រ ៨១

សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី ផ្ដើមពី៖ ........ ទំព័រ ៨៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ នៅក្នុងថ្ងៃនេះដំណើរការសវនាការរបស់អង្គជំនុំជម្រះនឹងធ្វើសវនាការចំនួនពីរ ដោយឡែកពីគ្នា។ ទី១ គឺសវនាការស្តាប់នូវសេចក្តីសន្និដ្ឋានរបស់ភាគីពាក់ព័ន្ធនឹងដំណើរការសវនាការពិភាក្សាដេញដោលលើរបាយការណ៍របស់អ្នកជំនាញ ចន ខាំប៊ែល ដែលអង្គជំនុំជម្រះបានធ្វើសវនាការកាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ កន្លងទៅ លើបញ្ហាសុខភាពក្នុងការចូលរួមសវនាការរបស់លោក អៀង សារី ដែលនៅព្រឹកនេះអង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យភាគីដែលពាក់ព័ន្ធឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នូវកិច្ចដំណើរការសវនាការនោះ។

ហើយបន្ទាប់មកអង្គជំនុំជម្រះនឹងបន្តសវនាការលើអង្គសេចក្តីសំណុំរឿង ០០២/០១ ដែលនឹងបន្តធ្វើដោយការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-507 តាមកាលវិភាគដែលបានគ្រោងទុក។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការទាំងពីរនេះ។ ដោយមួយម្តងដាច់ដោយឡែកពីគ្នាណា៎ះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ ចំពោះសវនាការដំបូងនេះ គ្រប់ភាគីទាំងអស់មានវត្តមានលើកលែងតែជនជាប់ចោទ លោក នួន ជា និង ខៀវ សំផន មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ។ ហើយជនជាប់ចោទ អៀង សារី អវត្តមានដោយមូលហេតុសុខភាព ប៉ុន្តែយោងតាមលិខិតលះបង់សិទ្ធិមានវត្តមានដែនកំណត់របស់ជនជាប់ចោទ ឯកសារលេខ E237 ជនជាប់ចោទបានលះបង់សិទ្ធិមានវត្តមាននៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការ នៃការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-507 ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មនៅសវនាការបន្ទាប់នេះ។

ហើយសាក្សីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបាន

បញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប គឺលោក នួន ជា, អៀង សារី និង ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីពេលព្រឹកមិញនេះ។ នៅថ្ងៃនេះក៏មានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូប គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-82។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ ជាបន្តនេះអង្គជំនុំជម្រះសូមចាប់ផ្តើមធ្វើនីតិវិធីនៃដំណើរការសវនាការទី១ គឺសេចក្តីសន្និដ្ឋានបញ្ចប់នូវកិច្ចពិភាក្សាដេញដោលលើរបាយការណ៍របស់អ្នកជំនាញ ដែលអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរ -- នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់។

លោកមេធាវីបើមានបញ្ហាអីលោកអាចបញ្ចប់ អាចលើកនៅពេលក្រោយណ៎ះ! លោកមេធាវីឥឡូវនេះយើងបានកំណត់រួចហើយ ថាឲ្យធ្វើសវនាការទី១ មុន។

[០៩:០៩:២៨]

លោកមេធាវីអន្តរជាតិការពារក្តី នួន ជា អង្គុយចុះ! ឥឡូវនេះ អង្គជំនុំជម្រះសម្រេចថា ធ្វើសវនាការស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគី ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការសវនាការស្តាប់របាយ-ការណ៍របស់អ្នកជំនាញជាមុនសិន ដើម្បីឲ្យបញ្ចប់នូវកិច្ចពិភាក្សាសវនាការទី១។ បើលោកមានបញ្ហាអីចាំដល់ពេល ក្រោយពេលចប់លោកអាចលើកបានចំពោះបញ្ហាដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការសវនាការលើអង្គសេចក្តី។

យើងបានសម្រេចរួចហើយ កុំឲ្យរំខានអី ពីព្រោះលោក -- ក្រុមលោកដូចរំខានយើងកាលពីសវនាការកាលពីថ្ងៃព្រហស្បតិ៍ម្តងហើយ។ ដោយនៅក្នុងកិច្ចដំណើរការនីតិវិធី គឺមិនមែនជាសិទ្ធិរបស់លោកដែលត្រូវចូលនៅក្នុងសវនាការនេះទេ។ សវនាការនេះ បើគិតចូល គឺលោកចូលក្នុងនាមជាអ្នកសង្កេតការប៉ុណ្ណោះ។ សវនាការនេះ យើងបានជម្រាបរួចហើយកាលពីថ្ងៃព្រហស្បតិ៍ថា ធ្វើសវនាការស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីដែលពាក់ព័ន្ធទៅនឹងរបាយការណ៍របស់អ្នកជំនាញ ចន ខាំប៊ែល។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី!

[០៩:១១:០៩]

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម។ សូមជម្រាបសួរអស់លោក លោកស្រីទាំងក្នុង ទាំងក្រៅសាលសវនាការ។ ជាដំបូង ខ្ញុំត្រូវបានគេជម្រាបមុនពេលដែលខ្ញុំមកដល់ពេលនេះថា មេធាវីលោក នួន ជា មានបញ្ហាមួយចំនួនដែលចង់លើកឡើងនៅក្នុងសវនាការនេះ ដើម្បីនិយាយទាក់ទងទៅនឹងកូនក្តីរបស់គាត់ ដោយសារកូនក្តីរបស់គាត់មានបញ្ហាវិលមុខ។ នេះគឺជាអ្វីដែលមេធាវីការពារក្តីលោក នួន ជា ចង់ជម្រាបទៅអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ បញ្ហាមានអីគឺក្រោយពេលចប់សវនាការទី១ អង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យភាគីពាក់ព័ន្ធដទៃទៀត លើកឡើងនូវបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងសវនាការបន្ទាប់។

យើងមិនអនុញ្ញាតឲ្យទេ! សូមលោកមេធាវីការពារក្តី ក្រុមការពារក្តីលោក អៀង សារី ធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន!

[០៩:១២:១៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងចាប់ផ្តើមនូវសារណារបស់ខ្ញុំលោកប្រធាន។ ជាដំបូង ក្នុងនាមឲ្យក្រុមលោក អៀង សារី ទាំងមូល ទាំងលោក អាង ឧត្តម ផងដែរ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះដែលបានជួយដល់បញ្ហាមួយចំនួន។

ជាដំបូង គឺសូមថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះដែលបានអនុញ្ញាតឲ្យលោក អៀង សារី ត្រូវបានធ្វើការពិនិត្យសុខភាពដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រជាច្រើន រួមបញ្ចូលទាំងលោកដុកទ័រ ខាំប៊ែល។ យើងសូមថ្លែងអំណរគុណ ហើយជាបន្ទាប់ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះដែលបានដំណើរការសវនាការសាធារណៈចំនួនពីរទាក់ទងទៅនឹងបញ្ហាសុខភាពរបស់លោក អៀង សារី ហើយយើងសូមថ្លែងអំណរគុណ ដែលយើងបានទទួលនូវរបាយការណ៍ ហើយនិងបានស្តាប់នូវសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត។ ហើយនៅក្នុងឱកាសនេះផងដែរ ក៏យើងបានទទួលនូវឱកាសដើម្បីធ្វើការសួរដេញដោលទៅលើលោកវេជ្ជបណ្ឌិត។

[០៩:១៣:៣០]

ទី៣ យើងសូមថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះដែលបានផ្ដល់ឱកាសនេះ ដើម្បីឲ្យខាងមេធាវី អៀង សារី ធ្វើសារណាទាក់ទងទៅនឹងសក្ខីកម្មរបស់របស់លោកវេជ្ជបណ្ឌិត ខាំប៊ែល នៅថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១២។

ខ្ញុំសូមធ្វើការសង្ខេបនៅលើគំនិតរបស់លោក ថូម៉ាស ជេហ្វឺសុន ដែលជាបិតាបង្កើតសហរដ្ឋអាមេរិកមួយ ហើយគឺជាអ្នកនិពន្ធចម្បងនៅក្នុងការប្រកាសឯករាជ្យ ហើយនិងជាប្រធានាធិបតីទី៣ របស់សហរដ្ឋអាមេរិក។ ការបញ្ចេញនូវមតិ និងការយល់ឃើញដ៏ស្មោះត្រង់ មិនទាមទារអ្វីឲ្យលើសពីការពន្យល់ ហើយនិងការយល់គ្នាទៅវិញទៅមក ដើម្បីធ្វើឲ្យយើងទាំងអស់គ្នារួបរួមគ្នានៅក្នុងមធ្យោបាយមួយចំនួន ដែលធ្វើឲ្យពួកយើងអាចធ្វើដំណើរទៅជាមួយគ្នាបាន។ ហើយក្នុងករណីរបស់យើងផ្ទាល់ ខ្ញុំសូមបន្ថែមថា គឺដើម្បីស្វែងរកនូវដំណោះស្រាយដែលអាចទទួលយកបាន និងប្រកបដោយយុត្តិធម៌។ យើងអាចនិយាយដោយជឿទុកចិត្តថា យើងកំពុងតែធ្វើ ហើយយើងបានចាប់ផ្ដើមស្វែងរកនូវការពិត ដើម្បីសង្ឃឹមថា យើងអាចទទួលបាននូវការយល់គ្នាទៅវិញទៅមក ដើម្បីឲ្យយើងទាំងអស់គ្នាអាចដោះស្រាយជាមួយនឹងការប្រឈមផ្នែកសុខភាពក្នុងពេលបច្ចុប្បន្នរបស់លោក អៀង សារី។ ហើយការប្រឈមទាំងអស់នេះទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចជានៅក្នុងពេលអនាគតឆាប់ៗខាងមុខនេះ វានឹងអាចប៉ះពាល់ទៅដល់កិច្ចដំណើរការនីតិវិធី។

[០៩:១៤:៥៨]

ហើយការប៉ះពាល់នេះគឺប្រាកដណាស់ ពិតជាប៉ះពាល់ទៅដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋាន ដែលធានាចំពោះលោក អៀង សារី ក៏ដូចជាប្រជាជនកម្ពុជាទាំងអស់ដោយមាត្រា៣១ និង៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏ដូចជាមាត្រាទី១៤ នៃលក្ខន្តិកៈ --កតិកាសញ្ញាអន្តរជាតិសិទ្ធិប្រជាជន សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ហើយក៏មិនត្រឹមតែមានបញ្ចូលនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែមានទាំងនៅក្នុងកិច្ចព្រមព្រៀងច្បាប់ស្ដីពីការបង្កើត និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ផងដែរ។ ទោះបីថាយើងមានសំណួរជាច្រើនដែលយើងបានចោទសួរទៅលើលោកវេជ្ជបណ្ឌិតទាំងនៅក្នុងសវនាការថ្ងៃទី២១ ខែ៩ ក៏ដូចជានៅថ្ងៃទី០៨ ខែវិច្ឆិកា បានលើកឡើងអំពីបញ្ហានៃលទ្ធភាព ឬក៏សមត្ថភាពនៅក្នុងការចូលរួមសវនាការពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយនិងអាចចូលរួមបានដោយមានអត្ថន័យ ដោយមានន័យ

នៅក្នុងកិច្ចដំណើរការនីតិវិធីក៏ដោយ ប៉ុន្តែយើងមិនត្រូវភ្លេចនូវការពិតមួយដែលថាយើងដែលជាក្រុមការពារ អៀង សារី មិនបានធ្វើការលើកសារណាទាក់ទងទៅនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី នោះឡើយ។

[០៩:១៦:២៩]

ចំពោះរបាយការណ៍ៗនយោបាយគឺសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត ក៏ដូចជារបស់ផ្នែកខាងវេជ្ជបណ្ឌិតផងដែរ បាននិយាយអំពីស្ថានភាពរបស់ជនជាប់ចោទដែលមានវ័យ៨៨ឆ្នាំ នៅក្នុងស្ថានភាពវេជ្ជបណ្ឌិតដែល -- ស្ថានភាពវេជ្ជសាស្ត្រដែលគួរឲ្យយកចិត្តទុកដាក់។ ហើយវាបង្ហាញយ៉ាងច្បាស់ថាបញ្ហានៃសមត្ថភាពគឺវាមានចំណុចមួយចំនួនដែលយើងត្រូវគិតពិចារណា ហើយត្រូវតែប្រឈមដើម្បីអាចធ្វើឲ្យមានការយោគយល់គ្នាទៅវិញទៅមក ហើយនិងដើម្បីឲ្យយើងរួមគ្នានៅក្នុងការស្វែងរកមធ្យោបាយមួយដើម្បីទទួលបានដំណោះស្រាយ ដែលអាចទទួលយកបាន និងប្រកបដោយយុត្តិធម៌។

ជាពិតណាស់ យើងមិនទាន់ទៅដល់ទីនោះទេ យើងសូមលើកឡើងថាការប្រើប្រាស់សវនាការនៅថ្ងៃនេះ ដើម្បីធ្វើការលើកឡើងនូវសារណាដែលមានទំហំវែងទាក់ទងទៅនឹងសមត្ថភាពរបស់ -- សម្បទារបស់លោក អៀង សារី មិនមែនជារឿងអ្វីដែលថាវាឆាប់រហ័សពេកនោះទេ។ ប៉ុន្តែប្រសិនបើមានការមិន -- ប្រសិនបើយើងមិនចំណាយពេលឲ្យបានហួសហេតុពេកនោះទេ យើងសូមធ្វើការបែងចែកពេលវេលាទៅដល់ភាគីនានាដើម្បីធ្វើការលើកអំពីមតិរបស់ពួកគេផ្ទាល់។

[០៩:១៧:៤៦]

លោកចៅក្រម -- លោកស្រី ខាតវ៉ាយច៍ បាននិយាយនៅពេលបញ្ចប់សវនាការកាលពីពេលលើកមុនថា “ក្នុងរយៈពេលបច្ចុប្បន្ននេះគឺលោក អៀង សារី បានលះបង់សិទ្ធិមានវត្តមានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះសាក្សីទាំងអស់ដែលមាននៅក្នុងបញ្ជីនៃខែវិច្ឆិកា ហើយក៏អាចនិយាយថាដល់ខែធ្នូផងដែរ”។ អានេះគឺៗផ្អែកទៅលើដំណើរការ ឬក៏ផ្អែកទៅលើល្បឿននៃកិច្ចដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះ។ ហេតុដូច្នេះហើយ ក្រៅពីអង្គហេតុដែលថាមិនទាន់មានការលើកឡើងអំពីសារណាទាក់ទងទៅនឹងសម្បទារបស់លោក អៀង សារី ដែលជាការចោទសួរទោះបីថា ជាការលើកសារណា ឬមួយក៏ជាសំណើសុំក៏ដោយ បញ្ហាសំខាន់គឺថា យើងមិនទាន់ដល់ពេលវេលាត្រឹមត្រូវគ្រប់គ្រាន់ដើម្បីធ្វើការពិភាក្សាឡើយ ពីព្រោះកិច្ចដំណើរការនីតិវិធីអាចបន្តទៅមុខបានដោយមិនមានការរំខាន ទោះបីជាលោក អៀង សារី មានបញ្ហាស្ថានភាពសុខភាពបែបណាក៏ដោយ។

[០៩:១៨:៥២]

ហេតុដូច្នេះហើយយើងអាចលើកឡើង ដោយច្បាស់លាស់ដោយមានភាពងាយស្រួលនៅរយៈពេលមួយចំនួនដែលយើងអាចជជែកគ្នាអំពីលទ្ធផល ក៏ដូចជាបញ្ហាទាក់ទងទៅនឹងរបាយការណ៍របស់លោកវេជ្ជបណ្ឌិត ខាំប៊ែល ក៏ដូចជាសក្ខីកម្មរបស់គាត់ផងដែរ។ យើងមិនឃើញថាមានចំណុចណាមួយដែលយើងត្រូវធ្វើនៅពេលនេះឡើយ។ ការណ៍នេះមិនគួរត្រូវបានយើងយល់ឃើញថាជាការទាមទារ ឬមួយក៏ជាការប្រើប្រាស់ដោយគោលដៅក្នុងការទទួលយកទស្សនៈដែលទទួលឡើង -- ដែលលើកឡើងដោយលោក ខាំប៊ែល នោះឡើយ។

យើងគិតថា យើងអាចមិនប្រាកដថាយើងត្រូវតែទទួលយកដោយគ្មានលក្ខខណ្ឌចំពោះទស្សនៈដែលលើកឡើងដោយលោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត ខាំប៊ែល នោះឡើយ។ ផ្ទុយទៅវិញយើងធ្វើការលើកលែងចំពោះវិធីសាស្ត្រក៏ដូចជាទំហំនៃការធ្វើការត្រួតពិនិត្យផ្នែកសុខភាពទៅលើលោក អៀង សារី ក្នុងពេលចុងក្រោយនេះ ហើយក៏ដូចជាការធ្វើសន្និដ្ឋានដែលមានលក្ខណៈជាបែបច្នៃប្រឌិត ឬក៏លក្ខណៈប្រឌិតខ្លះមួយចំនួនក៏ដោយ ដែលថា ព្រះរាជអាជ្ញាបានលើកឡើងថា ខ្ញុំបានផ្តល់នូវភស្តុតាងអ្វីដែលខ្ញុំបានជួប អ្វីដែលខ្ញុំបានធ្វើ គឺជាអ្នក -- មនុស្សម្នាក់ដែលយើងពណ៌នាដោយលោកវេជ្ជបណ្ឌិត ខាំប៊ែល ថាជាមនុស្សបែបនេះ។ ប៉ុន្តែយើងមិនមានពេលវេលាដើម្បីពិនិត្យទៅលើអង្គសេចក្តីនៃសក្ខីកម្ម ហើយនិងស្វែងរកទៅលើអ្វីដែលគាត់បានរកឃើញនោះឡើយ។ ប៉ុន្តែយើងត្រូវចងចាំថា ពេលវេលាគឺវាសមគ្រប់គ្រាន់រួចទៅហើយ ហើយយើងសូមលើកឡើងថា វាមានហេតុផលគ្រប់គ្រាន់ ហើយវាចាំបាច់ ដើម្បីឱ្យអង្គជំនុំជម្រះជំរុញឱ្យអ្នកជំនាញ ដែលមិនពាក់ព័ន្ធ ឬក៏មិនមានទំនាក់ទំនងជាមួយនឹងលោកវេជ្ជបណ្ឌិត ខាំប៊ែល ក្នុងការពិនិត្យទៅលើលោក អៀង សារី ដើម្បីផ្តល់នូវការវាយតម្លៃដែលមានលក្ខណៈជាឯករាជ្យ។

[០៩:២០:៥៦]

ខ្ញុំសូមបន្ថែមផងដែរថា នេះគឺជាបញ្ហាទូទៅមួយនៅក្នុងប្រព័ន្ធស៊ីវិលឡូ ទោះបីថាអ្នកជំនាញត្រូវបានជ្រើសរើសពីបញ្ជីដោយអង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏សក្ខីកម្មរបស់គាត់អាចថាមានការយល់ឃើញ ឬក៏មានការចោទសួរមួយចំនួន ទាក់ទងទៅនឹងសក្ខីកម្មចំពោះគាត់។ ហើយក៏គ្មានអ្វីដែលរារាំងអង្គជំនុំជម្រះ ក៏ដូចជាចៅក្រមមិនឱ្យជ្រើសរើសអ្នកជំនាញដទៃទៀតនោះឡើយ។ ហើយក៏មិនអាចរារាំងភាគីមិនឱ្យផ្តល់អនុសាសន៍ទៅដល់ចៅក្រម ដើម្បីផ្តល់យោបល់ទៅឱ្យចៅក្រម ថាតើអ្នកណា

ដែលអាចត្រូវបានកោះហៅបន្ថែម ដើម្បីមកធ្វើជាអ្នកជំនាញនោះឡើយ។

[០៩:២១:៤១]

ដូចដែលលោកវេជ្ជបណ្ឌិត ខាំប៊ែល ខ្លួនគាត់ផ្ទាល់បានទទួលស្គាល់នៅក្នុងសក្ខីកម្មរបស់គាត់ថា ទស្សនៈរបស់អ្នកជំនាញទី២ ឬក៏អ្នកជំនាញទី៣ ហ្នឹង គឺជាការមួយដែលត្រឹមត្រូវនៅក្នុងផ្នែកវេជ្ជសាស្ត្រ។ ហើយយើងសូមបញ្ជាក់ថា នេះគឺជាអ្វីដែលយើងព្យាយាមចង់ឲ្យមានការបញ្ចេញទស្សនៈរបស់អ្នកជំនាញទី២ ឬក៏ទី៣។

លោកវេជ្ជបណ្ឌិត ប៊ូស ចាន (Bursztajn) បានធ្វើការប្រឹក្សាទៅលើស្ថានភាពស្ម័គ្រចិត្ត ហើយដោយសារតែយើងមិនទទួលបានអ្វីដែលគាត់ ដែលយើងអាចផ្តល់ទៅគាត់បាន។ គាត់បានដាក់នូវលិខិតមួយ ហើយយើងបានបញ្ជាក់ថា លិខិតរបស់គាត់មានលក្ខណៈគួរឲ្យចាប់អារម្មណ៍។ វាមិនមែនជារបាយការណ៍វេជ្ជសាស្ត្រនោះទេ។ ប៉ុន្តែរបាយការណ៍នេះវាធ្វើឲ្យយើងលើកជាបញ្ហាទាក់ទងទៅនឹងវិធីសាស្ត្រ ក៏ដូចជាការអនុវត្តរបស់លោកវេជ្ជបណ្ឌិត ខាំប៊ែល ទោះបីថាគាត់មិនមាននូវឯកសារទាំងអស់ដែលលោកវេជ្ជបណ្ឌិតខាំប៊ែល មានក៏ដោយ រួមបញ្ចូលទាំងរបាយការណ៍ក៏ដូចជាការត្រួតពិនិត្យសុខភាព។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វេជ្ជបណ្ឌិត ប៊ូស ចាន បានផ្តល់នូវការវាយតម្លៃជាមូលដ្ឋាន។

[០៩:២៣:០៧]

លោកវេជ្ជបណ្ឌិត ប៊ូស ចាន មិនមានទំនាក់ទំនង ហើយក៏មិនមានជាប់ទាក់ទងជាមួយនឹងក្រុមមេធាវីការពារក្តី អៀង សារី ឬក៏លោក អៀង សារី នោះឡើយ។ ហើយលោកវេជ្ជបណ្ឌិតមិនដែលជួបជាមួយនឹងលោក អៀង សារី ដោយផ្ទាល់ ឬក៏និយាយដោយផ្ទាល់នោះឡើយ គឺគាត់ផ្តល់នូវរបាយ-ការណ៍នេះតាមរយៈអ៊ីម៉ែល ហើយគាត់គ្រាន់តែផ្តល់របាយការណ៍តាមមូលដ្ឋានស្ម័គ្រចិត្តតែប៉ុណ្ណោះ។ ប៉ុន្តែលោកវេជ្ជបណ្ឌិត ប៊ូស ចាន ត្រូវបានគេទទួលស្គាល់ថាជាវេជ្ជបណ្ឌិតដ៏ល្បី ហើយមានការគោរព ហើយគាត់មានកេរ្តិ៍ឈ្មោះយ៉ាងល្បីល្បាញបំផុតនៅក្នុងសហរដ្ឋអាមេរិក ហើយគាត់ក៏ជាវេជ្ជបណ្ឌិតដែលមានកេរ្តិ៍ឈ្មោះនៅក្នុងសាកលវិទ្យានានា នៅសហរដ្ឋអាមេរិកផងដែរ។ គាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបញ្ហាសម្បទា រួមបញ្ចូលទាំងទំនាក់ទំនងរវាងសម្បទា និងកត្តាផ្នែករូបរាងកាយ ឬក៏ផ្លូវចិត្តផងដែរ។

[០៩:២៤:០៤]

គាត់ត្រូវបានគេចាត់ទុកថាជាអ្នកជំនាញនៅខាងផ្នែកកោសល្យវិច័យផងដែរ។ ហេតុដូច្នេះហើយគឺយើងមិនគួរ មិនធ្វើការទាក់ទងជាមួយលោកវេជ្ជបណ្ឌិត ប៊ូស ចាន ឡើយ។ ហេតុដូច្នេះហើយគឺយើងអាចឲ្យគាត់ធ្វើការសម្រេចដោយសុទ្ធចិត្ត ហើយនិងធ្វើការដោះស្រាយ ដើម្បីកុំឲ្យបញ្ហាទាំងអស់វាកើតឡើងទៅជាបញ្ហានៅពេលអនាគត ដើម្បីធ្វើការវាយតម្លៃទៅលើស្ថានភាព និងសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ។

នេះគឺជាបញ្ហាមួយដែលយើងមិនត្រូវទុកចោលមួយកន្លែងនោះឡើយ។ ដោយលោក អៀង សារី មានអាយុជាង៨០ឆ្នាំ មានបញ្ហាបេះដូង មានបញ្ហាក្នុងការអាន ហើយនិងមានបញ្ហាជាច្រើន គឺយើងអាចនិយាយថាមានបញ្ហាមួយចំនួន។ ដូច្នេះហើយ យើងគិតថា លោក អៀង សារី មិនមានចំណុចណាមួយដែលថាប្រសើរជាង អាចប្រសើរឡើងវិញនោះឡើយ។ ដូច្នេះហើយ បញ្ហាបច្ចុប្បន្ន គឺថាយើងត្រូវម៉េចតាមដែលយើងអាចធ្វើទៅបាន ទោះបីថាវេជ្ជបណ្ឌិត ខាំប៊ែល មានលក្ខណៈសប្បុរសធម៌ ឬក៏រៀបរាប់បានល្អទាក់ទងទៅនឹងស្ថានភាពរបស់លោក អៀង សារី ក៏ដោយ។ ហើយគាត់បាន បញ្ជាក់ថា យើងត្រូវតែមានការព្យាយាមការពារ ទាក់ទងទៅនឹងស្ថានភាពសុខភាពនៅពេលអនាគតរបស់លោក អៀង សារី។

[០៩:២៥:៥៤]

យើងសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងធ្វើការទាក់ទងជាមួយដុកទ័រ លោកវេជ្ជបណ្ឌិត ប៊ូស ចាន ដើម្បីស្នើសុំឲ្យមានការវាយតម្លៃជាឯករាជ្យទៅលើស្ថានភាពរបស់លោក អៀង សារី ហើយនិងផ្តល់ឱកាសដល់ឌុក -- លោកវេជ្ជបណ្ឌិត ប៊ូស ចាន ដើម្បីផ្តល់នូវការវាយតម្លៃដែលលម្អិតនិងពេញលេញ ហើយយើងស្នើសុំផងដែរដល់អង្គជំនុំជម្រះ ដើម្បីផ្តល់ដល់លោកវេជ្ជបណ្ឌិត ប៊ូស ចាន នូវព័ត៌-មាននានាដែលបានផ្តល់ទៅដល់លោកវេជ្ជបណ្ឌិត ខាំប៊ែល។ ក្នុងនោះ គឺរួមបញ្ចូលទាំងរបាយការណ៍វេជ្ជសាស្ត្រទាំងអស់ និងការវាយតម្លៃវេជ្ជសាស្ត្រទាំងអស់ទាក់ទងទៅនឹងលោក អៀង សារី ប្រតិចារឹកនៃសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិតទាំងអស់ទាក់ទងទៅនឹងស្ថានភាពរបស់លោក អៀង សារី និងឯកសារពាក់ព័ន្ធនានាក៏ដូចជាអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង។

ប្រហែលជាអង្គជំនុំជម្រះសាលាដំបូង គិតថារបាយការណ៍បែបនេះហាក់ដូចជាមិនទាន់ដល់ពេលវេលាដែលត្រូវធ្វើនោះឡើយ ប៉ុន្តែយើងសូមបញ្ជាក់ថា យើងគ្រាន់តែចង់ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងដើម្បីឲ្យដឹងថាក្រុមការពារក្តីលោក អៀង សារី សូមស្នើសុំដោយគោរព ឲ្យមានការ

វាយតម្លៃដែលឯករាជ្យ។ ទាក់ទងទៅនឹងការវាយតម្លៃរបស់លោកវេជ្ជបណ្ឌិត ខាំប៊ែល ក៏ដូចជាការវាយតម្លៃនិងជំនាញរបស់គាត់ផងដែរ ក៏ដូចជាចេតនារបស់គាត់ក្នុងការផ្តល់សក្ខីកម្មផងដែរ។

[០៩:២៧:១២]

យើងនៅតែទាមទារ យើងនៅតែទទូចសុំឲ្យមានការវាយតម្លៃដោយឯករាជ្យពីលោកវេជ្ជបណ្ឌិតដទៃទៀតនៅពេលអនាគត។ ជាការពិតហើយយើងមិនមានការជំទាស់ទៅនឹងព្រះរាជអាជ្ញា ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំឲ្យមានអ្នកជំនាញដោយខ្លួនគេផ្ទាល់នោះឡើយ។ ព្រោះថាដូចគ្នានេះដែរ ពួកគេក៏មិនគួរមានការជំទាស់ ឬក៏មិនមានការប្រឆាំងទៅលើការស្នើសុំណាមួយដែលមេធាវីការពារក្តីលោក អៀង សារី នោះផងដែរ។ នេះគឺជាទស្សនៈទូទៅរបស់ព្រះរាជ -- របស់មេធាវីការពារក្តី ដែលព្រះរាជអាជ្ញាគួរតែគិត គួរតែពិចារណា ទាក់ទងទៅនឹងការស្នើសុំអ្នកជំនាញដែលជាអ្នកជំនាញដែលលើកឡើងដោយ ស្នើសុំឡើយដោយខាងព្រះរាជ -- ខាងមេធាវីការពារក្តី។

ដូច្នេះ ហើយយើងបានបញ្ជាក់រួចទៅហើយថា យើងមាននូវប្រវត្តិរូបសង្ខេបរបស់លោកវេជ្ជបណ្ឌិត ដើម្បីឲ្យខាងភាគីនានាពិនិត្យមើល។

[០៩:២៨:១៦]

លោកប្រធានអង្គជំនុំជម្រះ នេះគឺជាការសង្កេតក៏ដូចជាការស្នើសុំរបស់យើង។ ប្រសិនបើអង្គជំនុំជម្រះចង់ឲ្យយើងធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរ ទាក់ទងទៅនឹងការតែងតាំងអ្នកជំនាញបន្ថែមជាពិសេសគឺទាក់ទងទៅនឹងវេជ្ជបណ្ឌិត ប៊ូស ចាន ដែលយើងបានស្នើ យើងនឹងធ្វើសុំជាលាយក្ខណ៍អក្សរជូនទៅអង្គជំនុំជម្រះ។ ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបដិសេធ ឬក៏មិនទទួលយកនូវសំណើសុំរបស់យើង យើងស្នើសុំឲ្យមានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុ។ ប្រសិនបើមិនមានសំណួរ ឬក៏មិនមានការចោទសួរទេ នេះគឺជាការស្នើសុំរបស់មេធាវីការពារក្តី ហើយយើងសុំថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះដែលបានផ្តល់ឱកាសដល់ការពិនិត្យពិច័យទៅលើលោក អៀង សារី ក៏ដូចជាការបង្ហាញនូវរបាយការណ៍។ ហើយយើងសូមសង្កត់ធ្ងន់ថា យើងបានកត់សម្គាល់ថានេះគឺជាការខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះ ហើយយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាលោកចៅក្រមទាំងមូល។ សូមអរគុណ។

[០៩:២៩:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣២:០៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កាណាវាស អង្គជំនុំជម្រះសាលាដំបូង មានសំណួរមួយចំនួន ក្រោយពីលោកបានធ្វើសេចក្ដីសន្និដ្ឋាននេះ។ យើងខ្ញុំមិនយល់ច្បាស់លាស់ ថាតើលោកបានអះអាងថា នៅពេលនេះ លោក អៀង សារី គាត់មិនមានសម្បទាគ្រប់គ្រាន់ ឬក៏គាត់មានសម្បទាគ្រប់គ្រាន់? ឬក៏ឧទាហរណ៍ថា តើគាត់អាចចូលរួមសវនាការពីបន្ទប់ឃុំឃាំងខាងក្រោមដែរឬទេ? ប្រសិនបើលោកលើកឡើងថា លោក អៀង សារី នៅតែមានសម្បទាគ្រប់គ្រាន់ នោះ គឺយើងខ្ញុំយល់ហើយ។ សារណារបស់លោកបានបញ្ជាក់ហើយ ថាគាត់ទាន់ខ្សោយ គាត់ជាមនុស្សចាស់ វាមិនមែនជាបញ្ហានៅទីនេះនោះទេ។

[០៩:៣៣:០០]

ក៏ប៉ុន្តែប្រសិនបើលោកនៅតែលើកឡើង -- នៅតែអះអាងថា គាត់មានសម្បទាគ្រប់គ្រាន់ ក៏ប៉ុន្តែគាត់មានតែបញ្ហាសុខភាពតែប៉ុណ្ណោះ។ ហេតុអ្វីបានជាលោកស្នើសុំឲ្យតែងតាំងអ្នកជំនាញផ្សេងមួយទៀត តើមូលហេតុអ្វី ដែលលោកចង់ស្នើដូច្នេះ? សូមឲ្យលោកបញ្ជាក់ឲ្យច្បាស់។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់លាស់ ជំហររបស់យើងខ្ញុំគឺថាគឺគាត់មិនមានសម្បទាគ្រប់គ្រាន់នោះទេ។ គាត់មិនអាចចូលរួមសវនាការ ដោយមានន័យគ្រប់គ្រាន់ផ្អែកទៅតាមបទដ្ឋានអន្តរជាតិនោះទេ ដែលអង្គជំនុំជម្រះនេះ ត្រូវតែគោរពតាម ហើយគោរពរដ្ឋធម្មនុញ្ញកម្ពុជាផងដែរ។ ដូច្នេះ នេះជាចំណុចផ្ដើមដែលយើងលើកពីដំបូង ក៏ប៉ុន្តែយើងខ្ញុំសូមលើកឡើងអំពីវិធានការ វិធីសាស្ត្ររបស់យើង ដោយសារតែយើងស្ដាប់ចម្លើយសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីដែលពុំទាមទារការចូលរួមរបស់លោក អៀង សារី នោះ ហើយដោយសារតែលោក អៀង សារី មានបានពិនិត្យមើលឯកសារមួយចំនួនជាមួយយើងខ្ញុំហើយ ហើយគាត់លើកឡើងថា គាត់នឹងបោះបង់សិទ្ធិ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីជួយក្រុមមេធាវីការពារក្ដីរបស់ខ្លួន ជួយជ្រោមជ្រែង និងតាមដានដេញដោលទៅលើសាក្សី។

[០៩:៣៤:៣២]

យើងខ្ញុំឯកភាពឲ្យដំណើរការសវនាការនេះ ដំណើរទៅមុខ ដោយការឯកភាព -- មានឯកភាពពីលោក អៀង សារី ដែលថាធ្វើយ៉ាងឲ្យគាត់នេះ ក៏អាចមានលទ្ធភាពតាមដានពីបន្ទប់ឃុំឃាំង ហើយឲ្យគាត់មានលទ្ធភាពតាមដានដូចដែលគាត់ធ្លាប់ធ្វើពីមុន មុនពេលចូលមន្ទីរពេទ្យនាពេលនេះ។ យើងដឹងហើយ ថាមានតែថ្ងៃ -- កាលពីមុនមានតែពេលមួយតែប៉ុណ្ណោះដែលគាត់ថា គាត់វិលមុខ ហើយមិនក៏មិនអាចតាមដាន។ ក៏ប៉ុន្តែធ្វើយ៉ាងណាឲ្យគាត់មានលទ្ធភាពតាមដានសវនាការនេះហើយកុំឲ្យ -- ហើយធ្វើយ៉ាងនេះឲ្យយើងអាចធ្វើការជួបជាមួយគាត់នា ៥នាទី ឬក៏១០នាទី ដើម្បីសាកសួរទៅដល់គាត់។

វេជ្ជបណ្ឌិត ខាំប៊ែល គាត់បានលើកឡើងថា លោក អៀង សារី ងោកនោះ ហើយគឺវាមិនប៉ះពាល់អ្វីធ្ងន់ធ្ងរនោះទេ។ យើងត្រូវពិចារណាឲ្យបានច្បាស់លាស់នេះ ជាសវនាការមិនមែនការធ្វើបទបឋកថានោះទេ។ ដូច្នេះហើយគឺធ្វើយ៉ាងណាឲ្យលោក អៀង សារី នេះមានសុខភាពរឹងមាំដូចលោកសាស្ត្រាចារ្យ ខាំប៊ែល ធ្វើយ៉ាងម៉េចឲ្យគាត់ដូចលោក សាស្ត្រាចារ្យ ខាំប៊ែល។ ដោយសារតែលោកសាស្ត្រាចារ្យ ខាំប៊ែល មានវ័យតិចជាងលោក អៀង សារី។

[០៩:៣៥:៥៤]

ដូច្នេះយើងខ្ញុំយល់ឃើញថានៅក្នុងពេលនេះ លោក អៀង សារី គឺគាត់មិនមានលទ្ធភាពចូលរួមការការពារក្ដីរបស់គាត់ដោយខ្លួនឯងនោះទេ។ អ្វីដែលយើងដំណើរការក្នុងពេលសវនាការនេះ ដោយសារតែនៅពេលនេះយើងមានសាក្សី ហើយអង្គជំនុំជម្រះត្រូវតែស្ដាប់ភស្តុតាង និងយកភស្តុតាងពីសាក្សីទាំងអស់នោះ។ ក៏ប៉ុន្តែការស្ដាប់សក្ខីកម្មទាំងអស់នេះ ធ្វើយ៉ាងណាគឺមិន -- វាមិនប៉ះពាល់ទៅដល់លោក អៀង សារី មែន ហើយគាត់បានបោះបង់សិទ្ធិ គាត់មានសិទ្ធិបោះបង់មិនចូលរួម ហើយយើងអាចដំណើរការទៅមុខបាន។ យើងអាចគិតថា ប្រហែលជានៅក្នុងខែធ្នូ និងខែមករា គឺគាត់អាចមានសុខភាពធូរស្បើយឡើងវិញ ហើយប្រហែលជាយើងអស់សាក្សីនៅពេលនោះ។

ជំហររបស់យើងខ្ញុំនោះ គឺថាស្ថានភាពនេះ គឺមិនមែនថា វាមិនមានការវិវត្តនោះទេ គឺថា យើងនៅតែមានជំហរមូលដ្ឋានរបស់យើង ហើយអ្វីៗត្រូវតែមានសេចក្ដីសម្រេច។ ប្រសិនបើអង្គជំនុំជម្រះជឿជាក់នូវអ្វីដែលលោក ខាំប៊ែល បានលើកឡើងថា លោក អៀង សារី មានសមត្ថភាពនិងសម្បទាគ្រប់គ្រាន់នោះគឺថា អ្វីដែលយើងត្រូវធ្វើហ្នឹង គឺថាបង្ខំឲ្យគាត់ហ្នឹងចាប់ចិត្ត -- ចាប់អារម្មណ៍និងយកចិត្តទុកដាក់នៅក្នុងសវនាការនេះ។

[០៩:៣៧:២០]

ហើយមិនមែនថា យើងអាចឲ្យលោក អៀង សារី នោះនៅបន្ទប់ឃុំឃាំងខាងក្រោមនោះទេ។ យើងក៏អាចធ្វើយ៉ាងណាឲ្យគាត់នេះ មកក្នុងបន្ទប់សវនាការនេះចូលរួមផងដែរ ហើយពិនិត្យមើលថា តើគាត់ងោក ឬមួយក៏យ៉ាងម៉េច? ហើយយើងក៏ត្រូវសួរខ្លួនឯង ថាតើនេះជាបទដ្ឋានដែលបានគោរពតាមត្រឹមត្រូវដែរឬទេ? ចំពោះបុគ្គលដែលគាត់មានលទ្ធភាព ឬមិនមានលទ្ធភាពចូលរួមក្នុងនេះ ហើយយើងគិតថា តុលាការនេះនឹងជាតុលាការគំរូសម្រាប់អនាគតនោះ។ ទាំងអស់នេះគឺជាគំនិត និងជំហរដែលយើងត្រូវពិចារណា។

យើងខ្ញុំសូមលើកឡើងថា ដោយសារតែយើងមានរបាយការណ៍ពីវេជ្ជបណ្ឌិត ខាំប៊ែល និងសក្ខីកម្មរបស់គាត់រួចមកហើយ។ របាយការណ៍ សក្ខីកម្មទាំងអស់នេះវាមានផលសម្រាប់យើង។

ដូច្នេះហើយយើងដឹងថា បញ្ហានេះយើងត្រូវពិនិត្យមើលឡើងវិញនៅពេលដែលលោក អៀង សារី គាត់បោះបង់សិទ្ធិស្តាប់ចម្លើយសាក្សី។ មិនមែនថា នៅតាមផ្លូវយើងចេះតែដើរទាត់កំប៉ុងឲ្យវាដំណើរការហ្នឹងវាទៅអ៊ីចឹងរួចហើយនោះទេ។ ហើយយើងដឹងហើយថា ស្ថានភាពណាមួយលោក អៀង សារី គឺអាចមានស្ថានភាពធូរស្បើយឡើងវិញ ហើយប្រសិនបើលោកសាស្ត្រាចារ្យ ខាំប៊ែល នោះចម្លើយរបស់គាត់ត្រឹមត្រូវរបាយការណ៍របស់គាត់ត្រឹមត្រូវ ហើយវេជ្ជបណ្ឌិតកម្ពុជា គឺខុសទាំងអស់នោះ។ គឺថា ដោសារតែគឺគាត់វិលមុខនោះ ដោយសារតែខ្វះអុកស៊ីសែន ហើយអ្វីដែលអាចព្យាបាលគាត់បាន គឺធ្វើការពត់នៅក្បាលរបស់គាត់ ហើយធ្វើចលនាដើម្បីឲ្យគាត់ហ្នឹងមានស្ថានភាពល្អឡើងវិញនោះ គឺវាជាចំណុចមួយដែលយើងត្រូវពិចារណា។

[០៩:៣៩:០៦]

នេះគឺជាអ្វីដែលយើងខ្ញុំសូមលើកឡើង។ យើងស្ថិតនៅក្នុងស្ថានភាពកាលៈទេសៈ ប្រឈមមួយដើម្បីរកមធ្យោបាយកុំឲ្យដំណើរការសវនាការនេះរាំងស្ទះ។ យើងនៅក្នុងដំណាក់កាលនេះត្រូវតែគិតគូរពិចារណា ហើយយើងត្រូវយល់អំពីការស្ម័គ្រចិត្តលះបង់សិទ្ធិរបស់លោក អៀង សារី ហើយយើងក៏មិនចង់ឲ្យមានការបំបែកនូវសំណុំរឿងផងដែរ។ ជំហររបស់យើងខ្ញុំនោះ គឺថានៅក្នុងកិច្ចដំណើរការដែលវានឹងរាំងស្ទះនោះ គឺថា ពេលខ្លះទៅមិនអាចដំណើរការទៅមុខនោះទេ ដោយសារតែយើងត្រូវដោះស្រាយទៅលើចំណុចទាំងអស់នេះ។

[០៩:៤០:០០]

នៅក្នុងករណីមួយចំនួននោះ បញ្ហាទាំងឡាយនោះ វាអាច វាលឿនពេកក្នុងការសម្រេចរបស់យើង។ ហើយដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង ស្ថានភាពរបស់លោក អៀង សារី នោះ គឺវាអាចធូរស្បើយឡើងវិញ។ យើងធ្វើយ៉ាងនេះ ដើម្បីសម្របសម្រួល និងជួយទៅដល់កិច្ចដំណើរការរបស់សាលាដំបូងតែប៉ុណ្ណោះ។

យើងចង់ឲ្យមានការពិនិត្យទៅលើគាត់នេះ ឲ្យមានភាពហ្មត់ចត់តែប៉ុណ្ណោះ។ យើងមិនមែនព្យាយាមធ្វើឲ្យសវនាការនេះរាំងស្ទះនោះឡើយ។ យើងគ្រាន់តែព្យាយាមធ្វើការរួមជាមួយនឹងភាគីខាងសហព្រះរាជអាជ្ញា រួមទាំងខាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីដោះស្រាយបញ្ហានេះទាំងអស់គ្នា។ លោកស្មីត នោះបានទទួលស្គាល់ហើយតាំងពីដំណាក់កាលមុននៅពេលមុននោះ។ ប្រសិនបើខ្ញុំចាំមិនខុសនោះទេ គឺគាត់បានបញ្ជាក់ថា “យើងមានសាក្សីគ្រប់គ្រាន់ ហើយយើងគួរតែដំណើរការទៅសិនទៅ ទៅដល់ត្រឹមណា គឺយើងចាំគិតតាមក្រោយ”។

ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំលើកឡើងនេះ គឺឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលលោកស្រីចៅក្រមខាតវ៉ាយថ៍ បានចោទសួរ។

[០៩:៤១:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤២:៣៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានបំណងសួរសំណួរទៅកាន់ក្រុមមេធាវីការពារក្ដីលោកអៀង សារី!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមអភ័យទោសលោក កាណាវាស ដែលអូសបន្លាយពេលវេលានៃការផ្លាស់ប្ដូរគ្នានេះ។ អង្គជំនុំជម្រះចង់បានការបំភ្លឺមួយចំនួន។ នៅពេលដែលកូនក្ដីរបស់លោកបានយល់ព្រមមិនចូលរួមក្នុងសវនាការចំពោះសាក្សីមួយចំនួននោះ ស្ថានភាពគឺមានលក្ខណៈខុសគ្នាពីអ្វីដែលកើតឡើងនៅថ្ងៃនេះ។ កាលពីមុននោះ នៅពេលដែលកូនក្ដីរបស់លោកសម្រាកមន្ទីរពេទ្យនោះ យើងមានលិខិតបញ្ជាក់វេជ្ជសាស្ត្រមួយចំនួនដែលបញ្ជាក់បង្ហាញច្បាស់អំពីបញ្ហាដែល អៀង សារី កំពុងតែទទួលរង ហើយសេចក្ដីសន្និដ្ឋានទាំងអស់នោះ គឺថាមិនបានទទួលយកដោយសាស្ត្រាចារ្យ ខាំប៉ែល នោះទេ។

[០៩:៤៣:៣៤]

អ្វីដែលយើងចង់ដឹងនៅថ្ងៃនេះ គឺថាតើកូនក្ដីរបស់លោកមិនអាចចូលរួមនៅក្នុងសវនាការនេះ ឬក៏គាត់អាចចូលរួមមួយថ្ងៃពេញ ឬក៏លោកយល់ថា យើងធ្វើការរៀបចំសវនាការឡើងវិញដោយសម្របទៅតាមលទ្ធភាពរបស់គាត់ គឺថាបើគាត់មិនអាចចូលរួមបាននោះ តើមានមូលហេតុវេជ្ជសាស្ត្រអ្វីខ្លះដែលលោកលើកឡើងបែបនេះនោះ? លោកមានសំអាងហេតុអ្វីខ្លះ?

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណចៅក្រម ឡាវែន៍។ មិនចាំបាច់សូមទោសដោយសារតែធ្វើឲ្យការអូសបន្លាយការពិភាក្សានេះទេ។ គឺយើងនឹងពន្យល់បញ្ជាក់ទៅលើអ្វីដែលលើកឡើងនេះ។

យើងខ្ញុំនៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើងខ្ញុំ លោកចៅក្រម ឡាវែន៍ នោះគឺថា យើងខ្ញុំបានចំណាយពេលមួយចំនួនជាមួយនឹងកូនក្ដីរបស់យើង លើស៥ ទៅ១០នាទី នោះគឺថាគាត់នឹងមិនអាចផ្ដល់អារម្មណ៍បានទេ គឺគាត់វិលមុខ ធីងធោង គឺគាត់មិនអាចតាមដាននីតិវិធីនោះឡើយ។ ខ្ញុំយល់អ្វីដែលលោកវេជ្ជបណ្ឌិត ខាំប៊ែល បានលើកឡើង គឺវាមានភាពខុសគ្នាទៅនឹងអ្វីដែលយើងជួបជាមួយនឹងលោក អៀង សារី។ មន្ទីរពេទ្យ គឺបានលើកឡើងហើយថា ពួកគាត់គឺបានព្យាបាលអស់ពីសមត្ថភាពរួចមកហើយ។ ហើយគេក៏លើកឡើងថា គេបានដឹងអំពីការធ្វើរបាយការណ៍ផ្សេង ការវិភាគផ្សេង របស់លោក ខាំប៊ែល ទៅលើបញ្ហានេះ ដែលថាមានអាការៈអ្វីដែលឲ្យលោក អៀង សារី វិលមុខ ហើយនិងមិនអាចផ្ដង់អារម្មណ៍បាននោះ។

[០៩:៤៥:២៦]

យើងខ្ញុំសូមលើកឡើងថា សិទ្ធិក្នុងការចូលរួមក្នុងការជំនុំជម្រះក្ដី ជាពិសេសក្នុងការតាមដាននីតិវិធីដ៏យូរអង្វែងបែបនេះ យូរ វែងអន្លាយបែបនេះ និងផ្ដល់ការណែនាំ គឺមិនមែនថាត្រូវតែមានវត្តមាននៅខាងក្រោមគ្រប់ពេលនោះទេ។ ពេលខ្លះទៅគឺវាធ្វើឲ្យគាត់នោះ ងុយគេង គឺថាគាត់ហ្នឹង គាត់ចង់ចូលរួមណាស់ ក៏ប៉ុន្តែដោយសារវ័យរបស់គាត់ បញ្ហាសុខភាពរបស់គាត់ គឺគាត់មិនអាចនោះទេ គឺមិនអាចតាមដានដំណើរការយូរបែបនេះនោះឡើយ។ គឺគាត់មិនអាចចងចាំនូវអ្វី ដែលគាត់បានស្ដាប់ឮ មិនអាចផ្ដល់ការណែនាំមកដល់យើងខ្ញុំផងទៀត។ ដូច្នេះ គឺពេលខ្លះទៅវាធ្វើការឲ្យគាត់នេះផ្ដល់ការណែនាំមកដល់យើងខ្ញុំ ហើយយើងអានឯកសារមួយចំនួនឲ្យគាត់ស្ដាប់ ក៏ប៉ុន្តែមួយ -- នៅក្រោយមួយរយៈពេលមកគឺថាគាត់អស់កម្លាំង ហើយគឺគាត់ហេវហត់ ដូច្នេះហើយគឺគាត់មិនអាចគ្រប់គ្រងខ្លួនឯង និងការស្ម័គ្រចិត្ត

របស់គាត់ផ្តល់ការណែនាំមកយើងផងនោះ។

[០៩:៤៦:៤០]

ដូច្នេះយើងខ្ញុំសូមលើកឡើងថា ក្នុងស្ថានភាពបច្ចុប្បន្នរបស់គាត់ ពេលនេះគឺៗនៅពេលដែលគាត់ចាប់ផ្តើមចូលពេទ្យមកទល់ពេលបច្ចុប្បន្នហ្នឹង គឺនៅតែដដែល គាត់មិនអាចតាមដានកិច្ចដំណើរការនីតិវិធីនេះបាននោះទេ វាអាចកែប្រែ និងផ្លាស់ប្តូរក្នុងពេលណាមួយ។ ខ្ញុំសូមលើកឧទាហរណ៍ថា នៅក្នុងដំណាក់កាលណាមួយដែលយើងអស់សាក្សីមកផ្តល់សក្ខីកម្ម និងដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់ចម្លើយ -- មកផ្តល់សេចក្តីថ្លែងទុក្ខ យើងដឹងហើយថាសាក្សីទាំងអស់នោះ មិនមែនថាមិនពាក់ព័ន្ធនៅក្នុងរឿងក្តីនោះទេ គឺវាពាក់ព័ន្ធទៅនឹងអង្គហេតុមួយពីអង្គហេតុមួយទៅអង្គហេតុមួយ។ ឧទាហរណ៍ថា លោក ហ្វីលីព ស្សូត ប្រសិនបើយើងនៅក្នុងដំណាក់កាលនុ៎ង យើងខ្ញុំនឹងសូមលើកឡើងថា ឲ្យដកគាត់ បំបែកសំណុំរឿងគាត់នោះ គឺចេញពីសំណុំរឿងនេះនៅក្នុងករណីអ៊ីចឹង។

នៅពេលដែលយើងទាក់ទង ពិភាក្សាជាមួយនឹងលោក អៀង សារី ជារៀងរាល់ថ្ងៃនោះ គឺយើងដឹងថាស្ថានភាពនេះច្បាស់លាស់ យើងដឹងហើយថាវេជ្ជបណ្ឌិត ខាំប៊ែល នោះ គាត់មកធ្វើរបាយការណ៍ធ្វើការវាយតម្លៃ យើងមិនឯកភាពទេ ផ្អែកតាមការវាយតម្លៃរបស់គាត់។

[០៩:៤៨:០១]

យើងអាចបង្ហំឲ្យលោក អៀង សារី នៅក្នុងបន្ទប់នេះទៅ ហើយមើលទៅតើស្ថានភាពគាត់យ៉ាងម៉េច? គាត់ ៨៨ឆ្នាំ ពេលខ្លះ ពេលភាគច្រើននោះគឺថា គាត់ឈឺចាប់ ស្ថានភាពរៀងកាយរបស់គាត់ធ្វើឲ្យយើងឃើញហើយថា គាត់ឈឺចាប់ ហើយឲ្យ -- ត្រូវការឲ្យគេនោះធ្វើចលនាផ្លាស់បំបែរខ្លួនរបស់គាត់ គាត់ជួយគាត់ក្រោកឈរ ដូច្នេះហើយវាស្ថិត -- ឲ្យយើងយល់ថាតើគាត់អាចចូលរួមដោយមានន័យគ្រប់គ្រាន់ឲ្យពេញលេញដែរឬទេ? គឺបើយើងសន្និដ្ឋានថា អាចនោះវាចម្លែក និងប្លែកអស្ចារ្យណាស់។

ដូច្នេះនៅក្នុងពេលនេះគឺ ខ្ញុំសូមលើកឡើងថាគាត់មិនអាចមានលទ្ធភាពចូលរួមនោះទេ ក៏ប៉ុន្តែយើងខ្ញុំក៏សូមលើកឡើងផងដែរថា ដោយសារតែគាត់បានបោះបង់សិទ្ធិលើសាក្សីមួយចំនួន ដែលមិនប៉ះពាល់ដល់រឿងក្តីរបស់គាត់នោះ និងដោយសារតែយើងមិនដឹងថា តើស្ថានភាពសុខភាពរបស់គាត់នៅ -- ធូរស្បើយនៅពេលណាមួយនោះ ហេតុអ្វីបានជាយើងបន្តស្តាប់សាក្សីមួយចំនួន ដែលយើងមាននាពេលមុខនេះ -- នាពេលបច្ចុប្បន្ននេះសិន ដើម្បីកុំឲ្យយើងផ្អាកដំណើរការនីតិវិធីរបស់យើង។

[០៩:៤៩:១៦]

ហើយរង់ចាំមើលថាតើស្ថានភាពរបស់គាត់ធូរស្បើយដែរឬទេ ប្រសិនបើវាមិនធូរស្បើយនោះគឺថា យើងខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានបំបែកគាត់ចេញពីសំណុំរឿងនេះ។ ខ្ញុំយល់វាជាសេចក្ដីសម្រេច បើសិនជាធ្វើសេចក្ដីសម្រេចដូច្នេះ គឺវាសំខាន់ណាស់ វាប៉ះពាល់ដើមបណ្ដឹងរដ្ឋប្បវេណី ខាងសហព្រះរាជអាជ្ញា ហើយសាធារណជននឹងមានការយល់ឃើញផ្សេងទៅលើការបំបែកសំណុំរឿងរបស់យើង។ ហើយប្រហែលជាអាចថាខ្ញុំហ្នឹងលើកបញ្ហានយោបាយជាជាងបញ្ហាផ្លូវច្បាប់ក្នុងហេតុផលធ្វើដូច្នេះ។

ដូច្នេះហើយគឺថាជៀសវាងកុំទាន់ប្រឈមទៅនឹងបញ្ហាហ្នឹង យើងនឹងជួបបញ្ហាហ្នឹងនៅពេលក្រោយ។ ខ្ញុំសូមលើកឡើងនៅពេលនេះថា យើងបន្តស្ដាប់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានក្នុងពេលបច្ចុប្បន្ននេះសិន។ ក៏ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះយល់ថា សម្រេចថា គាត់មានសម្បទាគ្រប់គ្រាន់ហ្នឹង គឺនឹងឲ្យគាត់មកក្នុងសវនាការនេះតាមដាននេះ គឺថានៅពេលនោះខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានសុំបំបែកគាត់ចេញពីក្នុងសំណុំរឿងនេះ នៅពេលនេះគឺថាខ្ញុំចង់ឲ្យមានស្នើសុំការចាត់តាំងអ្នកជំនាញឯករាជ្យមួយ ដើម្បីធ្វើការវាយតម្លៃគាត់បន្ថែម។

ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំលើកឡើងចំពោះលោកចៅក្រម ឡាវែន៍ នេះ ច្បាស់លាស់ ហើយអ្វីដែលខ្ញុំលើកឡើង អំពីសុំពិភាក្សារបស់ខ្ញុំនាព្រឹក ពេលព្រឹកនេះ ក៏មានលក្ខណៈមួយជាភាសាកាទូត ឲ្យយើងយល់ទាំងអស់គ្នា។ យើងខ្ញុំមិនមានចេតនាក្នុងការវាយប្រហារសក្ដិកម្មរបស់បុគ្គលណាមួយ និងភាគីផ្សេងនោះទេ។ យើងខ្ញុំហ្នឹង -- យើងខ្ញុំគ្រាន់តែលើកនូវហេតុផលសមរម្យដែលឲ្យយើងដំណើរការទៅមុខបានតែប៉ុណ្ណោះ។

[០៩:៥១:00]

វាចាំបាច់ណាស់ដែលត្រូវអង្គជំនុំជម្រះសាលាដំបូងនោះត្រូវបន្តសវនាការយើងទៅមុខទៀត ក្នុងកាលៈទេសៈបែបនេះ។ យើងខ្ញុំប្រាកដជាដឹងថាខាងក្រុមមេធាវីការពារក្ដីនោះ និងខាងផ្សេងទៀតដែលលើកឡើងថា ហេតុអ្វីបានជាខ្ញុំនឹងមិនលើកជំហរដាច់ណាត់តែម្ដងទៅទៅលើចំណុចហ្នឹង។ ក៏ប៉ុន្តែយើងខ្ញុំលើកនេះគឺថា ធ្វើយ៉ាងណាកុំឲ្យមានការវាប៉ះពាល់ និងរាំងស្ទះដល់ដំណើរការនីតិវិធីរបស់យើងតែប៉ុណ្ណោះ។ សូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ការសូមបំភ្លឺមួយទៀតលោកមេធាវី កាណាវាស សុំអភ័យទោស។ យើងខ្ញុំយល់ថា លោកអះអាងថា កូនក្ដីរបស់លោកមិនអាចចូលរួមនៅក្នុងសវនាការបាន គឺថាគាត់មិនមានសម្បទាគ្រប់គ្រាន់

ក៏ប៉ុន្តែយើងចង់ដឹងថាតើអសម្បទាក្នុងការចូលរួមនៅក្នុងសវនាការនេះ នឹងបង្កឲ្យមានការចោទជាបញ្ហាពាក់ព័ន្ធទៅនឹងសមត្ថភាព -- អសមត្ថភាពរបស់គាត់ក្នុងការយល់អំពីវិសាលភាពនៃសិទ្ធិដែលគាត់បានលះបង់ ដោយសារតែគាត់បានលះបង់សិទ្ធិមួយចំនួនចំពោះការស្ដាប់សក្ខីកម្មសាក្សី?

**លោក ម៉ៃខល កាណាវាស៖**

សំណួរមួយល្អណាស់លោកចៅក្រមឡាវែន៍។ សូមអរគុណ ដែលបានសួរសំណួរល្អនេះ។ ខ្ញុំបានបញ្ជាក់មុនរួចមកហើយ ពេលមុនរួចមកហើយ។ លទ្ធភាពរបស់គាត់ក្នុងការផ្ដង់អារម្មណ៍នោះគឺថាអាចពី៥ទៅ១០នាទី ច្រើនបំផុតនោះគឺ១៥នាទីតែប៉ុណ្ណោះ។ យើងខ្ញុំធ្លាប់បានជួបជាមួយគាត់ ដឹងអំពីបញ្ហាហ្នឹងកាលពីអតីតកាល។ យើងខ្ញុំបានអានឯកសារ និងឲ្យគាត់ពិនិត្យមើលឯកសារ សាក្សីដែលយើងគ្រោងមកឲ្យមកផ្ដល់សក្ខីកម្ម។ យើងខ្ញុំបានអង្គុយរួមជាមួយនឹងលោក អៀង សារី ក្នុងរយៈពេលខ្លីៗ ដើម្បីឲ្យគាត់នេះអាចពិភាក្សាជជែកជាមួយយើងក្នុងរយៈពេល១០ ទៅ១៥ នាទីនោះ ថាតើគាត់អាចផ្ដង់អារម្មណ៍បានដែរឬទេ មុនពេលដែលគាត់ហត់នឿយ?

[០៩:៥៣:០៨]

ក្នុងអំឡុងពេលខ្លីៗបែបនោះ គឺយើងអាចពិភាក្សាខ្លីៗជាមួយនឹងលោកអៀង សារី ពាក់ព័ន្ធនឹងខ្លឹមសារសំខាន់ៗរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន។ យើងមានសេចក្ដីសង្ខេបមួយចំនួនដែលផ្ដល់ដោយភាគី គឺយើងបានមើលទៅកថាខណ្ឌមួយចំនួន ដែលភាគីទាំងអស់នោះចង់យោង។ យើងបានទាក់ទងជាមួយនឹង -- ពិភាក្សាជាមួយលោក អៀង សារី លើបញ្ហាទាំងអស់នេះក្នុងរយៈពេលខ្លីៗ គឺខ្ញុំសូមបញ្ជាក់ថា លោកអៀង សារី មិនមានសម្បទាខាងផ្នែកស្មារតីនៅក្នុងពេលមួយចំនួននោះឲ្យក្នុងការលះបង់សាក្សីមួយចំនួននោះទេ ក្រោយពីយើងពិភាក្សាជាមួយគាត់។ ជាពិសេសបញ្ហារសើបមួយចំនួន។ ហើយគឺខ្ញុំមិនចង់ឲ្យខ្ញុំនេះធ្វើជាជន -- កូនក្ដីរបស់ខ្ញុំខ្លួនឯងនោះទេ។ ខ្ញុំមិនមានចេតនាថា ធ្វើតួនាទីជំនួសគាត់នោះទេ។ ហើយមិនមែនថាការពារដោយឯកតោភាគីនោះទេ គឺយើងត្រូវទទួលការណែនាំពីកូនក្ដីរបស់យើងខ្ញុំ។

[០៩:៥៤:២២]

ផ្អែកតាមការសង្កេតរបស់យើងខ្ញុំនោះ គឺថា យើងខ្ញុំជឿជាក់ថា សាក្សីមួយចំនួននោះគឺគាត់បានបោះបង់សិទ្ធិហើយ មានប្រហែលជា៤០នាក់ គាត់បានបោះបង់សិទ្ធិ គឺគាត់បានផ្ដល់លិខិតបោះបង់សិទ្ធិហើយមិនមែនថាគាត់បោះបង់សិទ្ធិនេះដោយគាត់យល់គ្រប់ចំណុចនោះទេ។ យើងមិនមានបញ្ហាទេ

ការបោះបង់សិទ្ធិទាំងអស់នោះ។ យើងដឹងហើយថា គឺៗគាត់អាចផ្តង់អារម្មណ៍រយៈពេលខ្លីៗតែប៉ុណ្ណោះ នៅពេលដែលការស្តាប់ចម្លើយនោះគឺថាមានការជំទាស់ ការលើកឡើងនានាដែលថាយើងត្រូវការណែនាំពីកូនក្តីរបស់យើង។ ដូច្នេះចំណុចទាំងអស់នេះ យើងត្រូវពិចារណា។

ខ្ញុំកំពុងតែគិតអំពីសំណួរដែលថា លោកចៅក្រមអាចសួរបន្ថែមទៀតទើបខ្ញុំកំពុងតែនិយាយបញ្ជាក់បន្ថែមទៅលើចំណុចនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

[០៩:៥៥:៣៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោក កាណាវ៉ាស។ ខ្ញុំនៅមានសំណួរមួយទៀត។ លោកបានបញ្ជាក់ជូនអង្គជំនុំជម្រះរួចមកហើយថា លោកយល់ឃើញថា លោក អៀង សារី មានសមត្ថភាពខាងស្មារតី គឺបញ្ហាស្មារតីអាចផ្តល់ការលះបង់សិទ្ធិលើសាក្សី និងភាគីមួយចំនួនបាន។ នៅថ្ងៃ០៣ ខែវិច្ឆិកា លោក លីនណាហ្វួត និង ហ្វាស៊ែល និង ខាំប៊ែល គឺបានពិនិត្យស្ថានភាពបញ្ហាស្មារតីរបស់លោក អៀង សារី ហើយបានរកឃើញថាគ្មានអ្វីដែលត្រូវព្រួយបារម្ភទៅលើបញ្ហាបញ្ហាស្មារតីរបស់លោក អៀង សារី នោះទេ។ តើលោកយល់យ៉ាងម៉េច ឯកភាពទៅលើចំណុចនេះដែរឬទេ? គឺចំណុចនេះក៏បាន លោកសាស្ត្រាចារ្យខាំប៊ែល បានលើកឡើងក្នុងពេលសវនាការផងដែរ។ យើងដឹងហើយថា លោក ប៊ូស ចាន នោះមិនមានឯកសារមួយច្បាប់ត្រង់ចំណុចហ្នឹងនោះទេ ខ្ញុំសូមបញ្ជាក់។

[០៩:៥៦:៤១]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណចៅក្រម ខាតវ៉ាយថ៍ ដែលផ្តល់ការអនុញ្ញាតឲ្យខ្ញុំលើកឡើងចំណុចនេះ។ ខ្ញុំៗដឹងហើយថានៅពេលដែលខ្ញុំៗភ្ញាក់ពីព្រលឹមនោះ ឃើញថាការងារមួយចំនួនក៏ខ្ញុំមិនដឹងថានៅពេលខាងមុខនោះ វាមានស្ថានភាពយ៉ាងម៉េចនោះដែរ។ យើងដឹងហើយថា យើងបានពិនិត្យមើលការដេញដោលទាំងអស់នេះ។ ប្រហែលជាលោក លោកស្រីចៅក្រមចាំហើយនាពេលមួយនោះ គឺលោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម បោះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់នៅទៅតាមដានពីក្រោម។ នៅថ្ងៃទី០៧ ខែកញ្ញា យើងបានទៅជួបជាមួយនឹងលោក អៀង សារី នៅក្នុងបន្ទប់ឃុំឃាំងនៅខាងក្រោយ

ឯណោះ គឺយើងបានរៀបចំកាលវិភាគ ការជួបជាមួយគាត់នោះ១ម៉ោង ។ មុនពេលទៅដល់ ទៅទីនោះ គឺថាគាត់មិននិយាយថា គាត់មិនអាចក្រោកពីគ្រែបាន។ យើងៗបានទៅទីនោះ ហើយយើងជួបតែកន្លះម៉ោងតែប៉ុណ្ណោះ។ យើងព្យាយាមៗ ខ្ញុំបញ្ជាក់ យើងព្យាយាមពិភាក្សាជាមួយគាត់ទៅលើសក្ខីកម្មចម្លើយរបស់លោក ហ្វីលីព ស្បូត ដែលលោក ហ្វីលីព ស្បូត នេះបានស្ដាប់សម្ភាសលោក អៀង សារី ក្នុងពេលមួយចំនួន។ ក្រោយពេលដែលខ្ញុំជួបជាមួយ អៀង សារី ប្រហែលជាកន្លះម៉ោងនោះ ខាងមន្ទីរឃុំឃាំងនោះបានប្រាប់ខ្ញុំថា គឺគាត់ត្រូវតែបញ្ជូនទៅមន្ទីរពេទ្យ ហើយបន្ទាប់មកគឺគាត់ទៅចូលពេទ្យនោះ ៣, ៤ ថ្ងៃ។

[០៩:៥៨:២០]

ដូច្នេះអ្វីដែលខ្ញុំបញ្ជាក់នៅទីនេះ គឺថាមុនថ្ងៃ០៣ ខែកញ្ញា មុនថ្ងៃ០៣ ខែកញ្ញា មុនពេលវាយតម្លៃពេលនោះ គឺយើងមិនមានការព្រួយបារម្ភពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់លោក អៀង សារី ក្នុងការជួយជ្រោមជ្រែង និងការចូលរួមរបស់គាត់ក្នុងសវនាការនោះទេ។ គាត់បានចូលរួមក្នុងរយៈកាលមុន នោះ ហើយគឺយើងបានឃើញគាត់នៅពេលព្រឹក ហើយគាត់សម្រាក ធ្វើទៅតាមដានបន្ទប់ខាងក្រោមក្នុងពេលមួយចំនួន។

នៅក្នុងខែ១សីហា គឺថាយើងឃើញលោក ឃើញមានការចូលរួមដោយក្រុមមេធាវីការពារមួយចំនួន ហើយនៅពេលនោះ គឺយើងមិនអាចជំទាស់តទល់ទៅនឹងរបាយការណ៍មួយចំនួននោះ ដោយសារមិនមានការណែនាំ។

ដូច្នេះរបាយការណ៍ទាំងអស់នោះហើយដែលលោក ខាំប៊ែល នោះយកមកធ្វើជាមូលដ្ឋានផងដែរ។ ហើយពេលខ្លះ ដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង ម៉ោងប្រាំបួនយប់ ខ្ញុំចូលគេង ស្អែកព្រលឹមឡើងក៏ខ្ញុំមិនដឹងថាខ្ញុំនឹងមានស្ថានភាពល្អ ឬក៏ខ្ញុំនឹងឈឺ។ ហើយនេះជាអ្វីដែលយើងដឹងហើយថា ស្ថានភាពនេះវាកើតអ៊ីចឹង។

នៅថ្ងៃ០៦ ខែកញ្ញា នោះ គឺគាត់ គឺយើងៗខ្ញុំអាចពិភាក្សាជាមួយគាត់នៅថ្ងៃ០៦ ខែកញ្ញា ហើយបន្ទាប់មកនៅថ្ងៃស្អែកឡើង គឺថាគាត់មិនអាចពិភាក្សាជាមួយយើង គាត់ឈឺ ហើយបន្ទាប់មក គឺគាត់ចូលពេទ្យ។

[០៩:៥៩:៥៣]

ដូច្នេះហើយ គឺយើងសូមបញ្ជាក់ចំណុចហ្នឹង គឺថាយើងមិនអាចដឹងទេស្ថានភាពទាំងអស់ហ្នឹង។

យើងក៏មិនអាចដឹងថា តើគាត់ហ្នឹងនឹងទទួលមរណភាពឬយ៉ាងណានោះដែរ។ យើងកំពុងតែដោះស្រាយទៅលើស្ថានភាពជាក់ស្តែងមួយចំនួន។ ខ្ញុំមិនមែនថា ច្រានចោលនូវរបាយការណ៍ និងការយល់ឃើញរបស់លោកវេជ្ជបណ្ឌិត ខាំប៊ែល, លោក ហ្វាល ស៊ែល និង លោក ហួត លីនណា នៅថ្ងៃទី០៣ ខែកញ្ញានោះទេ។ ក៏ប៉ុន្តែរបាយការណ៍ទាំងអស់នោះ គឺជាមូលដ្ឋានចំណុចចាប់ផ្តើមសម្រាប់យើងនៅក្នុងថ្ងៃនេះមកដល់ថ្ងៃនេះ។ យើងដឹងហើយថា បុគ្គលម្នាក់ គាត់មានអាយុជរា ហើយមានស្ថានភាពសុខភាពនោះក៏ទន់ខ្សោយ ដូចលោក អៀង សារី។ ហើយខ្ញុំមិនដឹងថា ខ្ញុំត្រូវនិយាយបន្ថែមចំណុចណានោះទៀតទេ ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំឆ្លើយនេះ គឺថាបានតបទៅនឹងអ្វីដែលលោកចៅក្រម លោកស្រីចៅក្រមបានសួររួចមកហើយ។ តើលោកស្រីអនុញ្ញាតឲ្យខ្ញុំអង្គុយទេ លោក លោកស្រីចៅក្រម?

[១០:០០:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការធ្វើសន្និដ្ឋានបញ្ចប់នូវកិច្ចពិភាក្សាដេញដោលលើរបាយការណ៍របស់អ្នកជំនាញ លើបញ្ហាសុខភាពរបស់លោក អៀង សារី ដែលបានធ្វើកាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ កន្លងទៅ។

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម។ សូមជម្រាបសួរមេធាវីការពារក្តី។ ខ្ញុំគិតថា ប្រហែលជាពិបាកបន្តិចក្នុងការចាប់ផ្តើម ដោយសារតែមានពិភាក្សាយ៉ាងសំខាន់ដែលបានកើតឡើងក្នុងពេលនេះ។ ហើយនៅពេលនោះ គឺមានការផ្លាស់ប្តូរជំហររបស់មេធាវីការពារក្តីក៏ដូចជាសារណាដែលលើកឡើងដោយមេធាវីការពារក្តី។ ហើយយើងក៏ យើងសុំដាក់សំណើសុំទាក់ទងទៅនឹង ថាតើគាត់សម្បទា ឬក៏អត់? ហើយយើងសូមបញ្ជាក់ថា មេធាវីលោក អៀង សារី បានបញ្ជាក់ថា "លោក អៀង សារី មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការ"។ ដូច្នេះ ហើយការផ្លាស់ប្តូរជំហររបស់ពួកគាត់ បានផ្ទុះបញ្ចាំងអំពីស្ថានភាពដែលផុយស្រួយ ដែលមេធាវីការពារក្តីបាននិយាយយោងទៅរកនោះ។ ដូច្នេះហើយ គឺយើងច្បាស់ណាស់ថា ទាក់ទងទៅនឹងរបាយការណ៍របស់លោកដុកទ័រ ខាំប៊ែល បាននិយាយថា "ស្ថានភាពសុខភាពរបស់លោក អៀង សារី មានលក្ខណៈផុយស្រួយ ប៉ុន្តែគាត់បានបញ្ជាក់ផងដែរ មិនចាំបាច់ឲ្យមានការដាក់លោក អៀង សារី ឲ្យនៅក្នុងមន្ទីរពេទ្យនោះឡើយ"។ ហើយក៏វាបានបញ្ជាក់យ៉ាងច្បាស់ថា ការបញ្ជូនគាត់ត្រឡប់មកមន្ទីរឃុំឃាំងវិញហ្នឹង

តម្រូវឲ្យមានការជួយបន្ថែមទៀតដល់លោក អៀង សារី ហើយក៏មានការនិយាយយោងផងដែរ ពាក់ព័ន្ធទៅនឹងស្ថានភាពនៃការទៅបន្ទប់ទឹក ក៏ដូចជាការទទួលទានអាហារ ឬក៏ការងូតទឹកជាដើម។

[១០:០៣:០២]

ស្ថានភាពទាំងអស់នោះ ដែលលោកវេជ្ជបណ្ឌិត ខាំប៊ែល បានបញ្ជាក់ឡើង គឺបាន -- គឺនឹងអាច ជួយដល់លោក អៀង សារី ហើយវាពាក់ព័ន្ធផងដែរ ទៅនឹងបញ្ហាក្នុងការធ្វើដំណើររបស់លោក អៀង សារី។ ហើយការបញ្ជាក់នេះ វាបញ្ជាក់យ៉ាងច្បាស់ថា នៅចន្លោះថ្ងៃទី០៣ ខែ៩ គឺនៅពេលដែលលោក វេជ្ជបណ្ឌិត ខាំប៊ែល បានជួបគាត់ និងរយៈពេលដែលគាត់ជួបនៅដើមខែវិច្ឆិកានោះ គឺវាមានការ ប្រែប្រួលបន្តិចបន្តួច វាមានការប្រែប្រួលខ្លះ។ ដូច្នេះហើយ លោកវេជ្ជបណ្ឌិ ខាំប៊ែល បានបញ្ជាក់ផងដែរ លោក អៀង សារី តម្រូវឲ្យមានការជួយដល់គាត់ផងដែរ។

យើងទទួលស្គាល់ថា មានការធ្លាក់ចុះផ្នែកសុខភាពរបស់លោក អៀង សារី។ នេះគឺជាអ្វីដែល បានកើតឡើងកន្លងមក។ ប៉ុន្តែយ៉ាងណាក៏ដោយ លោកវេជ្ជបណ្ឌិត ខាំប៊ែល បានបញ្ជាក់ថា ប្រសិនបើ លោក អៀង សារី ត្រូវចាំបាច់នូវកាថែររក្សាបែបសង្គ្រោះបន្ទាន់ គឺ ប្រសិនបើមិនមានតម្រូវការចាំបាច់ ទេ គឺស្នើសុំឲ្យយកគាត់មកមន្ទីរឃុំឃាំងវិញ។

[១០:០៤:១៦]

ប៉ុន្តែលោក ខាំប៊ែល ផ្ទាល់ គាត់និយាយថា ស្ថានភាពរបស់លោក អៀង សារី គឺនឹងនរ គ្មានការ ប្រែប្រួល ហើយក៏បានបញ្ជាក់ថា មនុស្សជាច្រើនដែលអាយុ ដែលមានវ័យដូចគាត់ហ្នឹង គឺអាចនឹងចូល រួមនៅក្នុងសវនាការបាន។ ទាក់ទងទៅនឹងអ្វីដែលលោក កាណាវាស បាននិយាយ គឺថាយើងមានស្ថាន-ភាពមួយ ដែលថាស្ថានភាពរបស់លោក អៀង សារី មានលក្ខណៈស្មុគស្មាញ គាត់មិនអាចទៅបន្ទប់ទឹក មិនអាចទៅទីកន្លែងណាផ្សេងៗ ប្រសិនបើគ្មានការជួយធ្វើលំហាត់ប្រាណរបស់គាត់នោះ។

ដូច្នេះ យើងជួបប្រទះនូវស្ថានភាពមួយ ដែលយើងមានលក្ខណៈស្ថានភាពទន់ខ្សោយ ហើយ ក្នុងពេលជាមួយគ្នានេះ ក៏យើងទទួលបាននូវស្ថានភាពមួយដែលថា ជនជាប់ចោទផ្អែកទៅតាមមតិរបស់ លោកវេជ្ជបណ្ឌិត ខាំប៊ែល គឺបញ្ជាក់ថា គាត់សម្បទាគ្រប់គ្រាន់នៅក្នុងការចូលរួមសវនាការ។ ដូច្នេះ ហើយអ្វីដែលយើងសង្កេតឃើញ គឺថាយើងឃើញថាជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ហើយ សាធារណជនក៏មើលឃើញដូច្នេះនោះដែរ។ ប្រសិនបើយើងផ្អែកទៅលើអ្វីដែលលោកវេជ្ជបណ្ឌិតបាន និយាយ ទោះបីថា ដោយសារតែមានបញ្ហា ៗខ្លះរបស់គាត់ដែលតម្រូវឲ្យគាត់សម្រាកនៅលើគ្រែក៏

ដោយ។ ហើយម្យ៉ាងទៀតលោកវេជ្ជបណ្ឌិត ខាំប៊ែល ក៏បានផ្តល់អនុសាសន៍ទាក់ទងទៅដល់ការកែសម្រួលទៅលើទូរទស្សន៍ដែលដាក់បញ្ចាំងនៅក្នុងបន្ទប់របស់គាត់ផងដែរ ដើម្បីឲ្យគាត់ងាយស្រួល។

[១០:០៦:០៤]

ដូច្នេះហើយផ្អែកទៅតាមការលើកឡើងរបស់លោកវេជ្ជបណ្ឌិត ខាំប៊ែល ពាក់ព័ន្ធទៅនឹងស្ថានភាពរបស់លោក អៀង សារី នៅពេលដែលគាត់ចូលរួមតាមដានសវនាការនៅក្នុងបន្ទប់ឃុំឃាំងនោះ គឺមានការស្នើសុំឲ្យមានការកែប្រែ ឬក៏ការកែសម្រួលថា ឲ្យមានការនាំគាត់មកបន្ទប់សវនាការវិញថា នៅដំណាក់កាលនេះវាមិន -- វាគ្រប់ -- វាជួយដល់ភាពងាយស្រួលរបស់លោក អៀង សារី។ ដូច្នេះហើយយើងមានការលំបាកនៅក្នុងការថ្លឹងថ្លែងទៅលើបញ្ហាទាំងអស់នេះឲ្យវាមានតុល្យភាព ព្រោះថាស្ថានភាពគាត់មានលក្ខណៈនឹងនរ ប៉ុន្តែតម្រូវឲ្យមានការយកចិត្តទុកដាក់យ៉ាងច្រើនទៅលើស្ថានភាពទាំងអស់នេះ។ នៅពេលដែលយើងមើលទៅលើរបាយការណ៍ -- ទៅលើស្ថានភាពថ្ងៃ០៣ ខែ៩ គឺមានលក្ខណៈប្លែកពីនេះ។

[១០:០៧:០៥]

ទោះបីថាមានការការតម្រូវឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក៏ដោយ ក៏ក្នុងពេលបច្ចុប្បន្ននេះអង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីក្នុងលក្ខណៈមួយដែលថា លោក អៀង សារី នៅក្នុងបន្ទប់ឃុំឃាំងខាងក្រោម ហើយនេះគឺជាការធ្វើឡើងផ្អែកទៅតាមការផ្តល់អនុសាសន៍របស់លោកវេជ្ជបណ្ឌិត ខាំប៊ែល។ នេះគឺជាអ្វីដែលយើងបានឃើញ។ ប៉ុន្តែចំពោះសំណួរថា តើយើងនឹងបន្តទៅមុខទៀត ឬក៏អត់នោះ គឺថាភស្តុតាងដែលយើងមាននៅចំពោះមុខអង្គជំនុំជម្រះ បានបញ្ជាក់ថាវាមិនមែនជាបញ្ហានោះទេ។ ពីព្រោះយើងមានភស្តុតាងពីលោកវេជ្ជបណ្ឌិត ខាំប៊ែល ដែលជាសាស្ត្រាចារ្យខាងជំងឺមនុស្សចាស់ គឺយើងមិនមាន -- គឺគាត់មិនមានបញ្ហា -- គឺគាត់គិតថា មនុស្សចាស់ភាគច្រើនមានស្ថានភាពដូចលោក អៀង សារី បែបនេះដែរ។

[១០:០៨:១៣]

ហើយដូច្នេះ ការដែលយើងគោរពទៅតាមអនុសាសន៍របស់គាត់ដែលថា ឲ្យយកលោក អៀង សារី ត្រឡប់មកមន្ទីរឃុំឃាំងវិញ ហាក់ដូចជាមិនមានបង្កជាហានិភ័យអ្វីខ្លាំងក្លានោះឡើយ។ ហើយការដោះស្រាយ -- ហើយផ្អែកទៅតាមបទពិសោធន៍របស់គាត់ ដែលគាត់ជួបជាមួយមនុស្សចាស់ជាច្រើនគឺថាវានឹងអាចជឿទុកចិត្តបាន ហើយយើងអាចជឿជាក់បានទៅលើអ្វីដែលគាត់បានលើកឡើង។ ទោះបី

យ៉ាងណាក៏ដោយមេធាវីការពារក្តីអាចនឹងមានពេលវេលា -- ទោះបីថាលោក អៀង សារី អាចប្រាស្រ័យទាក់ទងត្រឹមតែ ១៥នាទីក៏ដោយ។ នេះគឺជាអ្វីដែលមេធាវីការពារក្តីបានលើកឡើង។

ក្នុងពេលដែលយើងមើលទៅលើការវាយតម្លៃដែលបានធ្វើឡើងដោយលោកវេជ្ជបណ្ឌិត ខាំប៊ែល ក្នុងរយៈពេល ២ថ្ងៃ កាលពីសប្តាហ៍មុននោះ។ នៅពេលដែលយើងចោទសួរថា តើលទ្ធភាពរបស់លោក អៀង សារី ក្នុងការផ្តល់អារម្មណ៍យ៉ាងម៉េចដែរ? គាត់និយាយថា នៅពេលដែលជជែកជាមួយគាត់រយៈពេលកន្លះម៉ោង គឺគាត់អាចប្រាស្រ័យទាក់ទងបាន ហើយអាចជជែកគ្នាបាន។ ហើយនៅពេលដែលលោកវេជ្ជបណ្ឌិតទៅជួបនៅពេលរសៀលនៅថ្ងៃដដែលហ្នឹងគឺ លោក អៀង សារី អាចទាក់ទងជាមួយគាត់បានដដែល។

[១០:០៩:៣២]

ហើយនៅថ្ងៃបន្ទាប់មកទៀត គឺនៅតែអាចប្រាស្រ័យទាក់ទងជាមួយគាត់បានដដែល។ ហើយគាត់ធ្វើការវាយតម្លៃផ្នែកចិត្តសាស្ត្រ គឺ អឹម.អឹម.អេស.អ៊ី ជាច្រើននៅតែអាចបញ្ជាក់ថា គាត់អាចផ្តល់អារម្មណ៍បាន ហើយគាត់ -- ហើយលោក អៀង សារី ទទួលបានពិន្ទុខ្ពស់នៅក្នុងការធ្វើតេស្ត អឹម.អឹម.អេស.អ៊ី។ ហើយដូច្នេះហើយទើបលោកវេជ្ជបណ្ឌិតសន្និដ្ឋានថា គាត់អាចចូលរួមនៅក្នុងសវនាការគឺដូចជាអ្វីដែលគាត់បានបញ្ជាក់នៅក្នុងរបាយការណ៍ចុះថ្ងៃទី០៣ ខែ៩ ដូច្នេះដែរ។

ដូច្នេះហើយយើងមានភស្តុតាងបញ្ជាក់ច្បាស់ថា នៅក្នុងរបាយការណ៍ពីដើមខែ៩ រហូតមកដល់ដើមខែ១១ហ្នឹង គឺទោះបីថា ស្ថានភាពរបស់គាត់មានការធ្លាក់ចុះបន្តិចមែនក៏ដោយ ប៉ុន្តែនៅពេលដែលយើងស្តាប់របាយការណ៍នៅដើមខែវិច្ឆិកា គឺសក្ខីកម្មនៅដើមខែវិច្ឆិកា នៅពេលដែលយើងនិយាយអំពីការវាយតម្លៃទាក់ទងទៅនឹងការផ្តល់អារម្មណ៍រយៈពេល១៥នាទីនោះ ការធ្វើការសម្ភាសផ្សេងៗទាក់ទងទៅនឹងស្ថានភាពរបស់គាត់ គឺធ្វើឡើងក្នុងរយៈពេល១៥នាទី ដូចដែលលោកវេជ្ជបណ្ឌិត ខាំប៊ែល បាននិយាយថា ជារយៈពេលសមស្របដើម្បីស្វែងរកព័ត៌មានពីអ្នកជំងឺត្រឹមតែរយៈពេល១៥នាទីនោះដែរ។ ដូច្នេះ ខ្ញុំស្នើសុំឲ្យមានការណែនាំពីអង្គជំនុំជម្រះ ប៉ុន្តែយើងចង់និយាយផងដែរថា លោកចៅក្រមត្រូវតែសម្រេចទៅលើបញ្ហាថាតើលោក អៀង សារី មានសម្បទាគ្រប់គ្រាន់ឬក៏អត់? នេះគឺជាអ្វីដែលអង្គជំនុំជម្រះត្រូវសម្រេច។ ហើយប្រសិនបើនៅពេលក្រោយមកទៀត លោក អៀង សារី មានការធ្លាក់ចុះផ្នែកស្ថានភាពកាយ ឬក៏សិតបញ្ញានោះ គឺនៅពេលនុំងហើយ ដែលអង្គជំនុំជម្រះ -- ដែលព្រះរាជអាជ្ញាមិនមានការជំទាស់នោះឡើយ ប្រសិនបើមានការសំណើដែលទាក់ទងទៅនឹងសម្បទារបស់

លោក អៀង សារី ប្រសិនបើគេរកឃើញថា លោក អៀង សារី មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការ។

[១០:១១:៤១]

ចំពោះយើងក្នុងពេលឥឡូវនេះ គឺថា អង្គជំនុំជម្រះ គឺមានឆន្ទានុសិទ្ធិក្នុងការសម្រេចដោយសារតែមេធាវីការពារក្តីថា លោក អៀង សារី មិនមានសម្បទាគ្រប់គ្រាន់ ប៉ុន្តែលោកវេជ្ជបណ្ឌិត ខាំប៊ែល បានបញ្ជាក់ច្បាស់នៅក្នុងរបាយការណ៍អ្នកជំនាញក៏ដូចជាសក្ខីកម្មរបស់គាត់ថា "លោក អៀង សារី មានសម្បទាគ្រប់គ្រាន់"។ ហើយលោកវេជ្ជបណ្ឌិត ហ្វាស៊ែល ហើយនិងលោកវេជ្ជបណ្ឌិត ហួត លីនណា កាលពីប៉ុន្មាន -- ២ខែមុនក៏ផ្តល់នូវគំនិតដូចគ្នា ផ្តល់នូវទស្សនៈដូចគ្នា។ ហើយ២, ៣សប្តាហ៍មុនគឺលោកវេជ្ជបណ្ឌិត ខាំប៊ែល ដដែលបានបញ្ជាក់ថា ស្ថានភាពរបស់លោក អៀង សារី មិនមានការផ្លាស់ប្តូរនោះឡើយ។ ដូច្នេះអ្វីដែលមានការប្រែប្រួល គឺតែទៅលើស្ថានភាពផ្លូវកាយ រូបរាងកាយរបស់គាត់ គ្រាន់តែទាមទារឲ្យមានការយកចិត្តទុកបន្ថែមទៅលើស្ថានភាពផ្លូវកាយរបស់គាត់។

ប៉ុន្តែបញ្ហាសំខាន់គឺមិនមែនទៅលើថា តើគាត់មានការផ្តង់អារម្មណ៍៥, ១០នាទី ឬក៏១៥នាទីនោះដែរ។ បញ្ហាសំខាន់គឺត្រូវឲ្យមានការយកចិត្តទុកដាក់បន្ថែម ដែលជាការទទួលខុសត្រូវរបស់ អ.វ.ត.ក។

[១០:១២:៥៥]

ខ្ញុំសូមលើកឡើងថា បញ្ហាចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ គឺថាគាត់អាចមានសម្បទាគ្រប់គ្រាន់នៅក្នុងការចូលរួម គឺគាត់មានសតិបញ្ញាគ្រប់គ្រាន់ក្នុងការតាមដាន មានសម្បទាគ្រប់គ្រាន់នៅក្នុងការណែនាំទៅដល់មេធាវីការពារក្តី ក៏ដូចជាយកចិត្តទុកដាក់ស្តាប់ទៅលើការផ្តល់សក្ខីកម្ម។ ហើយកាលពីប៉ុន្មានខែមុន គឺយើងមានអ្នកជំនាញដែលគាត់និយាយដូចគ្នាបែបនេះដែរ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ម្តងទៀតថា វាជាគ្រោះថ្នាក់មួយ ប្រសិនបើយើងមិនធ្វើការសម្រេចចំពោះបញ្ហានៅក្នុងពេលនេះ ប្រសិនបើដល់ពេលក្រោយ នៅពេលដែលបញ្ហាវាធ្លាក់ដល់ស្ថានភាពមួយដែលថា វាមានការប្រែប្រួលផ្សេងពីនេះ។ ដូច្នេះហើយ ខ្ញុំគិតថា ប្រសិនបើមានការប្តឹងសាទុក្ខ ឬក៏ប្តឹងឧទ្ធរណ៍ គឺថាអង្គជំនុំជម្រះ តុលាការកំពូលប្រហែលជាត្រូវការចង់ដឹង អំពីទស្សនៈរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ។

[១០:១៣:៥៤]

យើងសូមថ្លែងអំណរគុណផងដែរ ក៏ដូចជាការកោតសរសើរចំពោះមេធាវីការពារក្តី ដែលបាន

ផ្តល់នូវវិធីសាស្ត្រមួយដែលថា ជួយសម្រួលដល់អង្គជំនុំជម្រះដែលថា ឲ្យមានការលះបង់សិទ្ធិចូលរួមរបស់លោក អៀង សារី ដើម្បីឲ្យអង្គជំនុំជម្រះអាចបន្តកិច្ចដំណើរការនីតិវិធីតទៅមុខទៀតបាន។ យើងសូមថ្លែងអំណរគុណ។ ដូច្នេះ ខ្ញុំសូមសំណើសុំជាថ្មីម្តងទៀតថា ឲ្យអង្គជំនុំជម្រះធ្វើការសម្រេចទៅលើបញ្ហានេះក្នុងពេលឥឡូវនេះ ដើម្បីឲ្យយើងអាចដោះស្រាយបញ្ហាបាន ទោះបីថាត្រូវការឲ្យមានការស្តាប់ទៅលើវេជ្ជបណ្ឌិត ប៊ួស ចាន ឬមួយក៏ទៅលើអ្នកណាដទៃទៀត នៅពេលក្រោយយើងគួរតែមានការពិនិត្យទៅលើគុណភាព ក៏ដូចជាអ្វី គុណសម្បត្តិនានាទៅលើអ្នកជំនាញ ដែលស្នើឡើងដោយមេធាវីការពារក្តី ដោយព្រះរាជអាជ្ញា ឬក៏ដោយដើមបណ្តឹងរដ្ឋប្បវេណីក្តី យើងត្រូវតែសម្រេចនៅពេលនោះ។

ប៉ុន្តែនេះគឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការសម្រេចនៅពេលក្រោយនោះទេ ថាតើអ្នកណាគួរតែជាអ្នកជំនាញដើម្បីមកផ្តល់សក្ខីកម្ម នេះគឺជាបញ្ហានៅពេលក្រោយ។ ប៉ុន្តែក្នុងពេលឥឡូវនេះ យើងចង់ឲ្យអង្គជំនុំជម្រះធ្វើការពិនិត្យ ពិចារណា ហើយសម្រេចថាតើទស្សនៈរបស់លោកវេជ្ជបណ្ឌិតបីរូប គឺលោកវេជ្ជបណ្ឌិតដែលមានសមត្ថភាពបីរូបដែលមាន ដុកទ័រ ខាំប៊ែល, ដុកទ័រហ្វាស៊ែល ហើយលោកដុកទ័រ ហួត លីនណា ដែលបានផ្តល់សក្ខីកម្មតាំងពី ២ខែមុនរហូតមកដល់ពេលបច្ចុប្បន្ននេះ ដែលពួកគាត់ទាំងបីបាននិយាយថាលោក អៀង សារី មានបញ្ហាតែទៅលើផ្នែករូបរាងកាយ។ ហើយលោកវេជ្ជបណ្ឌិតខាំប៊ែល ក៏បានបញ្ជាក់ច្បាស់លាស់ថា គាត់គ្រាន់តែទាមទារឲ្យមានការផ្តល់សេវាផ្នែកសុខាភិបាល ក៏ដូចជាមានការយកចិត្តទុកដាក់បន្ថែមទៅលើលោក អៀង សារី។

[១០:១៦:០១]

ដូច្នេះផ្អែកទៅតាមរបាយការណ៍ក្នុងរយៈពេល ២ខែ ប្រសិនបើមានករណីតែមួយដែលមានវេជ្ជបណ្ឌិតណាមួយថា លោក អៀង សារី មិនមានសម្បទាគ្រប់គ្រាន់ អាហ្នឹងជាបញ្ហាមួយផ្សេង។ ប៉ុន្តែលោកវេជ្ជបណ្ឌិតទាំងបីរូបនោះបានបញ្ជាក់ច្បាស់ថា គាត់អាចផ្តង់អារម្មណ៍បានក្នុងរយៈពេល ១៥នាទី។ ដូច្នេះអង្គជំនុំជម្រះមានភស្តុតាងគ្រប់គ្រាន់នៅចំពោះមុខដែលថា ស្ថានភាពរបស់លោក អៀង សារី ផ្លាស់ប្តូរពីថ្ងៃទី០៣ ខែកញ្ញា រហូតមកដល់ថ្ងៃទី០៤ ថ្ងៃទី០៥ ខែវិច្ឆិកា នោះគឺមានតែការប្រែប្រួលតែផ្នែករូបរាងកាយប៉ុណ្ណោះ។ ដូច្នេះខ្ញុំគិតថា ចំពោះស្ថានភាពផ្នែកផ្លូវចិត្ត ផ្នែកសតិបញ្ញារបស់លោក អៀង សារី មិនមានការផ្លាស់ប្តូរឡើយក្នុងរយៈពេល ២, ៣ខែកន្លងមកនេះ។

លោក លោកស្រីចៅក្រម ខ្ញុំព្យាយាមលើកឡើងដោយសង្ខេប ប៉ុន្តែខ្ញុំចង់ឲ្យ អង្គជំនុំជម្រះពិនិត្យទៅលើយុត្តិសាស្ត្ររបស់តុលាការអាយ -- តុលាការប្រទេសយូហ្គោស្លាវី គឺ អាយ.ស៊ី.ធី.វ៉ាយ គឺសេចក្តី

សម្រេចបាននិយាយថា -- គឺសេចក្ដីសម្រេចទាក់ទងទៅនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធី ដែលបានលើកឡើងថា “ក្រៅពីលក្ខណៈវិនិច្ឆ័យ ឬក៏ការវិនិច្ឆ័យទៅលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ គឺផ្អែកទៅលើតេស្តស្រ្ទហ្កា គឺថាយើងមានលក្ខណៈស្រ្ទហ្កា គឺមានលក្ខណៈវិនិច្ឆ័យចំនួនប្រាំពីរ គឺផ្អែកទៅលើការវាយតម្លៃនៅថ្ងៃទី០៣ ខែកញ្ញា គឺលោក អៀង សារី មានលទ្ធភាពគ្រប់គ្រាន់ គឺមានលទ្ធភាពគ្រប់គ្រាន់ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី ហើយគាត់មានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការចូលរួមសវនាការ។

[១០:១៨:១៦]

ដូច្នេះហើយ យើងគិតថាផ្អែកទៅលើរបាយការណ៍ថ្ងៃទី០៣ ខែកញ្ញា គឺគាត់មានសម្បទាគ្រប់គ្រាន់ក្នុងការតទល់ក្ដី។ ផ្អែកទៅតាមលោកសាស្រ្តាចារ្យ ខាំប៊ែល កាលពីជួបរយៈពេល ២ខែមុន គឺថាលោក អៀង សារី មិនមានការផ្លាស់ប្ដូរអ្វីឡើយបន្ទាប់ពីពិភាក្សាជាមួយគាត់។ គោលការណ៍មួយទៀតដែលខ្ញុំមិនធ្វើការដកស្រង់នោះទេ ដោយសារតែយើងមានពេលវេលាតិចតួច គឺទាក់ទងទៅនឹងសំណុំរឿងស្រ្ទហ្កា គឺការធ្វើតេស្តស្រ្ទហ្កាផងដែរ គឺការពិនិត្យទៅលើរបាយការណ៍ ឬក៏ទៅលើរបាយការណ៍សុខភាពរបស់ជនជាប់នោះ គឺជា -- មិនមែនជាតួនាទីសំខាន់របស់អង្គជំនុំជម្រះនោះឡើយ។

តួនាទីសំខាន់របស់អង្គជំនុំជម្រះ គឺត្រូវធ្វើការវិនិច្ឆ័យថាតើជនជាប់ចោទមានសម្បទាក្នុងការតទល់ក្ដី ឬក៏អត់? នេះគឺជាអ្វីដែលយើងចង់បញ្ជាក់។ ទោះបីថាគាត់មានការវិលមុខ មានការស្ពឹកស្រពន់ ឬក៏មានបញ្ហាដូចថាបញ្ហាទាំងនេះកើតឡើងដោយស្ថានភាពនេះ ឬក៏ស្ថានភាពនោះក៏ដោយគឺវាមិនមែនជាបញ្ហាពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូងនោះឡើយ។ អ្វីដែលអង្គជំនុំជម្រះត្រូវការគឺថា តើគាត់អាចចូលរួមក្នុងសវនាការប្រកបដោយប្រសិទ្ធភាព ហើយអាចការពារខ្លួនគាត់បានដែរឬអត់នោះទេ? ទើបជាបញ្ហាសំខាន់។ ដូច្នេះហើយ គឺយើងគ្រាន់តែពិចារណាថាតើលោក អៀង សារី អាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពឬក៏អត់។ ប្រសិនបើអង្គជំនុំជម្រះយល់ថា វាជាការពិតគឺជឿជាក់ថារបាយការណ៍របស់អង្គ -- របស់អ្នកជំនាញ ដែលថាគាត់អាចចូលរួមដោយមានប្រសិទ្ធ-ភាពបាន ដូច្នេះបញ្ហាសំខាន់ថាតើ -- បញ្ហាដែលថាតើគាត់មានបញ្ហានេះដោយសារជំងឺអ្វី ឬក៏ដោយសារមូលហេតុអ្វី គឺហាក់ដូចជាមិនពាក់ព័ន្ធនោះឡើយសម្រាប់អង្គជំនុំជម្រះសាលាដំបូង។

ប៉ុន្តែតាមអ្វីដែលយើងយកចិត្តទុកដាក់បំផុត គឺថាយើងត្រូវផ្ដល់នូវការថែរក្សាផ្នែកសុខភាព ក៏ដូចជាការយកចិត្តទុកដាក់ចំពោះគាត់នៅ អ.វ.ត.ក។ ខ្ញុំនិយាយយោងទៅលើកថាខណ្ឌ៣៥ និង ៤៦ នៃ

គោលការណ៍នោះ។

[១០:២០:៥៣]

គោលការណ៍ទី២ ដែលខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាផងដែរ គឺថាអង្គជំនុំជម្រះគួរតែពិចារណាទៅលើភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ គឺលិខិតរបស់ដុកទ័រ ប្រោសស្កិន ធ្វើឡើងរយៈពេលត្រឹមតែ២៤ម៉ោង ដោយមិនមានការជួបពិភាក្សាជាមួយជនជាប់ចោទ មិនមានផ្អែកទៅលើរបាយការណ៍វេជ្ជសាស្ត្រ ឬក៏ពិនិត្យទៅលើរបាយការណ៍សុខភាពពីមុន។ ដូច្នេះហើយ យើងត្រូវធ្វើការធៀបផងដែរ ជាមួយនឹងរបាយការណ៍ផ្សេងៗដែលបានដាក់។

ដូច្នេះ ខ្ញុំចង់បញ្ជាក់ថា របាយការណ៍របស់លោកវេជ្ជបណ្ឌិត ខាំប៊ែល គួរតែមានតម្លៃជាង។ ចំពោះការលើកឡើងរបស់មេធាវីការពារក្ដី ដែលនិយាយថា ស្ថានភាពរបស់លោកអៀង សារី នៅពេលដែលពួកគាត់ជួបជាមួយលោកអៀង សារី នោះ មិនមែនជាភស្តុតាងដែលត្រូវលើកយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះឡើយ។

អង្គជំនុំជម្រះត្រូវតែធ្វើការសម្រេចដោយផ្អែកទៅលើភស្តុតាងជាជាងពឹងផ្អែកទៅលើសំណើ ឬក៏សារណារបស់ភាគីណាមួយ។ ម្យ៉ាងវិញទៀត ឯការលើកឡើងរបស់វេជ្ជបណ្ឌិតប៊ូសចាន់ មិនមានការជជែកពិភាក្សាដេញដោលនោះឡើយ។ ប្រសិនបើអង្គជំនុំជម្រះជឿទុកចិត្ត ហើយពឹងផ្អែក ហើយគិតថាអង្គជំនុំជម្រះទាមទារនូវរបាយការណ៍បន្ថែមទៀតនោះ -- ប្រសិនបើអង្គជំនុំជម្រះមិនទុកចិត្តទៅលើសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិតខាំប៊ែល ឬក៏មិនទុកចិត្តទៅលើរបាយការណ៍របស់លោកវេជ្ជបណ្ឌិតហ្វាស៊ែល ឬក៏លោកវេជ្ជបណ្ឌិត ហួត លីនណា នៅពេលនោះ ខាងព្រះរាជអាជ្ញា ប្រាកដជាស្នើសុំដល់អង្គជំនុំជម្រះថា អាចនឹងធ្វើការពិភាក្សា ហើយនិងសម្រេចដោយទទួលយកមតិបន្ថែមរបស់អ្នកជំនាញថ្មី។

[១០:២៣:០៥]

ប៉ុន្តែកន្លងមកគឺយើងមានរបាយការណ៍ ដែលជាក់លាក់លម្អិតច្បាស់លាស់ពីអ្នកជំនាញផ្សេងៗដែលបានបញ្ជាក់រួចមកហើយ ថាជនជាប់ចោទគាត់មានសម្បទាគ្រប់គ្រាន់។ មេធាវីការពារក្ដីបានបញ្ជាក់ថា ស្ថានភាពរបស់ជនជាប់ចោទវាមានលក្ខណៈនឹងនរ ប៉ុន្តែវាគ្រាន់តែជាការមិននឹងនរប៉ុណ្ណោះ ប៉ុន្តែលោកវេជ្ជបណ្ឌិតខាំប៊ែល បានបញ្ជាក់ច្បាស់រួចទៅហើយ ថាគាត់នឹងនរ។

ដូច្នេះហើយ ប្រសិនបើវាជាការចាំបាច់ គឺយើងអាចពឹងផ្អែកទៅលើរបាយការណ៍របស់លោក

ខាំប៉ែល លោកហ្វាស៊ែល ឬក៏លោក ហួត លីនណា ដើម្បីមកទទួលបន្ថែម។ ប៉ុន្តែយើងត្រូវចាំថា នេះមិនមែនជាប្រព័ន្ធស៊ីវិលឡូ -- ប្រព័ន្ធខំមិនឡូទេ នេះជាប្រព័ន្ធស៊ីវិលឡូ។ ដូច្នេះវាទាមទារឱ្យមានការពិចារណាទៅលើភស្តុតាងដែលមានស្រាប់។

[១០:២៤:០៧]

សំណើរបស់ពួកយើងគឺថា ក្នុងពេលឥឡូវនេះ ប្រសិនបើយើងធ្វើការកោះហៅអ្នកជំនាញបន្ថែមទៀត វាជាការមិនចាំបាច់ ព្រោះថាយើងទទួលបានរបាយការណ៍អ្នកជំនាញចំនួនបីរូបរួចទៅហើយ ហើយក៏មិនមានការផ្លាស់ប្តូរអ្វីសំខាន់នោះឡើយ។ ប្រសិនបើយើងកោះហៅអ្នកជំនាញម្នាក់បន្ថែមទៀត ហើយភាគីណាមួយមិនពេញចិត្ត ពេលហ្នឹងយើងត្រូវកោះហៅអ្នកជំនាញបន្ថែមទៀត តទៅមុខជារៀងរហូត។

នៅក្នុងកថាខណ្ឌ២៥ ទំព័រទី៧ នៃសេចក្តីសម្រេចរបស់ស្រ្តូហ្កា គឺបានបញ្ជាក់ថា ទាមទារឱ្យមានសំអាងហេតុគ្រប់គ្រាន់ ដែលៗថា ទាមទារឱ្យមានសំអាងហេតុគ្រប់គ្រាន់ ដើម្បីឱ្យមានការធ្វើការសម្រេចផ្សេង។ ប៉ុន្តែយើងចាំថា លោក អៀង សារី ត្រូវបានធ្វើការវាយតម្លៃសុខភាព ដោយសារអ្នកជំនាញជាច្រើនរូបរួចមកហើយ។ ដូច្នេះហើយយើងមិនគួរចំណាយពេលវេលា ក៏ដូចជាធនធានឱ្យអត់ប្រយោជន៍នោះទេ។

ជាចុងក្រោយ ពាក់ព័ន្ធទៅនឹងបញ្ហាសម្បទាក្នុងការតទល់ក្តីប្រសិនបើយើងមើលទៅលើតុលាការអាយ.ស៊ី.ធី.វ៉ាយ គឺយើងឃើញថាសម្បទាក្នុងការតទល់ក្តីបានលើកឡើងពីបញ្ហានេះផងដែរ។

ចំពោះការសម្រេចអំពីសម្បទាគឺនៅតុលាការអន្តរជាតិនានា គឺយើងត្រូវធ្វើការថ្លឹងថ្លែងរវាងលទ្ធភាព រវាងតុល្យភាពរវាងការដែលអាចចូលរួមបាន និងមិនអាចចូលរួមបាន។

[១០:២៥:៤៩]

ដូច្នេះ តំណាងព្រះរាជអាជ្ញាសូមស្នើថា យើងបានស្តាប់នូវសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិតខាំប៉ែល ហើយយើងបានពិនិត្យមើលទៅឯកសារគ្រប់គ្រាន់។ ដូច្នេះវាមិនមានកន្លែងណាមួយបញ្ជាក់ថា លោក អៀង សារី មិនមានសម្បទាគ្រប់គ្រាន់នោះឡើយ។

លោក លោកស្រីចៅក្រម ជាទីបញ្ចប់ ជាដំបូងគឺយើងស្នើថាអង្គជំនុំជម្រះមិនគួរពន្យារពេលក្នុងការចេញសេចក្តីសម្រេចនោះឡើយ ដើម្បីជាប្រយោជន៍ដល់ពេលអនាគត។ ដូច្នេះយើងស្នើសុំឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយយើងក៏សូមស្នើសុំផងដែរឱ្យ

បន្តកិច្ចដំណើរការនីតិវិធីជាធម្មតាតទៅមុខទៀត ទោះបីថាលោក អៀង សារី មានវត្តមាននៅក្នុងសវនាការ ឬក៏នៅទីណាក៏ដោយ អាចថាគាត់មិនមានលទ្ធភាពគ្រប់គ្រាន់ចូលរួមនៅក្នុងសវនាការ អាចឲ្យគាត់ទៅតាមដាននៅបន្ទប់ឃុំឃាំងខាងក្រោម។ អាចថាឲ្យគាត់នៅកន្លែងណាមួយក៏បានដែរក្នុងពេលអនាគត អាចថាគាត់បន្តទៅព្យាបាលនៅមន្ទីរពេទ្យ ឲ្យតែគាត់មានលទ្ធភាពតាមដានកិច្ចដំណើរការនីតិវិធីបាន គឺយើងអាចរៀបចំឧបករណ៍នៅមន្ទីរពេទ្យក៏បានដែរ។

ដូច្នេះខ្ញុំស្នើសុំថា ឲ្យមានការបន្តកិច្ចដំណើរការនីតិវិធីតទៅមុខទៀតជាធម្មតា។ ក្នុងករណីដែលអង្គជំនុំជម្រះមិនមានការ មិនច្បាស់លាស់ ឬមិនទុកចិត្តទៅលើរបាយការណ៍របស់លោកវេជ្ជបណ្ឌិត ខាំប៊ែល ឬក៏លោកវេជ្ជបណ្ឌិត ហួត លីនណា ឬក៏ ហ្វាស៊ែល ប្រសិនបើមិនមានការមិនទុកចិត្តទៅលើបញ្ហាទាំងអស់នោះទេ គឺយើងមិនចាំបាច់ត្រូវការមានអ្វីពិភាក្សាបន្ថែមទៀតឡើយ។

[១០:២៧:៤៧]

ដូច្នេះខ្ញុំគិតថា ការផ្ដល់ប្រឹក្សាបន្ថែម ការកោះហៅអ្នកជំនាញបន្ថែមគឺមិនចាំបាច់ឡើយក្នុងពេលឥឡូវនេះ។ ហើយដើម្បីបញ្ជាក់ឲ្យបានច្បាស់ ការផ្ដល់សេវាសុខភាពបន្ថែមតទៅលោក អៀង សារី គឺជាការចាំបាច់បំផុតនៅក្នុងពេលឥឡូវនេះ។ ដូច្នេះបញ្ហាដែលថា គាត់ត្រូវការការថែរក្សាផ្នែកសុខភាពបន្ថែមមិនបានធ្វើឲ្យមានការប្រែលប្រួលទៅដល់ការវាយតម្លៃរបស់លោកវេជ្ជបណ្ឌិត ខាំប៊ែល, ហ្វាស៊ែល និងលោកវេជ្ជបណ្ឌិត ហួត លីនណា ដែលថាគាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនោះឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្ដីសន្និដ្ឋាន។ សូមអញ្ជើញ!

[១០:២៨:៤៨]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន! ជម្រាបសួរលោក លោកស្រីចៅក្រម! ជម្រាបសួរភាគីទាំងអស់! ខ្ញុំគិតថា អ្វីដែលមេធាវីការពារក្ដីបានលើកឡើងអម្បាញ់មិញនេះ ហើយនិងអ្វីដែលអង្គជំនុំជម្រះបានគិតទុកជាមុនរវាងពួកយើង ហើយនិងខាងសហព្រះរាជអាជ្ញានោះ គឺថាមេធាវីការពារក្ដីបានបញ្ជាក់ថាពួកគេមានជំហរច្បាស់លាស់ ហើយយើងបានរង់ចាំអស់រយៈពេលជាច្រើនសប្ដាហ៍មកហើយពាក់ព័ន្ធ

ទៅនឹងការលះបង់សិទ្ធិក្នុងការចូលរួម ហើយច្បាស់ណាស់ថា ពួកគេលើកឡើងថា អៀង សារី មិនមានសម្បទា ហើយពួកគាត់សូមឲ្យមានការបំបែកប្រសិនបើចាំបាច់នោះ។ ដូច្នេះ ច្បាស់ណាស់គឺវាមានផលប៉ះពាល់ដ៏សំខាន់មកលើពួក -- មិនត្រឹមតែសម្រាប់លោក អៀង សារី ទេ គឺសម្រាប់វាទាំងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងការ កិច្ចដំណើរការនីតិវិធី ហើយអង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេច ហើយការសម្រេចនោះ ក៏នឹងមានផលប៉ះពាល់ទៅលើគោលជំហររបស់ជនជាប់ចោទផ្សេងទៀតផងដែរ គឺ -- ហើយយើងក៏ត្រូវតែគិតពិចារណាទៅលើផលប៉ះពាល់ទាំងអស់នេះ។

[១០:២៩:៥៤]

យើងខ្ញុំយល់ស្របថា អៀង សារី គាត់បានសម្រាកពេទ្យ ដោយសារតែបញ្ហាសុខភាព។ យើងយល់ព្រមទៅលើការកែប្រែ ទៅលើរបៀបវារៈនៃសវនាការ នេះគឺជារឿងធម្មតាទេ។ យើងបានស្ដាប់នូវសេចក្ដីសន្និដ្ឋានរបស់លោកដុកទ័រ ខាំប៊ែល នេះមិនមែនជាសេចក្ដីសន្និដ្ឋានលើកដំបូងទេ គាត់បានពិនិត្យលោក អៀង សារី ជាច្រើនដងហើយ ហើយក៏គាត់ធ្វើការសន្និដ្ឋានច្រើនដងហើយ។ ការសន្និដ្ឋាននេះគឺថាច្បាស់លាស់ណាស់ មិនមានភាពស្រពេចស្រពិលនោះទេ គឺយើងបានជជែកពិភាក្សាច្បាស់លាស់ ហើយនៅក្នុងសវនាការកាលពីសប្ដាហ៍មុននេះ។ គាត់បានបញ្ជាក់ច្បាស់នោះថា គឺមិនមានភាពចាំបាច់ក្នុងការរក្សាលោក អៀង សារី នៅមន្ទីរពេទ្យនោះទេ។

[១០:៣០:៣៨]

លោកសាស្ត្រាចារ្យ ខាំប៊ែល ក៏គាត់បញ្ជាក់ថា លើសម្បទាមិនមាន -- មិនមែន -- គឺមានសម្បទាគ្រប់គ្រាន់ទាំងផ្នែករាងកាយ ផ្នែកស្មារតី នាពេលបច្ចុប្បន្ននេះ។ ដូច្នេះ មិនមានបញ្ហាអ្វីពាក់ព័ន្ធទៅនឹងសម្បទារបស់គាត់នោះទេ។ ក៏ប៉ុន្តែខាងមេធាវីការពារក្ដី អៀង សារី បានជំទាស់ទៅនឹងរបាយការណ៍របស់លោក ខាំប៊ែល ហើយនិងជំទាស់ទៅលើវិធីសាស្ត្ររបស់លោក ខាំប៊ែល។

ខ្ញុំសូមរំឭកថា កាលពីប៉ុន្មានសប្ដាហ៍មុននេះ លោក ខាំប៊ែល បានចេញរបាយការណ៍ពាក់ព័ន្ធទៅនឹងសុខភាពរបស់លោកស្រី អៀង ធីរិទ្ធ ហើយទាំងមេធាវីការពារក្ដីរបស់លោកស្រី អៀង ធីរិទ្ធ ដែលជាភរិយារបស់លោក អៀង សារី នេះ គឺថាបានយល់ស្របថាជាឯកសារអាចយកជាការបាន មានសំអាងហេតុត្រឹមត្រូវ ដើម្បីឲ្យអង្គជំនុំជម្រះចេញសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងអសម្បទារបស់លោកស្រី អៀង ធីរិទ្ធ។ ហើយថ្ងៃនេះ គឺជាសេចក្ដីរបស់លោក ខាំប៊ែល ដដែល នេះគឺជារបាយការណ៍ចុងក្រោយ ហើយកាលពីខែកញ្ញានោះ ក៏មិនមានការជំទាស់ដែរ។ ហើយរបាយការណ៍ចុងក្រោយនេះ គឺ

មេធាវីការពារក្តី អៀង សារី មិនយល់ស្របនោះទេ។ ទោះបីជាមានរបាយការណ៍នេះ មានភាពច្បាស់លាស់ក៏ដោយ ហើយក៏នឹងមានមូលដ្ឋានច្បាស់លាស់ ដែលលោកវេជ្ជបណ្ឌិតបានធ្វើសេចក្តីសន្និដ្ឋានហើយក៏ដោយ។

[១០:៣១:៥៤]

ខ្ញុំបានស្តាប់កាលពីសប្តាហ៍មុន របស់ -- នូវអ្វីដែលការលើកឡើងរបស់មេធាវី អៀង សារី ថ្ងៃនេះក៏ដូចគ្នា គឺថាមិនមានការលើកឡើងនូវសំអាងហេតុពាក់ព័ន្ធទៅនឹងខាងផ្នែកវេជ្ជសាស្ត្រ ដើម្បីជំទាស់ទៅនឹងរបាយការណ៍របស់លោកសាស្ត្រាចារ្យ ខាំប៊ែល នោះទេ។ ដូច្នេះ វាមិនគ្រប់គ្រាន់នោះទេ នៅពេលដែលលើកឡើងថា របាយការណ៍មួយមិនពេញចិត្តខ្លួន ខ្លួនមិនពេញចិត្តនោះ ហើយខ្លួនមិនពេញចិត្តខ្លួនទាមទារឲ្យមានការពិនិត្យពិច័យឡើងវិញនោះ។ ខ្ញុំយល់ស្របទៅនឹងមតិយោបល់របស់សហព្រះរាជអាជ្ញា ដែលលើកឡើងថា អង្គជំនុំជម្រះមិនគប្បីគិតទៅលើទឡ្ហីករណ៍របស់មេធាវីការពារក្តី អៀង សារី នោះទេ។ ហើយខ្ញុំក៏យល់ស្របចំពោះសេចក្តីសន្និដ្ឋានរបស់លោកសហព្រះរាជអាជ្ញាដែលបានលើកឡើងថា យើងមានរបាយការណ៍កោសល្យវិច័យដែលមានលក្ខណៈច្បាស់លាស់រួចមកហើយ ហើយលិខិតរបស់លោកវេជ្ជបណ្ឌិត ប៊ូស ចាន នោះ គ្រាន់តែជាការរិះគន់ទៅលើទម្រង់តែប៉ុណ្ណោះ គឺមិនមានការរិះគន់ទៅលើខ្លឹមសារសំខាន់ទៅលើ -- នៃសេចក្តីសន្និដ្ឋានរបស់សាស្ត្រាចារ្យ ខាំប៊ែល នោះទេ។

[១០:៣២:៥៧]

អាស្រ័យហេតុនេះ ខ្ញុំគិតថា នៅថ្ងៃនេះ យើងក៏ដូចជាសហព្រះរាជអាជ្ញាដែរ សូមឲ្យអង្គជំនុំជម្រះកុំរង់ចាំពេលវេលាតទៅទៀត សូមកុំឲ្យអូសបន្លាយពេលវេលា សូមឲ្យមេត្តាចេញសេចក្តីសម្រេចឲ្យបានលឿន។ សូមធ្វើយ៉ាងណា ឲ្យមានការសម្រេចឲ្យបានឆាប់។ អង្គជំនុំជម្រះសូមមេត្តាមេធាវី -- សុំឲ្យអង្គជំនុំជម្រះបដិសេធចោលនូវការលើកឡើងរបស់មេធាវីការពារក្តី អៀង សារី។

ដើមបណ្តឹងរដ្ឋប្បវេណី សូមឲ្យអង្គជំនុំជម្រះសម្រេចនៅថ្ងៃនេះ ដោយយោងទៅលើស្ថានភាពដែលបានកើតឡើង ហើយនិងពិនិត្យពិច័យទៅលើសម្បទារបស់លោក អៀង សារី ដែលគាត់មានសម្បទាទាំងខាងផ្នែករាងកាយ និងខាងផ្នែកបញ្ញាស្មារតី ក្នុងការចូលរួមសវនាការ។ ដូច្នេះ យើងមានគោលជំហររួមជាមួយនឹងសហព្រះរាជអាជ្ញា។

ខ្ញុំសូមបញ្ចប់ ដោយគ្រាន់តែលើកឡើងថា ប្រសិនបើវត្តមានរបស់លោក អៀង សារី នៅសវនាការ គឺជាសិទ្ធិរបស់គាត់នោះ គឺថាយើងមិនអាចប្រកែកបានទេ ថានេះ ក៏ជាកាតព្វកិច្ចរបស់ចំពោះ

ដើមបណ្តឹងរដ្ឋប្បវេណី និងចំពោះសារធាណជនផងដែរ ថាគាត់ត្រូវតែមានវត្តមានជាចាំបាច់។ យើងបានពិនិត្យមើលទៅលើការសន្និដ្ឋានរបស់របាយការណ៍ហើយ ដែលបានបញ្ជាក់អំពីគោលជំហរនេះ។ ដូច្នេះ សូមឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យពិច័យទៅលើរបាយការណ៍របស់លោកសាស្ត្រាចារ្យដែលបានរៀបរាប់រួចមកហើយ។ សូមអរគុណលោកប្រធាន។

[១០:៣៤:២៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ លោកមេធាវីៗ មាន -- លោកមេធាវីការពារក្តីមានអ្វីចង់ធ្វើសេចក្តីថ្លែងការណ៍តបដែរទេ? សូមអញ្ជើញ បាទ!

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព! ជាការពិតយើងខ្ញុំនឹងឆ្លើយតប។ ខ្ញុំសូមឆ្លើយតបដោយដំបូងទៅនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលបានបញ្ជាក់ថា អ្វីទៅដែលថា វាមិនសម និងវាមិនសមរម្យដូចដែលបានលើកឡើងនោះ ដោយក្រុមមេធាវីការពារក្តី អៀង សារី។ តាមរបាយ-ការណ៍របស់លោកវេជ្ជបណ្ឌិត ខាំប៊ែល នោះ គឺយើងមិនលើកឡើងពាក់ព័ន្ធនឹងទៅនឹងលោកស្រី អៀង ធីរិទ្ធ នោះទេ គឺគាត់មិនមែនជាកូនក្តីរបស់យើងខ្ញុំ ហើយយើងមិនមែនធ្វើការច្របូកច្របល់គ្នា យកប៉ោមមកច្របាច់ចូលជាមួយនឹងក្រូចនោះទេ គឺយើងបានបែងចែកច្បាស់លាស់ណាស់រឿងក្តីនេះ។ហើយយើងគ្រាន់តែលើកឡើងពាក់ព័ន្ធនឹងស្ថានភាពនេះតែប៉ុណ្ណោះ។ នេះគឺជាចំណុចដែលខ្ញុំសូមចាប់ផ្តើម។ ប្រសិនបើអង្គជំនុំជម្រះធ្វើការសម្រេចផ្អែកតាមការស្តាប់ឮនៅក្នុងពេលនេះ ដែលថាលោក អៀង សារី ពិតជាមានសម្បទាក្នុងការចូលរួមសវនាការ ដូចដែលសហព្រះរាជអាជ្ញាលើកឡើងនោះ គឺថានៅពេលនេះ គឺខ្ញុំសូមរំឮកឡើងវិញជូនអង្គជំនុំជម្រះថា យើងមិនមានកំណត់ត្រា កាសែត ឬក៏វីដេអូឲ្យយើងមើលឃើញថា តើលោក អៀង សារី នោះមានស្ថានភាពយ៉ាងម៉េចក្នុងពេលដែលលោក ខាំប៊ែល ទៅពិនិត្យ និងធ្វើការវាយតម្លៃគាត់នោះ?

[១០:៣៦:២០]

យើងគ្រាន់តែទទួលយកពាក្យដែលចេញពីមាត់របស់លោក ខាំប៊ែល តែប៉ុណ្ណោះ។ យើងដឹងហើយថា មេធាវីនោះគឺមិនបានចូលរួមនោះទេ ដោយសារតែវាមាន វាអាចមានការរាំងស្ទះទៅលើការវាយតម្លៃ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា គ្មានខ្សែវីដេអូ ខ្សែអាត់សំឡេងថតទុកពាក់ព័ន្ធទៅនឹងការវាយតម្លៃ

លោក អៀង សារី នៅពេលដែលលោកវេជ្ជបណ្ឌិតធ្វើការវិភាគនោះ។

នៅក្នុងខែកញ្ញា ឆ្នាំ២០០៩ នៅពេលដែលធ្វើការពិនិត្យផ្នែកផ្លូវចិត្តរបស់កូនក្តីរបស់ខ្ញុំនោះ គឺយើងឃើញមានរបាយការណ៍ ហើយចម្លើយនោះ គឺគេឆ្លើយថា "គឺគាត់មិនមានបញ្ហាផ្លូវចិត្តនោះទេ" គឺឯកសារលេខ D38/6 និងឯកសារ D38/5 ឯកសារចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៩ ផ្អែកតាមឯកសារចុះថ្ងៃ១៦ ខែកញ្ញា ឆ្នាំ២០០៩ យោងតាមលិខិតរបស់យើងទៅកាន់ -- ផ្ញើជូនការិយាល័យសហចៅក្រមស៊ើបអង្កេត។ នៅថ្ងៃ១៦ ខែមីនា ឆ្នាំ២០១១ យើងខ្ញុំស្នើសុំឲ្យពិនិត្យមើលលោក អៀង សារី ដោយធ្វើយ៉ាងណាឲ្យសមាជិកមេធាវីការពារក្តីម្នាក់នោះ គាត់ចូលរួមសង្កេតការណ៍នៅក្នុងពេលវាយតម្លៃ។

[១០:៣៧:៥៨]

នៅក្នុងពេលអនាគតនោះ គឺថាយើងខ្ញុំស្នើសុំឲ្យការធ្វើការវាយតម្លៃសុខភាពនោះ គឺថតវីដេអូផងដែរ ហើយក៏ឲ្យយើងនោះធ្វើការចូលតាមដានដំណើរការនោះផងដែរ។ គឺខ្ញុំមកពីប្រព័ន្ធតុលាការមួយដែលខ្ញុំជាមន្ត្រីតុលាការមួយរូបដែលគេតម្រូវឲ្យស្បថផងដែរ។ ក៏ប៉ុន្តែពេលខ្លះទៅ មិនមែនថាអ្វីដែលស្បថនោះ គឺថាយើងអាចយកមកធ្វើជាភស្តុតាងគ្រប់ទាំងអស់នោះទេ។ សហព្រះរាជអាជ្ញាបានលើកឡើងថា វាគ្រោះថ្នាក់ណាស់ មិនត្រូវលើកសេចក្តីសន្និដ្ឋាននៅពេលនេះនោះទេ ដោយសារតែវាអាចមានការកើតឡើងជាក់ស្តែងនាពេលអនាគត។

[១០:៣៨:៤៥]

យើងមិនចាំបាច់ព្រួយបារម្ភចំណុចនេះទេ យើងមានលិខិតបោះបង់សិទ្ធិរួចមកហើយ លើកលែងតែការបោះបង់សិទ្ធិនោះ គឺក្នុងកាលៈទេសៈមួយចំនួននោះ គឺថាមិនអាចឲ្យលោក អៀង សារី នោះមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការពារក្តី។ ផ្អែកតាមការបោះបង់សិទ្ធិ និងការទទួលយករួចមកហើយ ដូចដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់ផងដែរ គឺគេមិនបានចោទសួរទៅលើបញ្ហាការបោះបង់សិទ្ធិនេះទេ។ ដូច្នេះយើងមិនចាំបាច់ព្រួយបារម្ភអំពីការបញ្ហា ការបោះបង់សិទ្ធិនោះទេ ថាតើមេធាវីការពារក្តីដោយភាពឆ្លាតវៃរបស់ខ្លួននោះព្យាយាមធ្វើការប្តឹងសាទុក្ខ ដោយផ្អែកទៅលើដំណើរការនៃការបោះបង់សិទ្ធិនេះ ដែលយើងបានឃើញមាននៅពេលនេះ គឺមិនបាច់ព្រួយបារម្ភទេ។ គឺខ្ញុំយល់អំពីការព្រួយបារម្ភបែបហ្នឹង ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា យើងមិនបាច់ព្រួយបារម្ភទៅលើចំណុចនោះទេ។ វាអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេចផ្អែកទៅតាមការរកឃើញរបស់ឯកសារមួយចំនួន និងរបាយការណ៍មួយចំនួនថា តើលោក អៀង សារី នោះគឺមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងការពារក្តីដែរឬទេ?

ហើយមេធាវីការពារក្ដីនោះក្នុងករណីមានសេចក្ដីសម្រេចមួយចំនួននោះ គឺយើងមានមធ្យោបាយផ្សេងទៀតដែលយើងអាចធ្វើការលើកឡើងឆ្លើយតបទៅលើចំណុចទាំងអស់នេះបាន។

យើងដឹងហើយថា យើងមិនបានធ្វើការ -- មានបំណងធ្វើការប្ដឹងសាទុក្ខដោយសារតែហេតុផលនៃការព្រួយបារម្ភនេះមួយចំនួនពាក់ព័ន្ធទៅនឹងការបោះបង់សិទ្ធិនោះទេ។ ដែលការបោះបង់សិទ្ធិនោះក៏ផ្អែកទៅលើការផ្ដល់យោបល់ និងការពិភាក្សាជាមួយនឹងកូនក្ដីរបស់យើងខ្ញុំ។ ដូច្នេះយើងអាចដំណើរការទៅដោយតាមលក្ខណៈដែលយើងធ្វើការបោះបង់សិទ្ធិនេះ។ ក៏ប៉ុន្តែប្រសិនបើឲ្យគាត់ចូលរួមពីបន្ទប់ឃុំឃាំងនៅខាងក្រោយនោះ គឺថាធ្វើយ៉ាងណាឲ្យមានការតភ្ជាប់ម៉ាស៊ីនវីដេអូ ហើយឲ្យយើងមើលឃើញស្ថានភាពរបស់គាត់នៅទីនោះផង ថាតើគឺគាត់បានចូលរួមដែរឬទេ ឬក៏គាត់គេងក្នុងពេលដែលគាត់ចូលរួម គាត់ងោក គាត់អស់កម្លាំង។

[១០:៤១:២៥]

ដូច្នេះ យើងសូម -- ខ្ញុំសូមលើកឡើងថា ដំណើរការក្ដីរបស់យើងគឺកាត់ក្ដីទៅលើបុគ្គលមានវ័យ ៨៨ឆ្នាំ គឺមានបញ្ហាជាច្រើន ដូច្នេះការចូលរួមការជំនុំជម្រះក្ដីរបស់គាត់នោះគឺមិនអាចដូចនឹងមនុស្សដែលមានស្ថានភាពរឹងប៉ឹងនោះទេ។ ដូច្នេះហើយ យើងដឹងហើយថាបទដ្ឋានដែលយើងត្រូវគោរពនោះ គឺបទដ្ឋានអន្តរជាតិដែលធ្វើយ៉ាងណាឲ្យគាត់ចូលរួមពេញលេញបាន។

ខ្ញុំព្យាយាមមិនធ្វើការលើកឡើងអំពីការរកឃើញណាមួយនៅក្នុងពេលនេះនោះទេ ដោយសារតែយើងមិនទាន់ឃើញមានការសម្រេច និងការរកឃើញនូវឡើយនោះទេ។ ដូច្នេះប្រសិនបើអង្គជំនុំជម្រះសម្រេច និងរកឃើញបែបណាមួយនោះ គឺថាយើងខ្ញុំនឹងសូមធ្វើឲ្យមានការពិនិត្យទៅលើកូនក្ដីរបស់យើងខ្ញុំម្ដងទៀត ដើម្បីកុំឲ្យយើងជួបប្រទះនូវស្ថានភាពដែលថា នៅពេលដែលថា មិនមាន -- គាត់មិនមានបញ្ហាអ្វីនោះ គឺថាយើង -- នៅពេលក្រោយយើងរកឃើញបញ្ហាផ្សេងទៅវិញ បែរយើងខ្ញុំស្នើសុំឲ្យមានការបំបែកសំណុំរឿងទៅលើរូបគាត់។

[១០:៤២:៣៦]

ដូចតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលជាតុលាការមួយបានផ្ដល់នូវយុត្តិសាស្ត្រយ៉ាងច្រើនក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ ដែលខ្ញុំធ្វើការនៅទីនោះផងដែរ។ ប្រសិនបើយើងមើលរឿងក្ដី ស្ត្រូហ្គា -- ប្រសិនបើយើងមើលទៅលើសេចក្ដីសម្រេចនៅថ្ងៃ១៧ ខែកក្កដា ឆ្នាំ២០០៨ សេចក្ដីសម្រេចនេះមានលេខ០១--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកចៅក្រម ឲ្យមេធាវីបញ្ជាក់រឿងក្ដីនៅស្ទ្រូហ្កានេះឡើងវិញ។

**លោក ម៉ៃខល កាណាវាស៖**

*(គ្មានការបកប្រែ)*

[១០:៤៣:៣២]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់នូវរឿងក្ដីស្ទ្រូហ្កាចុងក្រោយអំមិញ ដែលលោកបង្ហាញនេះព្រោះអ្នកបកប្រែបកប្រែអត់ទាន់ទេ អត្តសញ្ញាណនៃឯកសារ។

**លោក ម៉ៃខល កាណាវាស៖**

រឿងក្ដីនេះគឺ IT/01/42/A នេះគឺជារឿងក្ដីដែលខ្ញុំយោងទៅតាមអ្វីដែលព្រះរាជអាជ្ញា គាត់បានយោងអម្បាញ់មិញនេះ គឺ IT/01/42/A សេចក្ដីសម្រេចចុះថ្ងៃ១៧ ខែកក្កដា ឆ្នាំ២០០៨។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:៤៤:២៦]

**លោក វីល្លៀម ស្មីត៖**

សូមអធ្យាស្រ័យ គឺយើងយោងទៅលើសេចក្ដីសម្រេចរបស់សាលាដំបូង បន្ទាប់មកគេប្ដឹងឡើងទៅឧទ្ធរណ៍ ទៅសាទុក្ខតែប៉ុណ្ណោះ។

**លោក ម៉ៃខល កាណាវាស៖**

គឺដដែលទេ សេចក្ដីសម្រេចនោះ។ ដូចតែគ្នា ដែលក្នុងនោះអង្គជំនុំជម្រះបានកំណត់មូលដ្ឋានមួយចំនួន យើងក៏ទទួលស្គាល់ហើយថារឿងក្ដីនោះបានប្ដឹងឡើងទៅលើ គឺមានការប្ដឹងឡើងទៅលើមែន។ អ្វីដែលយើងឃើញនៅពេលនោះ គឺថាអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ឬសាលាឧទ្ធរណ៍ គឺគេបានបញ្ជាក់ថា បញ្ជាក់ទៅលើសេចក្ដីសម្រេចមួយចំនួនរបស់សាលាដំបូង។

នៅក្នុងកថាខណ្ឌ៥៥ គឺបានលើកឡើងថា ខ្ញុំអានពីចំណុចពាក់កណ្ដាល "... ដូចកត់សម្គាល់ខាងលើ បទដ្ឋានអនុវត្តទៅបានគឺការចូលរួមដោយមានន័យគ្រប់គ្រាន់ ដែលអាចអនុញ្ញាតឲ្យជនជាប់ចោទអនុវត្តសិទ្ធិជំនុំជម្រះ ដោយយុត្តិធម៌របស់ខ្លួនក្នុងកម្រិតមួយ ដែលឲ្យគាត់ចូលរួមដោយប្រសិទ្ធភាព

ក្នុងការជំនុំជម្រះក្តីរបស់គាត់ និងឲ្យគាត់យល់ខ្លឹមសារសំខាន់ នៃកិច្ចដំណើរការនីតិវិធី”។ បន្ទាប់មកគេសរសេរបន្ត -- ថែងបន្តទៀត “នៅក្នុងន័យនេះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានយ៉ាងត្រឹមត្រូវ ដូចដែលបង្ហាញនៅក្នុងភស្តុតាងនៅក្នុងសេចក្តីសន្និដ្ឋាន ដែលថា សម្បទាការចូលរួមជំនុំជម្រះក្តីរបស់ជនជាប់ចោទ គឺវាអាស្រ័យទៅលើសមត្ថភាព និងទស្សនៈការយល់ឃើញរបស់គាត់ ដោយគាត់ត្រូវយល់ឃើញឲ្យមានហេតុផលគ្រប់គ្រាន់ និងអាចផ្តល់យោបល់ត្រឹមត្រូវ ក្នុងលក្ខណៈមួយដែលឲ្យគាត់នេះអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងករណីមួយចំនួននោះ គឺដោយមានការជួយជ្រោមជ្រែង និងអាចអនុវត្តសិទ្ធិដោយមានប្រសិទ្ធភាព”។ បញ្ចប់ការដកស្រង់សម្តីចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង សាលាក្តី អាយ. ស៊ី.ធី.វ៉ាយ។

[១០:៤៦:៤៣]

អ្វីដែលខ្ញុំឲ្យអង្គជំនុំជម្រះចាប់អារម្មណ៍នោះគឺ ត្រង់ពាក្យដែលថា តាមសុភវិនិច្ឆ័យ ពាក្យថា “*ខំមិនសិនស៍*”។ ដូច្នេះហើយ ក្នុងនាមជាវេជ្ជបណ្ឌិត ប្រសិនបើក្នុងនាមជាអ្នកវិជ្ជាជីវៈនោះ នៅពេលដែលបុគ្គលម្នាក់នោះ គាត់ងោក គឺថា ពាក្យថា “សុភវិនិច្ឆ័យ” នេះ មិនមានថាគាត់ហ្នឹងអាចតាមដាននីតិវិធីនេះពេញលេញនោះទេ។ ដូច្នេះតើឲ្យបុគ្គលម្នាក់នោះ តាមដាននីតិវិធីយ៉ាងម៉េច នៅពេលដែលគាត់ងោក? ហើយយើងត្រូវពិនិត្យមើលគាត់ហ្នឹងឲ្យគ្រប់ស្ថានភាព លោក អៀង សារី នេះគ្រប់ស្ថានភាព ថាតើគាត់ហ្នឹងគឺពីពេលមួយទៅពេលមួយហ្នឹង គឺថាតើគាត់នឹងងោក ហើយគាត់នឹងអស់កម្លាំងឬយ៉ាងម៉េច? ហើយថាតើគាត់នោះមានសភាពវិលមុខឺងធោងដែរឬទេ? ឬក៏គាត់នោះឈឺចុកចាប់ដែលអាចតដំណើរការនីតិវិធី ឬក៏យ៉ាងណា? ហើយយើងត្រូវឈប់សម្រាករយៈពេលក្រោយពី១០, ១៥ នាទី ដើម្បីឲ្យគាត់អាចចូលរួមវិញ ឬក៏យ៉ាងម៉េច?

[១០:៤៧:៤៥]

នេះគឺជាធាតុផ្សំដែលគេសម្រេចនៅក្នុងសេចក្តីសម្រេចរបស់ស្ត្រូហ្កា។ យើងត្រូវតែប្រើ “សុភវិនិច្ឆ័យ”របស់យើង។ យើងទាំងអស់គ្នាមិនបានចូលរួមនៅក្នុងពេលធ្វើការវាយតម្លៃដោយលោកសាស្ត្រាចារ្យនោះទេ ទាំងអស់គ្នា គឺទាំងសហព្រះរាជអាជ្ញា មេធាវីការពារក្តី និងមេធាវីការពារក្តី។ យើងមិនបានតាមដានទាំងអស់គ្នានោះទេ។

ដូច្នេះហើយមិនមែនថា យើងទាំងអស់គ្នាហ្នឹង រាល់ថ្ងៃសុខភាពល្អទាំងអស់នោះ។ វាមានថ្ងៃដែលយើងសុខភាពចុះខ្សោយ។ ដូច្នេះនៅក្នុងពេលនេះ យើងដឹងហើយថា ក្នុងករណីថ្ងៃជាក់លាក់ណា

មួយនោះ គឺយើងត្រូវមានការចាត់វិធានការជាក់លាក់ទៅលើស្ថានភាពរបស់យើង។ វាមិនមែនជាអ្វីដែលគ្រោះថ្នាក់នោះទេ គឺជាការដែលយើងត្រូវធ្វើដោយហ្មត់ចត់ និងយកចិត្តទុកដាក់ ដោយសារតែយើងធ្វើយ៉ាងនេះ គឺយើងធ្វើដើម្បីកុំឲ្យមានការបោះបង់គ្រប់សិទ្ធិទាំងអស់របស់ជនជាប់ចោទ ដោយ -- ហើយយើងត្រូវសម្រេចផងថាតើលោក អៀង សារី នោះមានសម្បទាគ្រប់គ្រាន់ ឬក៏យ៉ាងម៉េច?

ហើយប្រសិនបើស្នើសុំឲ្យខ្ញុំសរសេរជាសារណាជាលាយលក្ខណ៍អក្សរបន្ថែមនោះ គឺយើងខ្ញុំអាចធ្វើទៅបាន គឺយើងខ្ញុំនៅតែសុំឲ្យមានការតែងតាំងអ្នកជំនាញឯករាជ្យមួយ ដើម្បីធ្វើការវាយតម្លៃទៅលើស្ថានភាពរបស់គាត់។

[១០:៤៩:១៦]

ដូច្នេះហើយសេចក្ដីសន្និដ្ឋានរបស់ខ្ញុំ ដូចដែលយើងខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថា ក្នុងស្ថានភាពនេះ យើងទុកដំណើរការហ្នឹងឲ្យអ៊ីចឹងសិនទៅ ហើយយើងនឹងគិតគូរនៅពេលស្ថានភាពណាមួយលេចឡើងឲ្យយើងឃើញ។ យើងដឹង សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីគឺចង់ឲ្យមានភាពច្បាស់លាស់នៅក្នុងពេលនេះ។ ហើយគឺវាអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេចទៅលើស្ថានភាពទាំងអស់នេះ។ យើងត្រូវពិចារណាឡើងវិញ ដោយសារនេះគឺជាកាតព្វកិច្ចរបស់ខ្ញុំ កាតព្វកិច្ចរបស់យើងខ្ញុំ ដែលធ្វើយ៉ាងណាឲ្យយើងខ្ញុំនេះ អាចការពារកូនក្ដីរបស់យើងដោយយកចិត្តទុកដាក់ ដោយពេញលេញ និងការពារផលប្រយោជន៍របស់កូនក្ដីរបស់យើងខ្ញុំបាន។ យើងមិនមានពេលវេលាគ្រប់គ្រាន់ក៏ដោយ ក៏ប៉ុន្តែយើងត្រូវតែធ្វើដូច្នេះ ជាកាតព្វកិច្ចរបស់យើង។ យើងត្រូវតែបង្កើតវិធីសាស្ត្រច្នៃប្រឌិតមួយ ដើម្បីឲ្យយើងដំណើរការទៅមុខបាន និងទោះបីជាយើងដឹងថាក្នុងកាលៈទេសៈមួយចំនួនហ្នឹងមានការសម្រេចផ្សេងពីនេះក៏ដោយ។ ដូច្នេះយើងត្រូវតែធ្វើឡើងដើម្បីផលប្រយោជន៍ទាំងអស់នេះ។

យើងខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្ដងទៀតដល់អង្គជំនុំជម្រះសាលាដំបូងក្នុងនាមជាក្រុម ក្នុងនាមក្រុមមេធាវីការពារក្ដីរបស់លោក អៀង សារី ខ្ញុំសូមថ្លែងអំណរគុណដែលផ្ដល់ឱកាសយើងខ្ញុំផ្ដល់សេចក្ដីសន្និដ្ឋានដ៏សំខាន់បែបនេះជាសាធារណៈ។ បញ្ហាទាំងអស់នេះ គឺជាបញ្ហាដែលសំខាន់បំផុតដែលត្រូវយកមកដេញដោលជាសាធារណៈបែបនេះ។ សូមអរគុណ។

[១០:៥០:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

លោក កាលណាវាស ខ្ញុំនៅសល់សំណួរចុងក្រោយមួយទៀតសួរលោក។ ខ្ញុំទំនងជាយល់ឃើញថា លោកយល់ថាកូនក្ដីរបស់លោក។ អៀង សារី នៅពេលនេះ នៅតែមិនមានសម្បទាគ្រប់គ្រាន់ ក៏ប៉ុន្តែលោកមិនចង់ឲ្យអង្គជំនុំជម្រះចេញសេចក្ដីសម្រេចលើបញ្ហានៅពេលនេះតែម្ដងនោះទេ លោកស្នើសុំឲ្យបន្តដេញដោលស្ដាប់សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលលោក អៀង សារី នោះគាត់មិនបារម្ភគាត់បានបោះបង់សិទ្ធិ។ អ្វីដែលខ្ញុំចង់សួរនោះ គឺថាប្រសិនបើយើងធ្វើដូច្នេះ ផ្អែកតាមដំណើរការរបស់សាលាដំបូងនោះ គឺវាទំនងជាអាចធ្វើទៅបានក្នុងកម្រិតអប្បបរមា គឺយើងបន្តសវនាការរបស់លោក អៀង សារី ក្នុងពេលដែលគាត់មានស្ថានភាពគ្រប់គ្រាន់។ ខ្ញុំដឹងហើយថា លោកមិនចង់ឲ្យអង្គជំនុំជម្រះធ្វើសេចក្ដីសម្រេចលើបញ្ហាសម្បទារបស់លោក អៀង សារី នៅពេលនេះនោះទេ ហើយគឺយើងខ្ញុំត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ទៅលើចំណុចដំណើរការនេះ។ គ្មាននរណាម្នាក់ដែលលើកឡើងថាក្រុមរបស់លោកមិនធ្វើការដោយយកចិត្តទុកដាក់នោះទេ គេមិនបាននិយាយដូច្នោះនោះឡើយ ក៏ប៉ុន្តែយើងរកមធ្យោបាយ ថាតើដោះស្រាយបញ្ហានេះយ៉ាងម៉េច? ដំណើរការពីពេលនេះទៅដោយរបៀបណា? ហើយដើម្បីដោះស្រាយបញ្ហាទាំងអស់ដែលយើងជួបប្រទះ។

[១០:៥២:៤១]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៌។ ខ្ញុំសូមចាប់ផ្ដើមដោយលើកឡើងថា លោក អៀង សារី សម្បទារបស់គាត់នោះ គឺគាត់មានលក្ខណៈកម្រិតចូលរួមដោយក្នុងលក្ខណៈកម្រិតតែប៉ុណ្ណោះ អាចចូលរួម១០ ទៅ ១៥នាទី តែប៉ុណ្ណោះ ដែលវាអាចឲ្យយើងឲ្យគាត់ហ្នឹងណែនាំយើងខ្ញុំបាន។ ដូច្នេះអ្វីដែលខ្ញុំលើកឡើងនេះ គឺថាសម្បទារបស់គាត់ក្នុងចូលរួមក្នុងលក្ខណៈខ្លីដូច្នេះ គឺវាមិនបានបំពេញទៅតាមបទដ្ឋានអន្តរជាតិ ដូចមានចែងនៅក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ និងរដ្ឋធម្មនុញ្ញកម្ពុជានោះឡើយ។

យើងខ្ញុំសង្ឃឹម ខ្ញុំនិយាយអ៊ីចឹងទៅថា ខ្ញុំសង្ឃឹមថាស្ថានភាពរបស់គាត់នឹងធូរស្បើយនឹងប្រសើរឡើងវិញ។ ហេតុដូច្នេះហើយ យើងខ្ញុំបានលើកឡើងជំហរថា ដរាបណាយើងមានការបោះបង់សិទ្ធិរបស់គាត់លើសាក្សីនេះមួយចំនួន ដំណើរការសវនាការនេះគួរតែបន្តទៅមុខទៀតសិនទៅ ហើយអ្វីដែលយើងព្រួយបារម្ភគឺថាយើងខ្ញុំមិនចង់ឲ្យមានការរារាំង និងការផ្អាកដំណើរការសវនាការ។ យើងខ្ញុំមិនគិតថា -- យើងខ្ញុំគិតថា សេចក្ដីសម្រេចលើបញ្ហានេះគឺថាមិនចាំបាច់ទេនៅពេលនេះ ដោយសារតែយើង

មានការបោះបង់សិទ្ធិរបស់លោក អៀង សារី។ ហើយប្រសិនបើមានស្ថានភាពណាមួយប្រែប្រួលនោះ គឺថាយើងខ្ញុំនឹងមានជំហរផ្សេង និងមានមធ្យោបាយ និងវិធានការផ្សេងនឹងត្រូវលើកឡើង។ ក៏ប៉ុន្តែ ដំណាក់ការនេះ គឺយើងធ្វើឡើងដូចដែលខ្ញុំបានបញ្ជាក់។ វាអាស្រ័យទៅលើការសម្រេចដ៏ត្រឹមត្រូវ និង មានហេតុផលគ្រប់គ្រាន់ពីអង្គជំនុំជម្រះ។ ខ្ញុំមិនមែនថា ចង់ចំណេញទាំងពីរផ្លូវនោះទេ ក៏ប៉ុន្តែគឺ អាស្រ័យទៅលើអង្គជំនុំជម្រះបើសិនបើអង្គជំនុំជម្រះសម្រេចថា ចង់ធ្វើសេចក្តីសម្រេចនៅពេលនេះ គឺថាយើងខ្ញុំអនុវត្តតាម មិនជាបញ្ហាអ្វីនោះទេ គឺខ្ញុំនឹងរកវិធានការ និងធ្វើការលើកឡើងទៅលើបញ្ហានៃ សេចក្តីសម្រេច និងអ្វីៗដែលខ្ញុំបានបញ្ជាក់នេះ។ ហើយខ្ញុំលើកឡើងដូចម្តង ដូចដែលខ្ញុំបានបញ្ជាក់ហើយ គឺថា ក្នុងពេលដែលគាត់ចូលរួមបាន តែរយៈពេលខ្លីៗដូច្នេះ គឺគាត់មិនអាចចូលរួមពេញលេញបាន នោះទេ។

[១០:៥៥:០៩]

ខ្ញុំមិនមែនថា ខ្ញុំនឹងទៅធ្វើការពិភាក្សាជាមួយនឹងលោក អៀង សារី ដោយដកការបោះបង់សិទ្ធិ នោះវិញនោះទេ។ យើងដឹងហើយ យើងធ្វើយ៉ាងណាឲ្យលោក អៀង សារី នោះ មានស្ថានភាពនោះ ល្អ សម្រាប់គាត់ ហើយឲ្យគាត់អាចមានសមត្ថភាព និងសម្បទាគ្រប់គ្រាន់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធី នេះ។ ខ្ញុំសូមបញ្ចប់ដោយលើកឡើងថា នៅពេលដែលយើងឆ្លើយតបទៅនឹងសំណួរទាំងអស់នេះ យើង គួរតែសួរខ្លួនឯង តើយើង គិតថាយើងក្នុងស្ថិតក្នុងស្ថានភាពដូចបុគ្គលម្នាក់ ដែលគាត់កំពុងតែជួបប្រទះ នេះ ឬក៏យ៉ាងម៉េច? ដែលគាត់កំពុងតែតាមដានកិច្ចដំណើរការនីតិវិធីក្នុងប្រភេទបែបនេះ។ ខ្ញុំដឹងថា គ្មាននរណាម្នាក់នៅក្នុងនេះ នឹងនិយាយថា ពិតជាដូច្នោះនោះឡើយ។

[១០:៥៦:០៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញប្តូរៗ ប្តូរឌីវីឌី សិនទៅ ហើយរាយការណ៍ប្រាប់យើងវិញ នៅពេលដែលរៀបចំរួច។

លោកមេធាវី ប្តូរឌីវីឌី ដោយសារអស់ឌីវីឌីហើយ អ៊ីចឹងយើងឲ្យប្តូរសិន ទើបយើងបន្តកិច្ច ដំណើរការនីតិវិធីហ្នឹង ឲ្យចប់ទី១ ហើយនិងយើងជូនវេទិកា ជូនទៅលោក។

[១០:៥៦:៣៩]

*(មន្ត្រីផ្នែកសោតទស្សន៍រៀបចំប្តូរឌីវីឌី)*

[១០:៥៦:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ អស់លោក លោកស្រី ក្នុងនាមខ្ញុំជាប្រធាន និងជំនួសមុខឲ្យអង្គចៅក្រម នៃអង្គជំនុំជម្រះសាលាដំបូងទាំងអស់ ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាល់មតិយោបល់បានលើកឡើងនៅក្នុងសវនាការរយៈពេល១ថ្ងៃ គឺថ្ងៃព្រហស្បតិ៍ ទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ និងព្រឹកនេះ។ អង្គជំនុំជម្រះនឹងយកមតិយោបល់អ្នកជំនាញ និងមតិយោបល់របស់ភាគីពាក់ព័ន្ធនានា ដែលបានលើកឡើងពិភាក្សាអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ យកទៅពិនិត្យពិចារណា ពិភាក្សា និងចេញសេចក្តីសម្រេចសមស្របនាពេលខាងមុខ។

ខ្ញុំសូមថ្លែងអំណរគុណដល់សហព្រះរាជអាជ្ញា សហមេធាវីការពារក្តីលោក អៀង សារី មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មន្ត្រីនៃបណ្តាផ្នែកចំណុះឲ្យការិយាល័យរដ្ឋបាល មន្ត្រីសន្តិសុខ អនុរក្សមន្ទីរឃុំឃាំង បុគ្គលិកនៃអង្គជំនុំជម្រះសាលាដំបូង និងអ្នកបកប្រែសាភាផ្ទាល់មាត់ ដែលបានខិតខំប្រឹងប្រែចូលរួមយ៉ាងសកម្មភាព ហើយជ្រោមជ្រែងធ្វើឲ្យសវនាការនេះ ប្រព្រឹត្តទៅបានរលូត។

[១០:៥៨:០៨]

ហើយខ្ញុំសូមប្រកាសបិទសវនាការពិភាក្សាដេញដោល លើរបាយការណ៍របស់អ្នកជំនាញ លើបញ្ហាសុខភាពរបស់លោក អៀង សារី ក្នុងការចូលរួមសវនាការត្រឹមនេះ។ ហើយជាបន្តនេះ គឺសវនាការពិនិត្យភស្តុតាង គឺតាមស្តាប់សក្ខីកម្មសាក្សី TCW-507 គឺបន្តសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០១ តាមកាលបរិច្ឆេទដែលបានគ្រោងទុក។

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់។ ខ្ញុំសូមនិយាយដោយសង្ខេបទេ ដោយសារមើលទៅម៉ោង ហើយខ្ញុំគិតថា អ្នកបកប្រែប្រហែលជាអស់កម្លាំងណាស់ទៅហើយ ប៉ុន្តែខ្ញុំព្យាយាមប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាព យើងទទួលបានការជូនដំណឹង មុនពេលចាប់ផ្តើមសវនាការដោយមន្ត្រីរបស់សាលាដំបូងថា កូនក្តីរបស់យើង គឺលោក នួន ជា មិនមានសុខភាពល្អនោះទេ ហើយគាត់កំពុងតែជួបជាមួយនឹងវេជ្ជបណ្ឌិត។

[១០:៥៩:១៩]

ក្នុងពេលនេះ គឺយើងដឹងត្រឹមតែប៉ុណ្ណោះទេ ហើយសំណើសុំរបស់យើង គឺថាមុនពេលយើងបន្តសវនាការជាមួយសាក្សីបន្ទាប់ យើងស្នើសុំឲ្យមានការបញ្ជាក់ ថាតើវេជ្ជបណ្ឌិត គាត់ពិនិត្យទៅឃើញថាមានស្ថានភាពបែបណា? ហើយយើងចង់ដឹងថា តើលោកវេជ្ជបណ្ឌិតបានពិនិត្យលោក នួន ជា ហ្នឹង ដើម្បីឲ្យដឹងថា តើគាត់មានលទ្ធភាពចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ឬអត់? ប្រសិនបើលោកវេជ្ជបណ្ឌិតមិនបានធ្វើពិនិត្យលោក នួន ជា ថាតើលោក នួន ជា អាចចូលរួមសវនាការ ឬក៏អត់?

ដូច្នេះ យើងស្នើសុំថា ឲ្យវេជ្ជបណ្ឌិតពិនិត្យទៅលើលោក នួន ជា អំពីស្ថានភាពបែបនេះ មុនពេលដែលយើងចាប់ផ្ដើមសវនាការស្ដាប់សាក្សីបន្ត។ ដូច្នេះហើយខ្ញុំគិតថា ប្រសិនបើខ្ញុំបាននិយាយពីមុន គឺខ្ញុំមានឱកាសនឹងស្នើសុំឲ្យវេជ្ជបណ្ឌិតធ្វើការតាំងពី២ម៉ោងមុនមកម្ល៉េះ។ ដូច្នេះហើយ គឺយើងគ្រាន់តែស្នើសុំឲ្យវេជ្ជបណ្ឌិតធ្វើការពិនិត្យទៅលើលោក នួន ជា ថាតើលោក នួន ជា អាចមានលទ្ធភាពចូលរួមសវនាការបាន ឬក៏អត់? ហើយយើងស្នើសុំនូវឯកសារបញ្ជាក់អំពីលទ្ធផលនៃការវាយតម្លៃ។ ប៉ុន្តែក្នុងករណីដែលវេជ្ជបណ្ឌិតមិនទាន់បានធ្វើការវាយតម្លៃទៅលើលោក នួន ជា ទេ យើងស្នើសុំឲ្យលោកវេជ្ជបណ្ឌិត ឲ្យអង្គជំនុំជម្រះបង្គាប់ទៅលោកវេជ្ជបណ្ឌិត ធ្វើការវាយតម្លៃលោក នួន ជា ក្នុងពេលឥឡូវនេះ។

ដូច្នេះ គឺយើងបន្ទាប់ពីពិនិត្យលទ្ធផលហើយ យើងនឹងពិនិត្យថា តើយើងត្រូវឲ្យលោក នួន ជា តាមដានពីបន្ទប់ខាងក្រោម ឬក៏ឲ្យបញ្ជូនគាត់ទៅបន្ទប់ឃុំខ្លួនបន្តទៅទៀតមុននឹងចាប់ផ្ដើមសវនាការលើសាក្សីបន្ទាប់។ សូមអរគុណ។

[១១:០០:៥៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៣:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានទទួលនូវការពិនិត្យសុខភាពបឋមរបស់លោកវេជ្ជបណ្ឌិត អែម សារឿន ដែលបានពិនិត្យសុខភាពរបស់លោក អៀង សារី កាលពីព្រឹកមិញថា គាត់មានបញ្ហាសញ្ញាវិលមុខ ធឹងធោង ហើយនិងអស់កម្លាំង។ ហើយស្ថានភាពនេះ គឺមិនស្រួលដូចសព្វមួយដងទេ ប៉ុន្តែមិនបានបញ្ជាក់ថាគាត់មានអាការៈធ្ងន់ធ្ងរនោះឡើយ។ ហើយអនុសាសន៍របស់លោកគ្រូពេទ្យព្រឹកមិញ គឺគាត់បានផ្ដល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យជនជាប់ចោទនៅថ្ងៃនេះ បន្តការតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។

នេះជាព័ត៌មានដែលយើងទទួលបាននៅមុនពេលចូលមកកិច្ចដំណើរការសវនាការនេះ។

[១១:០៤:៤១]

**លោក ហ្សាស្តើ ប៉ោះ**

លោកប្រធាន ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមបញ្ជាក់ថា យើងមិនធ្លាប់ដែលឃើញសេចក្តីសន្និដ្ឋានវេជ្ជបណ្ឌិតបែបនេះទេ។ ដូច្នេះ ខ្ញុំស្នើសុំថា ខ្ញុំសូមពិនិត្យមើលទៅលើឯកសាររបាយ-ការណ៍របស់លោកវេជ្ជបណ្ឌិតមុនពេលដែលយើងកោះហៅសាក្សីចូលមកក្នុងសវនាការនេះ។ ដូច្នេះខ្ញុំនឹងពិនិត្យមើលទៅលើរបាយការណ៍នេះនៅពេលដែលយើងឈប់សម្រាក។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដោយសារមានមូលហេតុនៃបញ្ហាសុខភាពរបស់លោក នួន ជា ហើយបាន -- ដែលមានបញ្ជាក់ដោយលោកវេជ្ជបណ្ឌិតទទួលបន្ទុកពិនិត្យ ព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងដូចដែលអង្គជំនុំជម្រះជម្រាបជូនភាគី និងសាធារណជនអម្បាញ់មិញនេះរួចហើយ ហេតុដូច្នេះអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការនៅ -- ចាប់ពីពេលនេះតទៅរហូតដល់រសៀល។ ហើយដោយ នួន ជា លះបង់សិទ្ធិនៅក្នុងការចូលរួមសវនាការក្នុងសវនាការនេះ ហើយអង្គជំនុំជម្រះនឹងបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនា-ការចាប់ពីពេលនេះទៅរហូតដល់ពេលរសៀល។

[១១:០៦:៣៧]

បាទ ដោយឡែកនៅកំណត់ហេតុនៃការពិនិត្យសុខភាពរបស់លោកវេជ្ជបណ្ឌិត ចំពោះសុខភាពលោក នួន ជា នៅព្រឹកនេះគឺក្រឡាបញ្ជីចាត់បញ្ចូលទៅក្នុងសំណុំរឿងដូចឯកសារដែលបានពិនិត្យសុខភាពរបស់លោក អៀង សារី និងជនជាប់ចោទដទៃទៀតដូចសព្វដង ដើម្បីឲ្យភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះអាចពិនិត្យមើលបានរាល់ -- ដូចរាល់ដង ហើយបញ្ហាមួយទៀតគឺនៅពេលបន្តិចទៀតនេះអង្គជំនុំជម្រះសូមបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ឡើងមកកាន់បន្ទប់សវនាការដើម្បីបន្តចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅបន្តិចទៀតនេះក្រោយពេលសម្រាក។

សូមអញ្ជើញលោកមេធាវី!

[១១:០៧:៣១]

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ដើម្បីបញ្ជាក់ឲ្យច្បាស់ លោក នួន ជា មិនបានលះបង់សិទ្ធិក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីក្នុងសាលសវនាការនេះឡើយ ព្រោះថាមិនៗ -- ដោយសារមិនបានពិភាក្សា -- ដោយសារមេធាវីការពារក្តីមិនទាន់បានពិភាក្សាជាមួយវេជ្ជបណ្ឌិត ដូច្នេះគោលជំហររបស់យើងគឺថារបាយ-ការណ៍វេជ្ជបណ្ឌិតគួរតែផ្តល់ទៅដល់មេធាវីការពារក្តី ដើម្បីឲ្យមេធាវីការពារក្តីពិនិត្យមើល ហើយនិងសម្រេចថាតើត្រូវលះបង់សិទ្ធិចូលរួម មិនចូល -- លះបង់សិទ្ធិមិនចូលរួមនៅក្នុងសាលសវនាការនេះ ហើយបន្តចូលរួមនៅក្នុងបន្ទប់ឃុំឃាំង ឬក៏អត់នោះ។ ហើយយើងក៏ទទួលបាននូវព័ត៌មានមួយផងដែរថា គឺថានៅក្នុងព្រឹក -- តាមអ្នកស្តាប់ភាសាខ្មែរនៅពេលដែលលោកប្រធានមានប្រតិកម្មដំបូងគឺលោកប្រធានបានបញ្ជាក់ថា ជារបាយការណ៍វេជ្ជសាស្ត្ររបស់លោក អៀង សារី មិនមែនរបស់លោក នួន ជា នោះទេ។ ដូច្នេះខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា តើរបាយការណ៍វេជ្ជបណ្ឌិតនុ៎ងគឺជារបស់លោក អៀង សារី ឬក៏លោក នួន ជា? អ៎! ខ្ញុំឃើញលោកស្រីចៅក្រម ខាតរ៉ាយច៍ បានបញ្ជាក់ច្បាស់ហើយថា ជារបស់លោក នួន ជា។ ដូច្នេះហើយគឺខ្ញុំខាងមេធាវីការពារក្តីនឹងពិនិត្យមើលនៅពេលឈប់សម្រាកនេះ ថាតើត្រូវពិនិត្យរបាយការណ៍របស់ -- សម្រេចយ៉ាងម៉េច។

**ចៅក្រម ស៊ីលវៀ ខាតរ៉ាយច៍៖**

សូមអរគុណលោកប្រធាន ដើម្បីបញ្ជាក់ឲ្យច្បាស់ របាយការណ៍នោះគឺជារបាយការណ៍របស់លោក នួន ជា ហើយលោកមេធាវីនឹងទទួលបាននូវរបាយការណ៍នៅពេលឈប់សម្រាកនេះ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណ ហើយខ្ញុំច្បាស់ហើយទៅលើបញ្ហានេះ។

[១១:០៩:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១២:២២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេល

នេះតទៅរហូតដល់ម៉ោងដប់មួយ សាមសិបនាទីចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ គឺនឹងដំណើរការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-507។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:១២ នាទី ដល់ម៉ោង ១១:៣១ នាទី)*

[១១:៣១:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយដូចអង្គជំនុំជម្រះបានជម្រាបអ៊ីចឹង សវនាការនេះតាមកាលវិភាគដែលបានគ្រោងទុក គឺយើងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-507។

ហើយមុននឹងកោះហៅសាក្សីចូលមកកាន់បន្ទប់សវនាការ អង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្តីថា តើបញ្ហាលះបង់សិទ្ធិ ឬមិនលះបង់សិទ្ធិរបស់លោក នួន ជា អំមិញដែលលោកបានលើកឡើងហ្នឹង លោកប្រកាន់ជំហរយ៉ាងម៉េចច្បាស់លាស់ ដើម្បីអង្គជំនុំជម្រះពិនិត្យពិចារណាលើការដកហូតនូវសេចក្តីសម្រេចដែលយើងបានសម្រេចកន្លងមកនេះវិញ ដើម្បីយើងសម្រេចលើបញ្ហានេះសាជាថ្មី ប្រសិនបើមានបញ្ហាខុសពីនេះ?

[១១:៣២:៥៩]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ជាការពិតយើងបានមើលរបាយការណ៍ ហើយយើងបានពិភាក្សាជាមួយកូនក្តីរបស់ខ្ញុំ នួន ជា។ នួន ជា គាត់បោះបង់សិទ្ធិមិនចូលរួមក្នុងសវនាការដោយផ្ទាល់នៅទីនេះ ហើយគាត់ស្នើសុំបន្តសវនាការ -- តាមដានសវនាការពីបន្ទប់ខាងក្រោម។ វេជ្ជបណ្ឌិតបានបញ្ជាក់ថា គឺគាត់មិនមានសុខភាពល្អ ហើយអស់កម្លាំង។ ជាទូទៅគឺថាជារួម គឺកូនក្តីគាត់មិន -- កូនក្តីខ្ញុំគាត់មិនចង់ឲ្យមានការពន្យារសវនាការ ដូច្នេះហើយគឺគាត់ស្នើសុំបោះបង់សិទ្ធិមិនចូលតាមដានសវនាការដោយ

ផ្ទាល់ក្នុងបន្ទប់សវនាការនៅក្នុងថ្ងៃនេះ ហើយសូមតាមដានពីខាងក្រោម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មិនមានអ្វីប្រែប្រួលទេ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-507 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

[១១:៣៤:០៩]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១១:៣៥:២៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនឲ្យបានជម្រាបថា អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលចំពោះសាក្សីចំនួន១០រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦រូប។ ក្នុងចំណោមសាក្សីចំនួន១០រូប ក៏មានឈ្មោះសាក្សីដែលមានរហស្សនាម TCW-507 ម្នាក់ផងដែរ។ ហើយនៅពេលនេះ លោក អៀង សារី សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងមួយចំនួន ដោយមានដែនកំណត់ ដោយគាត់មានបញ្ហាសុខភាព តែរូបកាយនិងស្មារតីសមស្រប។ អង្គជំនុំជម្រះសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-507 ដោយមិនមានវត្តមានលោក អៀង សារី ដោយអនុវត្តតាមវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[១១:៣៦:៣៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកសាក្សីឈ្មោះអី?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំបាទជាសាក្សី ខ្ញុំបាទឈ្មោះ ប៉េជុយ ជីបសែ។

សៈ ប៉េជុយ ជីបសែ អ៊ីចឹងពិតមែនទេ?

ឆៈ បាទ លោកប្រធាន ឈ្មោះ ប៉េជុយ ជីបសែ ពិតប្រាកដ។

សៈ បាទ អរគុណ។ លោក ជីបសែ តើលោកមានអាយុប៉ុន្មានឆ្នាំ?

ឆៈ បាទ ខ្ញុំមានអាយុ៥៨ឆ្នាំហើយ។

សៈ បាទ អរគុណ។ ហើយតើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណាដែរ?

ឆៈ បាទ ខ្ញុំសព្វថ្ងៃនៅក្នុងភូមិថ្មី ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប។

សៈ បាទ អរគុណ។ ហើយលោក ជីបសែ តើសព្វថ្ងៃលោកប្រកបមុខរបររកស៊ីធ្វើអ្វី?

ឆៈ បាទ ខ្ញុំសព្វថ្ងៃជាគ្រូបង្រៀននៅសាលាបឋមសិក្សា គីឡូតាឈឹម ក្នុងឃុំគោកធ្លកក្រោមដដែល។

សៈ បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោក គាត់ឈ្មោះអី?

ឆៈ បាទ ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ឆេង ជុយ សព្វថ្ងៃគាត់អនិច្ចកម្មទៅហើយ។

សៈ បាទ អរគុណ។ ចុះម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

ឆៈ បាទ ម្ដាយបង្កើតរបស់ខ្ញុំឈ្មោះ តែ ហៀក សព្វថ្ងៃក៏គាត់អនិច្ចកម្មដែរ។

សៈ បាទ អរគុណ។ ហើយតើលោកអាចប្រាប់ឈ្មោះប្រពន្ធរបស់លោកបានដែរទេ? ហើយនិងកូនរបស់លោក តើកូនរបស់លោកហ្នឹងមានចំនួនប៉ុន្មាន?

[១១:៣៨:៤៥]

ឆៈ បាទ ខ្ញុំមានប្រពន្ធឈ្មោះ កៅ ម៉េងអ៊ី សព្វថ្ងៃមានកូនចំនួនបីនាក់ ក្នុងនោះមានស្រីពីរនាក់ប្រុសមួយនាក់បាទ។

សៈ បាទ អរគុណ។ លោក ជីបសែ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការព្រឹកមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវទទួលយកធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដី០០២ នេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរ គឺលោក នួន ជា, លោក អៀង សារី, និងលោក ខៀវ សំផន តើពិតមែនដែរទេ?

ឆៈ បាទ លោកប្រធាន គឺថាខ្ញុំមិនមានជាប់ពាក់ព័ន្ធដូចសេចក្ដីរាយការណ៍របស់លោកប្រធានពិតមែន។

**ស៖** ហើយសេចក្ដីរាយការណ៍ដដែលនោះបានរាយការណ៍ថា លោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកនៅពីខាងមុខសាលសវនាការនេះរួចហើយ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានស្បថចំពោះលោកតាដំបងដែកនោះ ពិតប្រាកដមែន។

**ស៖** បាទ អរគុណ។ លោក ជឹបសែ ក្នុងនាមលោកជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះហើយ ដែលនាំឲ្យលោកនឹងត្រូវទទួលរងនូវការចោទប្រកាន់។ ហើយទន្ទឹមនោះដែរ គឺថាលោកករណីយកិច្ចក្នុងនាមជាសាក្សីត្រូវតែផ្ដល់ៗ ក្នុងកិច្ចផ្ដល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយ ដែលសួរលោកដោយភាគី ឬដោយអង្គជំនុំជម្រះ។ លើកលែងតែក្នុងករណីដែលឆ្លើយតបទៅនឹងសំណួរឬអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចដែលសិទ្ធិរបស់លោក ដែលអង្គជំនុំជម្រះបានជម្រាបជូនអម្បាញ់មិញនេះ។

[១១:៤១:១១]

លោកជាសាក្សីត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលខ្លួនបានឃើញ បានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ លោក ជឹបសែ តើលោកដែលធ្លាប់បានផ្ដល់កិច្ចសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ក្នុងរយៈពេលកន្លងមក?

**ឆ៖** បាទ លោកប្រធាន ខ្ញុំបានធ្លាប់សម្ភាសជាមួយអ្នកដែលយកព័ត៌មាន ចុះទៅសម្ភាសជាមួយរូបខ្ញុំហ្នឹង គឺបានសម្ភាសរួចហើយ។

**ស៖** ធ្វើប៉ុន្មានដងដែរ? ហើយធ្វើនៅកន្លែងណាសាក្សី? ឈប់ៗ កុំអាលទាន់--

**ឆ៖** បាទ ទី១ គឺខ្ញុំបានសម្ភាសនៅក្នុងវត្តថ្មី ក្នុងភូមិគោកធ្លកក្រោមនោះម្ដង ហើយបន្ទាប់មកគឺនៅសាលារៀនខ្ញុំផ្ទាល់ នៅឯសាលាគីឡូតាឈឹម នោះ។ អានេះ គឺលើកទី២។

**ស៖** អ៊ីចឹង លោកផ្ដល់សក្ខីកម្មនោះ ពីរដង ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ អ៊ីចឹងពិតមែនដែរទេ?

**ឆ៖** បាទ លោកប្រធាន គឺថាចំនួនពីរដងពិតប្រាកដមែន។

[១១:៤៣:១០]

**ស៖** ធ្វើដាច់ដោយឡែកពីគ្នា ហើយមានគម្លាតពេលគ្នាប៉ុន្មានដែរ ពីលើកទី១ មកធ្វើលើកទី២?

**ឆ៖** លោកប្រធាន ចំពោះពេលដែលដាច់រយៈប៉ុន្មានថ្ងៃ គឺខ្ញុំអត់ចាំទេ។ ប៉ុន្តែចាំតែលើកទី១ នៅវត្តថ្មី ហើយលើកទី២ នៅសាលាបឋមសិក្សាគីឡូ តាឈឹម តែម្តង។

**ស៖** អរគុណ ហើយលោកចាំថា នៅពេលណាទេ នៅវត្ត ពេលដែលធ្វើនៅវត្តលើកទី១ហ្នឹង នៅពេលណា? ខែណា? ឆ្នាំណា ក៏បានដែរ? ហើយលើកទី២ នៅខែណា? ឆ្នាំណា?

**ឆ៖** លោកប្រធាន គឺខ្ញុំចាំតែឆ្នាំទេ គឺនៅឆ្នាំ២០០៨ ត្រង់ថ្ងៃខែហ្នឹង អត់ចាំបានទេ លោកប្រធាន។

**ស៖** បាទ អរគុណណាស់ ហើយនៅមុនពេលចូលមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុស្តាប់ចម្លើយដែលលោកបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេតកន្លង ដើម្បីរំឭកការចងចាំដែរឬទេ?

[១១:៤៤:៣០]

**ឆ៖** បាទ ខ្ញុំបានមើលនូវសំណួរចម្លើយដែលបានសម្ភាសជាមួយនឹងអ្នកយកព័ត៌មានហ្នឹង បានគ្រប់គ្រាន់ហើយលោកប្រធាន។

**ស៖** បាទ អរគុណណាស់ ហើយបើតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ ថាតើលោកអាចបញ្ជាក់បានដែរឬទេ? តើថាកំណត់ហេតុដែលស្តាប់សក្ខីកម្មលោក ដែលលោកបានអាន ដើម្បីរំឭកការចងចាំនេះ គឺពិតជាត្រឹមត្រូវ ឬក៏សមស្រប ស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្តល់សក្ខីកម្មជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតកន្លងមកដែរឬទេ?

**ឆ៖** បាទ លោកគឺថាសំណួរ-ចម្លើយដែលខាងចៅក្រមស៊ើបអង្កេតសួរមកខ្ញុំនោះ គឺថាត្រឹមត្រូវទាំងអស់ អត់មានកន្លែងណាដែលមិនច្បាស់លាស់ទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ហើយថ្ងៃនេះ លោកមានមេធាវីប្រឹក្សា។ ហើយលោកមេធាវីប្រឹក្សាអាចផ្តល់ឈ្មោះដល់អង្គសវនាការបានដែរឬទេ? តើលោកឈ្មោះអី ហើយអត្តលេខប៉ុន្មាននៅក្នុងគណៈមេធាវី?

**លោក មឿន សុវណ្ណ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំបាទឈ្មោះ មឿន សុវណ្ណ ជាសមាជិកគណៈមេធាវីមានអត្តលេខ៥៦១។

[១១:៤៦:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបជូនសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់ជូនវេទិកាទៅតំណាងសហព្រះរាជ-អាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់តំណាងសហព្រះរាជអាជ្ញា និងភាគីដែលពាក់ព័ន្ធបានជ្រាបផងដែរថា នៅក្នុងកិច្ចដំណើរការសវនាការចំពោះសាក្សីនេះ គឺសូមកម្រិតនូវការអនុវត្តនូវគោលនយោបាយនៃការជម្លៀសទូទៅហើយនិងពាក់ព័ន្ធសំខាន់ទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន ពីព្រោះជៀសវាងនូវការសួរដេញដោលឯណាចេញផុតពីរង្វង់នេះ វានឹងអាចឈានចូលទៅដល់ក្រៅអង្គហេតុ គឺក្រៅអង្គហេតុដែលមិនបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ ដែលយើងកំណត់ធ្វើសវនាការ។ នេះសូមមានការចំណាប់អារម្មណ៍។

បាទ សូមអញ្ជើញ!

[១១:៤៧:២៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងសួស្តីភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ ហើយនិងលោកសាក្សីផងដែរ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទ សួស្តីលោក ជីបសែ។ ខ្ញុំមានសំណួរមួយចំនួនចង់ឲ្យលោកជួយបញ្ជាក់ ជាពិសេសបើពិនិត្យទៅលើបទសម្ភាសន៍របស់លោក ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានឯកសារលេខ D125/127 ត្រង់ ERN ជាភាសាខ្មែរ គឺ 00224051, និងERN ជាភាសាអង់គ្លេសគឺ 00225210, ជាភាសាបារាំងគឺ 00239976។

**លោក សេង ប៊ុនឃាង៖**

មិនដឹងថាលោកមានឯកសារហ្នឹងហើយឬនៅទេ? បើសិនជាមិនទាន់មានទេ សូមអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ឯកសារនេះជូនទៅសាក្សីផង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជ-អាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

[១១:៤៨:៥៩]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី នៅក្នុងឯកសារហ្នឹងដែលនៅត្រង់ទំព័រ ERN ជាភាសាខ្មែរ លោកបើកមើលទៅឃើញនៅត្រង់ ERN ជាភាសាខ្មែរហ្នឹង គឺទំព័រ 00224051 ដែលនៅក្នុងនោះគឺលោកបានបញ្ជាក់ជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា "លោកបានចូលរួមក្នុងកម្លាំងខ្មែរក្រហម និងហើយបន្ទាប់ -- នៅក្នុងឆ្នាំ១៩៧១ ហើយបន្ទាប់មកទៀត លោកក៏បានធ្វើការនៅមន្ទីរសន្តិសុខពង្រ"។ អ៊ីចឹងសំណួររបស់ខ្ញុំ គឺចង់ឲ្យលោកជួយជម្រាបជូនអង្គសវនាការថា តើលោកបានធ្វើអ្វីខ្លះនៅចន្លោះពីឆ្នាំ១៩៧១នេះ រហូតដល់ពេលដែលលោកធ្វើការនៅមន្ទីរសន្តិសុខពង្រហ្នឹង តើលោកធ្វើអ្វីខ្លះ?

[១១:៥០:០៣]

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ សូមគោរព! គឺសំណួរនេះ ខ្ញុំចង់សូមឲ្យលោកបញ្ជាក់ម្តងទៀត ពីព្រោះស្តាប់មិនទាន់ច្បាស់។

**ស៖** បាទ សំណួរគឺអ៊ីចេះ ចាប់ពីឆ្នាំ១៩៧១ ដែលលោកបានចូលក្នុងបដិវត្តន៍របស់ខ្មែរក្រហម រហូតទៅដល់ពេលដែលលោកចាប់ផ្តើមធ្វើការនៅមន្ទីរសន្តិសុខពង្រនោះ ដែលលោកបានជម្រាបជូនអ្នកស៊ើបអង្កេតហ្នឹង ចង់ដឹងថាចន្លោះពេលនោះ តើលោកធ្វើអ្វីខ្លះ?

**ឆ៖** បាទ ខ្ញុំក៏ស្តាប់សំណួររបស់លោកបានហើយ ដូច្នេះខ្ញុំសូមឆ្លើយ គឺនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយ ប្រហែលជា ៧១ហ្នឹងគឺខ្ញុំក៏បានចូលរួមនៅក្នុងជាមួយថា កងទ័ពខ្មែរក្រហមគឺបាននៅធ្វើការ

ជាមួយ ហើយដល់ពេលដែលឆ្នាំ៧២ ពេលនោះវាមានគឺថាខ្មែរក្រហមវាប្រទាញប្រទង់នៅក្នុងសមរភូមិ គឺថាខ្ញុំកាលនោះគឺនៅក្នុងសមរភូមិតាំងគោក ហើយពេលនោះក៏មានសង្គ្រាមខ្មែរក្រហម គេបានបើកយុទ្ធនាការមួយគេហៅថា “យុទ្ធនាការចេនឡាទី២” ខ្ញុំក៏បានរត់ចេញពីខ្មែរក្រហមទៅនៅផ្ទះវិញ ទៅនៅភូមិឃុំរបស់ខ្ញុំវិញ ហើយភូមិរបស់ខ្ញុំនោះគឺភូមិហៅថាឈ្មោះ ភូមិតាព័រលើ ឃុំពង្រក្រោម ស្រុកជីក្រែង ខេត្តសៀមរាបបាទ។ ដូច្នេះក្នុងចន្លោះដែលខ្ញុំបានចេញពីខ្មែរក្រហម គឺខ្ញុំបានទៅនៅហ្នឹងភូមិស្រុករបស់ខ្លួនវិញ។ ដូច្នេះបើខ្ញុំឆ្លើយមិនទាន់គ្រប់គ្រាន់ សូមលោកសួរសំណួរមកតទៅទៀត។

[១១:៥២:៤៨]

**ស៖** បាទ អរគុណ។ ហើយនៅក្នុងឯកសារដដែលនេះដែរ គឺឯកសារ D125/127 ត្រង់ ERN ជាភាសាខ្មែរគឺ 00224051, ជាភាសាអង់គ្លេសគឺ 00225210, ហើយនិងជាភាសាបារាំង 00234976។ លោកក៏បានបញ្ជាក់ដែរថានៅក្នុងឆ្នាំ១៩៧៤ មានការសម្លាប់មនុស្សច្រើនណាស់ ដោយគេចោទថាជាចោរព្រៃ មានទាំងកុមារ និងស្ត្រីជាដើម។ អ៊ីចឹងចង់ដឹងថា តើនរណាគេជាអ្នកចោទមនុស្សទាំងនេះថាជាចោរព្រៃ លោកអាចជម្រាបជូនអង្គសវនាការបានដែរទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយសំណួររបស់លោក គឺថាអ្នកដែលចោទគឺ មានតែថ្នាក់ដូចថាចៅហ្វាយស្រុកខ្មែរក្រហមហ្នឹងដែលចោទទៅលើប្រជាជនដែលថាធ្វើចោរព្រៃ ហើយបានឱ្យកម្លាំងខាងពួកសន្តិសុខខ្ញុំហ្នឹង គឺទៅចាប់ប្រជាជនដែលចោរព្រៃហ្នឹងមកឃុំឃាំង។ គឺថាមានតែពួកថ្នាក់លើខ្មែរក្រហមហ្នឹងហើយដែលចោទប្រកាន់។ ហើយបញ្ជាទៅថ្នាក់ក្រោមឱ្យចាប់ជនទាំងនោះបញ្ជូនទៅកន្លែងមន្ទីរឃុំឃាំង។

[១១:៥៤:៤០]

**ស៖** បាទ អរគុណ។ តើលោកអាចបញ្ជាក់ឱ្យច្បាស់ជាងនេះបន្តិចបានទេថា អ្នកដែលគេចោទថាជាចោរព្រៃហ្នឹង គេ -- អ្នកហ្នឹងគេសំដៅទៅលើមនុស្សប្រភេទម៉េចដែរ?

**ឆ៖** បាទ លោក ចំពោះថ្នាក់លើ -- ខ្មែរក្រហមដែលចោទថា ចោរព្រៃហ្នឹងគឺថា ដោយសារនៅឆ្នាំ១៩៧៤ហ្នឹង គឺមានការរើបម្រះពីប្រជាជនប្រឆាំងជាមួយខ្មែរក្រហម បានរត់ទៅនៅក្នុងព្រៃ ហើយពួកប្រជាជននោះគឺ ទាក់ទងជាមួយនឹងខាង លន់ នល់ ហើយពួក លន់ នល់ ទាក់ទងជាមួយពួកប្រជាជនដែលធ្វើចោរព្រៃហ្នឹង តាមរយៈដូចថា ឧទ្ធម្ភាគចក្រមកដឹកពីក្នុងព្រៃនោះឯងទៅតំបន់វា ដូចជាថា សៀមរាបហ្នឹងគឺ ដឹកតាមឧទ្ធម្ភាគចក្រចុះមកយក ហើយយកទៅសៀមរាបរួច បានបំពាក់បំប៉នរួច

បានយកមកទម្លាក់ប្រជាជន ដែលវាបំពាក់បំប៉នបាននោះ គឺមកកន្លែងព្រៃនោះវិញ។ ដូច្នេះខ្មែរក្រហមក៏ចោទពួកទាំងនោះ ថាបានចូលដៃចូលជើងជាមួយ លន់ នល់ ដូច្នេះក៏ចោទថា ចោរព្រៃទៅ។

[១១:៥៦:១៥]

**ស៖** បាទ អរគុណ។ នៅក្នុងបទសម្ភាសន៍នេះដែរដដែលគឺ ក៏មានការរៀបរាប់អំពីព្រឹត្តិការណ៍ផ្សេងៗ ដែលទាក់ទងទៅនឹងការជម្លៀសនៅសៀមរាប នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងការគ្រប់គ្រងទាហាន និងអ្នករដ្ឋការនៃរបប លន់ នល់ ផងដែរ។ ឥឡូវ ខ្ញុំសូមសួរសំណួរមួយចំនួនទាក់ទងនឹងបញ្ហានេះ ថាតើនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហ្នឹង លោករស់នៅកន្លែងណាដែរ?

**ឆ៖** បាទ លោកនៅក្នុងថ្ងៃ១៧ មេសា ១៩៧៥ ហ្នឹងគឺខ្ញុំនៅជាមួយ -- នៅកន្លែងសន្តិសុខពង្រហ្នឹងគឺ ខ្ញុំមិនទាន់ចេញពីកន្លែងខ្មែរក្រហមទេ គឺទៅធ្វើការជាមួយវាហ្នឹង កន្លែងសន្តិសុខពង្រហ្នឹង។

**ស៖** ចុះលោកដឹងទេថា ប្រជាជននៅខេត្តសៀមរាបហ្នឹងគេ ត្រូវបានគេជម្លៀសនៅពេលណាដែរ? លោកមាននៅចាំទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

[១១:៥៧:៥៧]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ការតាំងសំណួរនេះ ជាពិសេសការជម្លៀសប្រជាជនសៀមរាប វាមិនមែនជាផ្នែកនៃសំណុំរឿង០០២/០១ នោះទេ ហើយប្រសិនបើសាក្សីដឹងអំពីការជម្លៀសប្រជាជនភ្នំពេញនោះ គឺសាក្សីអាចឆ្លើយបាន ព្រះរាជអាជ្ញាអាចសួរបាន ហើយប្រសិនបើសួរអំពីការជម្លៀសប្រជាជននៅសៀមរាបនោះ គឺមិនមែនជាផ្នែកនៃសំណុំរឿង០០២/០១ នោះទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ មានហេតុផលចំនួនពីរ។ ហេតុអ្វីបានជាការជម្លៀសប្រជាជនសៀមរាប គឺជាបញ្ហាដែលអង្គជំនុំជម្រះនោះ គួរតែស្តាប់ភស្តុតាង។ ទី១ គឺពាក់ព័ន្ធទៅនឹងភស្តុតាងនៃការអនុវត្តគោលនយោបាយនៃការជម្លៀសប្រជាជន ដែលអនុវត្តដោយខ្មែរក្រហម។ តុលាការបានស្តាប់ភស្តុតាង ពាក់ព័ន្ធទៅនឹងសាក្សីមួយចំនួន ស្តីអំពីការជម្លៀសប្រជាជនកំពត និងតាកែវ និងខេត្តផ្សេងៗទៀត។ ហេតុផលទី២ នោះគឺថា បន្ទុកនៃការបង្ហាញភស្តុតាងរបស់សហព្រះ

រាជអាជ្ញា គឺត្រូវបង្ហាញថា មានការអនុវត្តជាលក្ខណៈប្រព័ន្ធ និងទូលំទូលាយ នៃការជម្លៀសប្រជាជន ដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ។

ដូច្នេះ ដើម្បីជាភស្តុតាងនោះគឺថា យើងត្រូវតែបង្ហាញថា ទីក្រុង និងខេត្តនោះ ត្រូវបានជម្លៀសប្រជាជន។ យើងមិនបានស្តាប់ឮសាក្សីមួយចំនួន និយាយអំពីបញ្ហានេះ ក៏ប៉ុន្តែសាក្សីទាំងឡាយ គឺគាត់លើកឡើងអំពីការជម្លៀសទីរួមខេត្តនានា ដូចជាខេត្តសៀមរាប។ ដូច្នេះ ហើយវាពាក់ព័ន្ធទៅនឹងរឿងក្តីយើងយ៉ាងជាក់ស្តែង និងពិតប្រាកដ។

[១១:៥៩:៥២]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០០:១០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា មិនសមស្របទេ។ អង្គជំនុំជម្រះបានជម្រាបជូនហើយ តាមការពិចារណាឃើញថា បញ្ហានៃការដឹងរបស់សាក្សីរូបនេះ វាទាក់ទិនជាមួយការអនុវត្តគោលនយោបាយទូទៅ ស្តីពីការជម្លៀសរបស់កម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះ សម្រេចកំណត់យកសាក្សីនេះមកផ្តល់សក្ខីកម្ម។

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរនេះ ប្រសិនបើលោកនៅចងចាំ! បើមិនចងចាំទេ លោកអាចសុំឱ្យតំណាងសហព្រះរាជអាជ្ញា តាំងសំណួរសាជាថ្មីចំពោះលោកម្តងទៀត។

**លោក ប៉េជុយ ដឹបសែះ**

បាទ ខ្ញុំអម្បាញ់មិញហ្នឹង មិនបានស្តាប់លោកប្រធាននិយាយច្បាស់លាស់ សូមលោកប្រធានមានប្រសាសន៍ម្តងទៀត។

**ប្រធានអង្គជំនុំ៖**

បាន សេចក្តីថា លោកមិនចាំនូវសំណួរ ដែលសួរឡើងដោយសហព្រះរាជអាជ្ញាជាតិទេ។ អ៊ីចឹងអង្គជំនុំជម្រះឲ្យ តម្រូវឱ្យតំណាងសហព្រះរាជអាជ្ញាជាតិ តាំងសំណួរចុងក្រោយ ដែលលោកសួរដោយ -- សួរទៅសាក្សីហ្នឹងសាជាថ្មីម្តងទៀត ពីព្រោះគាត់ទំនងជាភ្លេចហើយ នូវសំណួររបស់លោក។

[១២:០១:៤០]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សំណួររបស់ខ្ញុំគឺចង់ដឹងថា តើប្រជាជននៅខេត្តសៀមរាបហ្នឹង ត្រូវបានគេជម្លៀសនៅពេលណាដែរ? លោកនៅចាំទេ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ខ្ញុំនៅចាំបានថា ប្រជាជននៅខេត្តសៀមរាបនេះ ជម្លៀសនៅក្រោយថ្ងៃ១៧ មេសា ១៩៧៥ ដូចនៅភ្នំពេញដែរ ជម្លៀសដូចគ្នា។

**ស៖** បាទ ចុះលោកដឹងទេថា ប្រជាជនដែលគេជម្លៀសនុំង គេជម្លៀសទៅណាដែរ? លោកមានដឹងទេ?

**ឆ៖** បាទ ខ្ញុំដឹងច្បាស់ថា ការជម្លៀសប្រជាជននៅសៀមរាបហ្នឹងគឺថា ផ្នែកប្រជាជនគឺមកតាមជនបទស្រុកស្រែ ឯអ្នករដ្ឋការ ទាហានអីគឺថា វាយកមកដាក់នៅកន្លែងសំណង់ចាស់ៗនៅកំពង់ក្ដីហ្នឹងគឺ យកមកបម្រុងដើម្បីសម្លាប់។

[១២:០៣:១០]

**ស៖** បាទ អរគុណ។ ចុះលោកមានដឹងទេថា មានដូចជាកម្មាភិបាល នៅក្នុងតំបន់របស់លោកហ្នឹង មានបានផ្ដល់សេចក្ដីណែនាំអ្វីខ្លះទាក់ទងទៅនឹងការជម្លៀសចេញពីសៀមរាបនេះ ហើយថាតើត្រូវចាត់ចែងយ៉ាងណា ចំពោះអ្នកដែលត្រូវគេជម្លៀសនេះ?

**ឆ៖** បាទ លោក ចំពោះបញ្ហាជម្លៀសទាហាន និងអ្នករដ្ឋការមកកន្លែងនៅទីរួមស្រុកជីក្រែងគេហៅ កំពង់ក្ដីហ្នឹង គឺខាងសន្តិសុខពង្រហ្នឹង មិនបានគ្រប់គ្រងលើពួកហ្នឹងទេ ប៉ុន្តែគ្រាន់តែដឹងថា វាជម្លៀសមកចំនួនច្រើន ហើយទ័ពខ្មែរក្រហមហ្នឹង វាការពារអ្នកទាំងនោះ រួចហើយក៏វាក្រោយពីសួរនាំនោះគឺថា ការសួរនាំនោះគឺខាងសន្តិសុខហ្នឹងក៏ មិនបានជាអ្នកទទួលដែរគឺ វាមានអ្នកសួរផ្សេង ហើយក្រោយមកក៏វាដឹកឡានទាំងអ្នក -- ទាំងឪពុកម្ដាយ ដែលធ្វើទាហានអ្នករដ្ឋការហ្នឹង យកទៅសម្លាប់តែម្ដង ហើយខាងសន្តិសុខពង្រនោះ គ្រាន់តែវាឲ្យមនុស្សមកធ្វើឃាតចំពោះទាហានរដ្ឋការនោះឯង។ គឺខ្ញុំបានដឹងត្រឹមប៉ុណ្ណឹងហើយ គឺខាង -- សូមគោរពលោកប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ មុននេះបន្តិចឮលោកនិយាយថា មានពាក្យថា “អ្នករដ្ឋការ” តើលោកអាច

បញ្ជាក់បានទេថា "អ្នករដ្ឋការ" -- លោកៗមុននេះបន្តិចបានបញ្ជាក់ថា មានអ្នករដ្ឋការ និងទាហាន។ តើលោកអាចបញ្ជាក់បានទេថា អ្នករដ្ឋការ និង ទាហានហ្នឹង ជាមនុស្សរបស់ខាងណាដែរ?

[១២:០៥:២៨]

**ឆ៖** បាទ លោកអ្នករដ្ឋការ និងទាហាន ហ្នឹងគឺនៅខាងគេហៅថា របប លន់ នល់ ដែលពួកខ្មែរក្រហមវាប្រុងយកមកធ្វើ -- មកសម្លាប់ហ្នឹង គឺសុទ្ធតែពួកខាង លន់ នល់ ថាពួកវាតែងនិយាយថា ពួក លន់ នល់ អីចឹង។ ដូច្នេះហើយវាយកមកដើម្បីសម្លាប់អ្នករដ្ឋការ ហើយនិងទាហាន។ ទាហានហ្នឹងវាមានទាំងប្រពន្ធ មានទាំងកូនមកជាមួយផង ដែលមកនៅវាជម្លៀសមកដាក់នៅសំណង់ចាស់ៗនៅផ្សារកំពង់ក្ដីហ្នឹង។ ឃើញកូនចៅហ្នឹងរត់លេងប្រសាច ដែលវាយកមកហ្នឹង។

**ស៖** បាទ អរគុណ។ បើពិនិត្យទៅលើអត្ថបទសម្ភាសរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺលោកបានបញ្ជាក់ថា "ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញគេជម្លៀសទាហាន និងអតីតអ្នករដ្ឋការ លន់ នល់ ពីខេត្តសៀមរាបមកដាក់នៅតាមផ្ទះចាស់ៗនៅផ្សារជីក្រែង ដោយមានការយាមកាមទាំងយប់ទាំងថ្ងៃផង"។ ឯកសារនោះគឺ D125/127, ត្រង់ ERN ជាភាសាខ្មែរគឺ 00224051, ជាភាសាអង់គ្លេសគឺ 00225210, ជាភាសាបារាំងគឺ 00239976។ អីចឹងចង់ឲ្យលោកជួយបញ្ជាក់មើលថា តើផ្សារជីក្រែងហ្នឹង មានទីតាំងនៅកន្លែងណាដែរ? ឆ្ងាយពីមន្ទីរសន្តិសុខពង្រ ដែលលោកធ្វើការនោះដែរទេ?

[១២:០៧:៣៨]

**ឆ៖** បាទ លោកចំពោះផ្សារកំពង់ក្ដីហ្នឹងគឺ ស្ថិតនៅក្នុងស្រុកជីក្រែង ហើយចម្ងាយពីកន្លែងផ្សារទៅដល់កន្លែងសន្តិសុខហ្នឹង ប្រហែលជា៧គីឡូ ថា៦គីឡូជាង ៧គីឡូទៅ។ ៧គីឡូ បានដល់កន្លែងសន្តិសុខនោះ។

**ប្រធានអង្គជំនុំ៖**

បានហើយ ឥឡូវដល់ពេលសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ បាទ អរគុណលោកសាក្សី ឥឡូវនេះក៏ដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយ សាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នក

ជំនាញដល់សាក្សីរូបនេះ សម្រាកនៅក្នុងអំឡុងពេលពិសាអាហារថ្ងៃត្រង់ ព្រមជាមួយនឹងមេធាវីប្រឹក្សារបស់គាត់ផង។ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរ អ៊ំ ! ទៅបន្ទប់រង់ចាំនៅខាងក្រោមវិញ ហើយនិងឲ្យនៅរសៀលនេះ ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៩ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សីមុនពេលឈប់សម្រាក លោកបានជម្រាបជូនអង្គសវនាការថា "ផ្សារកំពង់ក្តីហ្នឹងមានចម្ងាយប្រហែលជា៧គីឡូម៉ែត្រ ពីមន្ទីរសន្តិសុខពង្រ"។ តើលោកឧស្សាហ៍ទៅផ្សារកំពង់ក្តីហ្នឹងដែរទេនៅពេលនោះ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ដែលមកផ្សារកំពង់ក្តីហ្នឹង មកដោយសារពេលណាដែលគេឲ្យខ្ញុំមកម្តងម្កាល មិន

មែនថា មកញឹកទេគឺ តាមការចាត់តាំងរបស់ប្រធានសន្តិសុខឱ្យមក។

[១៣:៣៤:៤៤]

**ស៖** បាទ អរគុណ។ ចុះប្រធានសន្តិសុខចាត់តាំងឱ្យលោកទៅផ្សារកំពង់ក្តីហ្នឹង ចាត់តាំងឱ្យទៅធ្វើអ្វីនៅទីនុ៎ង?

**ឆ៖** ដែលឱ្យខ្ញុំមកផ្សារកំពង់ក្តីហ្នឹង ដើម្បីមកសួររកអ្នកដែលត្រូវនាំយកទៅកន្លែងៗសន្តិសុខហ្នឹង គឺថា នាំអ្នកដែលមានទោសនោះទៅកន្លែងហ្នឹង ឱ្យខ្ញុំមក។ ប៉ុន្តែមកហ្នឹងគឺថា មកជាមួយបុគ្គលិកដែលនៅធ្វើការ មិនមែនមកតែឯងទេ គឺមកជាមួយពួកសន្តិសុខគ្នាឯង។

**ស៖** បាទ អរគុណ។ ចុះតួនាទីដែលថ្នាក់លើប្រធានរបស់លោក ឱ្យមកនាំអ្នកជាប់ឃុំទៅសន្តិសុខហ្នឹងតើអ្នកជាប់ឃុំនៅទីនោះ មានជាជនប្រភេទណាខ្លះដែលជាប់នៅផ្សារកំពង់ក្តីហ្នឹង?

**ឆ៖** បាទ លោកចំពោះអ្នកដែលមានទោសត្រូវចូលទៅកន្លែងសន្តិសុខពង្រហ្នឹងគឺ ភាគច្រើនជាអ្នកទោសខុសសីលធម៌រវាងយុវជន នារី គឺថាបានយកទៅកន្លែងនោះ។ ចំពោះអ្នកដែលទោសដែលជម្លៀសមកពីខាងសៀមរាបអ្នកជម្លៀសទាហានរដ្ឋការនោះគឺ មិនបានយកទៅកន្លែងសន្តិសុខនោះទេ គឺយកអ្នកដែលខុសសីលធម៌។

[១៣:៣៦:៥២]

**ស៖** បាទ អរគុណ។ តើលោកអាចបញ្ជាក់ឱ្យច្បាស់ថែមទៀតទេថា អ្នកដែលជាអ្នករដ្ឋការ ឬក៏អ្នកទាហាន នៃរបបមុនហ្នឹងគេយកទៅឃុំ នៅកន្លែងណាឱ្យច្បាស់លាស់?

**ឆ៖** បាទ លោកចំពោះការដែលអ្នកមន្ត្រីរដ្ឋការ លន់ នល់ ឬទាហាន ដែលវាជម្លៀសមកដាក់នៅកំពង់ក្តីហ្នឹង គឺអត់មានយកទៅឃុំឃាំងអីទេ គឺវាយកមករួចសួរនាំ គឺថាក្រុមប៉ែកផ្សេងពីខាងសន្តិសុខទេ ប៉ុន្តែគឺបន្ទាប់ពីនោះ គឺដឹកឡានយកទៅសម្លាប់តែម្តង។ អត់មានចូលទៅសន្តិសុខរបស់ពង្រទេ អត់មានទេ។

**ស៖** បាទ អរគុណ។ ចុះតើលោកអាចបញ្ជាក់បានទេថា ហេតុអីបានជាលោកដឹងថា អ្នកទាំងនោះជា អ្នករដ្ឋការ ឬក៏ទាហាន នៃរបប លន់ នល់?

**ឆ៖** បាទលោក ត្រង់ចំណុចនេះគឺថា មិនពិបាកនេះទេគឺថា ប្រជាជនដែលខ្ញុំមកហ្នឹងគឺគេនិយាយប្រាប់ទៅគឺខ្ញុំបានដឹង តាមរយៈប្រជាជនមូលដ្ឋាន តាមភូមិគេប្រាប់ថា ពួកខ្មែរក្រហមបានជម្លៀសទាហានថ្នាក់សុទ្ធតែថ្នាក់ធំៗមកដាក់កំពង់ក្តីហើយ ហើយមានទាំងមន្ត្រីរដ្ឋការថ្នាក់ធំៗទៀតមក

ហើយខ្ញុំឮសួរ ខ្ញុំពេលមកដល់កំពង់ក្តីហ្នឹងគឺថា មិនបានចូលកន្លែងវាទេគឺថា ខ្ញុំនៅនោះឃើញទាហានខ្មែរក្រហមវាដើរៗការពារ អាហ្នឹងគឺថា បានឃើញជាក់ស្តែង ហើយវាបាញ់កាំភ្លើងទៅលើដើម្បីកុំឲ្យមានអ្នកណា ដែលអាចចេញពីរង្វង់ អាកន្លែងដែលវាការពារហ្នឹងបាន។ ហ្នឹងគឺដឹងតាមរយៈប្រជាជន។

[១៣:៣៩:២៩]

**ស៖** បាទ អរគុណ។ ដូចដែលខ្ញុំបានអាននូវកំណត់ហេតុយកចម្លើយ -- កំណត់ហេតុស្ដួរចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត រួចហើយថាដែលលោកបានឡើងថា "អ្នករដ្ឋការ និងទាហាន លន់ នល់ ត្រូវបានឃុំខ្លួននៅផ្សារកំពង់ក្តី ឬផ្សារជីក្រែងហ្នឹង ហើយមានការឃាមកាមទាំងយប់ទាំងថ្ងៃ"។ តើលោកដឹងទេថា នរណាខ្លះដែលគេចាត់ឲ្យទៅឃាមនៅទីនោះ?

**ឆ៖** បាទលោក ចំពោះអ្នកដែលទៅឃាមកន្លែងនុ៎ង គឺចំពោះខ្ញុំអត់ដឹងទេ ពីព្រោះទាហានខ្មែរក្រហមហ្នឹង គឺខ្ញុំមិនដឹងជាអង្គភាពណាអីមកពីខាងណាទេ គ្រាន់តែបានឃើញ ហើយនិងឮពីប្រជាជនដែលជិតៗនោះប្រាប់ខ្ញុំ បាទ។

**ស៖** បាទ អរគុណ។ យោងទៅតាមបទសម្ភាសន៍របស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដដែលហ្នឹង គឺលោកបានបញ្ជាក់ថា "អ្នកទាំងនោះ គឺជានាយទាហានអតីតរដ្ឋការ លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ ដែលគេជម្លៀសចេញពីខេត្តសៀមរាប ហើយគេដឹកយកទៅសម្លាប់ ដោយប្រាប់ថាយកទៅរៀន តែតាមពិតគេដឹកយកទៅសម្លាប់។ អ្នកទាំងនោះមានចំនួនរាប់រយនាក់ ព្រោះគេដឹកយកទៅសម្លាប់ជាច្រើនថ្ងៃ។ អ្នកដែលសម្លាប់ពួកគេ គឺជាពួកសន្តិសុខនៅពង្រ ដោយគេដឹកយកទៅសម្លាប់នៅកន្លែងផ្សេង។ ខ្ញុំឮថា គេយកអ្នកទាំងនោះទៅសម្លាប់នៅម្កាក់"។ ដើម្បីប្រតិចារឹក ឯកសារនេះគឺឯកសារលេខ D125/127 ត្រង់ ERN ជាភាសាខ្មែរគឺ 00224051, ជាភាសាអង់គ្លេសគឺ 00225210 ដល់ 11 និងជាភាសាបារាំងគឺ 00239976។ តើលោកនៅចាំបានទេថា រយៈពេលប៉ុន្មានថ្ងៃដែលគេដឹកយកទៅសម្លាប់អ្នករដ្ឋការ និងទាហាន លន់ នល់ទាំងអស់នោះ?

[១៣:៤២:១៨]

**ឆ៖** បាទលោកត្រង់ទៅ គឺខ្ញុំមិនអាចបញ្ជាក់ចំនួនថ្ងៃបានទេ ដោយខ្ញុំមិនបានចាំ គឺចំនួន -- ចាំថ្ងៃដែលវាសម្លាប់ប៉ុន្មានថ្ងៃអស់នោះទេ មិនចាំទេ។

**សៈ** ចុះការសម្លាប់ហ្នឹង សម្លាប់រួមទាំងប្រពន្ធកូនរបស់អ្នករដ្ឋការ និងទាហាននោះដែរ ឬក៏យ៉ាងណាដែរ?

**ឆៈ** ខ្ញុំសូមប្រាប់លោកថា វាសម្លាប់ទាំងអស់ អត់មានថាទុកប្រពន្ធ ទុកកូន គឺថាជម្លៀសមកទាំងប៉ុន្មានហ្នឹង គឺវាយកទៅទាំងអស់ ដឹកឡានទៅសម្លាប់ទាំងអស់។

**សៈ** បាទ អរគុណ។ លោកបានជម្រាបជូនអ្នកស៊ើបអង្កេតនុ៎ងថា អ្នកដែលសម្លាប់ពួកគេហ្នឹង គឺជាសន្តិសុខនៅពង្រ ហើយក៏បានបញ្ជាក់ដែរថា ការសម្លាប់នេះគឺនៅម្កាក់។ សួរថា តើលោកដឹងដោយរបៀបណាដែលថាសន្តិសុខនៅពង្រ ដែលជាអ្នកសម្លាប់អ្នករដ្ឋការ ឬក៏ទាហាន លន់ នល់ និងក្រុមគ្រួសាររបស់គេហ្នឹង តើលោកដឹងដោយរបៀបណាដែរ?

[១៣:៤៣:៥៤]

**ឆៈ** បាទលោក គឺថា ខ្ញុំដឹងដោយពួកហ្នឹងវាៗមកដល់កន្លែងវិញ វានិយាយប្រាប់ខ្ញុំ គឺបានខ្ញុំដឹង។

**សៈ** បាទ អរគុណ។ ចុះការដែលទៅ -- ដែលសម្លាប់នុ៎ងមានតែបុគ្គលិកនៅមន្ទីរសន្តិសុខពង្រហ្នឹង ឬក៏មានអ្នកកម្លាំងរបស់ខ្មែរក្រហមផ្សេងទៀតចូលរួមដែរ?

**ឆៈ** បាទលោក ចំពោះការសម្លាប់ខាង លន់ នល់ ហ្នឹង ទាហាន លន់ នល់ ហ្នឹងគឺមិនមែនមានតែពួកបុគ្គលិកខាងសន្តិសុខហ្នឹងទេ គឺមានពួកទាហានខ្មែរក្រហម ប៉ុន្តែខ្ញុំមិនស្គាល់ថា អង្គភាពណាទេ។

**សៈ** បាទ អរគុណ។ ចុះនៅក្នុងការសម្លាប់ហ្នឹងតើលោកមានដឹងទេថា នរណាគេជាអ្នកចាត់ចែងជាអ្នកគ្រប់គ្រងក្នុងការសម្លាប់ហ្នឹង? លោកនៅចាំទេ?

**ឆៈ** ចំពោះដែលលោកសួរថា អ្នកណាហ្នឹងគឺខ្ញុំវាមិនអាចចាំបានទេ ប៉ុន្តែពួពួកវាថាពួកតំបន់ៗហ្នឹងវារួមជាមួយនឹងបុគ្គលិកសន្តិសុខបីបួននាក់ហ្នឹងឯងជាអ្នកសម្លាប់។ ប៉ុន្តែខ្ញុំក៏មិនដឹងថា តំបន់ហ្នឹងពីណា អីឈ្មោះអី? មេដឹកនាំឈ្មោះអ្វី? គឺខ្ញុំនេះអត់បានដឹងទេ។ អត់បានដឹងឈ្មោះទេ។

**សៈ** បាទ អរគុណ។ ចុះលោកអាចបញ្ជាក់បានទេថា តំបន់ ពួកតំបន់ហ្នឹងតំបន់អីដែរ? តំបន់ខាងណា?

**ឆៈ** បាទ ពួកតំបន់ហ្នឹងខ្ញុំចាំថា វាថាតំបន់សៀមរាប-ឧត្តរមានជ័យ ប៉ុន្តែមិនដឹងជារចនាសម្ព័ន្ធវាយ៉ាងម៉េចគឺ -- ហ្នឹងគឺខ្ញុំមិនដឹងដែរ។ តំបន់វាឈ្មោះតំបន់សៀមរាប-ឧត្តរមានជ័យ។

[១៣:៤៦:៤០]

**ស៖** ចុះទាក់ទងទៅនឹងទីកន្លែងដែលឈ្មោះថាម្កាក់ហ្នឹង តើកន្លែងនោះនៅកន្លែងណា? ហើយម្កាក់ហ្នឹងនៅឆ្ងាយពីមន្ទីរសន្តិសុខពង្រដែរឬទេ?

**ឆ៖** បាទ ម្កាក់នៅឆ្ងាយពីសន្តិសុខពង្រឆ្ងាយ ព្រោះសព្វថ្ងៃគេហៅថាទំនប់ម្កាក់វា ខ្ញុំមិនចាំថាប៉ុន្មានគីឡូពីកន្លែងសន្តិសុខពង្រទេ។ ប៉ុន្តែដឹងថាវាមានចម្ងាយឆ្ងាយ ប្រហែលជាង១០គីឡូ អានេះការស្មានរបស់ខ្ញុំទេ វាមិនអាចជាត្រឹមត្រូវ វាឆ្ងាយពីកន្លែង។

**ស៖** បាទ អរគុណ។ ចុះលោកអាចបញ្ជាក់បានទេថា ទិសពី -- បើប្រៀបធៀបពីមន្ទីរសន្តិសុខពង្រហ្នឹង ទៅខាងម្កាក់ហ្នឹងទិសខាងណាដែរ?

**ឆ៖** បាទ ខ្ញុំអាចដឹងទិសពីសន្តិសុខពង្រទៅអាកន្លែងដែលវាសម្លាប់អ្នកជម្លៀសហ្នឹង គឺទិសពាយ័ព្យៗ វាខាងជើងឆៀងខាងលិច។

[១៣:៤៨:២៧]

**ស៖** បាទ អរគុណ។ ចុះផ្ទាល់ខ្លួនលោក តើលោកធ្លាប់ដែលឃើញអ្នកដែលជម្លៀសនោះត្រូវបានគេដឹកយកទៅសម្លាប់ទេ សម្រាប់ផ្ទាល់ខ្លួនលោកតែម្តង?

**ឆ៖** បាទ សម្រាប់ផ្ទាល់ខ្លួនខ្ញុំគឺអត់បានឃើញវាយកទៅដោយផ្ទាល់ភ្នែកទេ អាហ្នឹងគឺអត់បានឃើញទេ។ គឺខ្ញុំដឹងតាមរយៈដែលពួកដែលចូលរួមទៅសម្លាប់វានិយាយប្រាប់តែម្តងបាទ។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណ។ លោកប្រធានខ្ញុំអស់សំណួរហើយនៅពេលនេះ ហើយសូមឲ្យសហការីខ្ញុំបន្តសំណួរសួរទៅទៀត។ ហើយសូមអរគុណលោកសាក្សីផងដែរ ដែលបានឆ្លើយនឹងសំណួរយ៉ាងក្បោះក្បាយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៣:៤៩:៤៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ឌេល លីសាក់ ហើយខ្ញុំមានសំណួរពីរបីបន្ថែមទៀតសម្រាប់លោកនៅរសៀលថ្ងៃនេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជាដំបូងខ្ញុំសូមចាប់ផ្ដើមដោយបង្ហាញសាក្សីនូវឯកសារមួយទៀតដែលជាឯកសារ D83-Annex 00012។ វាគឺជារបាយការណ៍ដែលមាននូវការសម្ភាសពាក់ព័ន្ធទៅនឹងសាក្សី ដែលធ្វើឡើងនៅខែកក្កដា ឆ្នាំ១៩៨១។ ហើយទំព័រដែលខ្ញុំចង់សាកសួរទៅលើសាក្សី ដោយសារឯកសារនេះវាមានទំហំវែង ដូច្នេះហើយខ្ញុំចង់សូមអនុញ្ញាតដើម្បីចោទសួរទៅលើខ្មែរ ERN 001 -- 00812860 ហើយអង់គ្លេសគឺមាន 00164153, ភាសាបារាំងគឺមានលេខ 00779381។ ខ្ញុំមានឯកសារជាក្រដាសដើម្បីផ្ដល់ជូនទៅដល់សាក្សី។ ដូច្នេះខ្ញុំសូមលោកប្រធានអនុញ្ញាតដើម្បីប្រគល់ទៅដល់សាក្សី ហើយនិងដាក់បញ្ចាំងនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍។ សូមលោកប្រធានអនុញ្ញាត។

[១៣:៥១:២៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ! ហើយនិងអនុញ្ញាតឲ្យដាក់បញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍ និងអេក្រង់កុំព្យូទ័រផងដែរ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ជាដំបូងសូមលោកមើលទៅលើឯកសារ ហើយសំណួរទី១ ដែលខ្ញុំចង់សួរលោក គឺថាតើលោកចាំដែរឬទេ ថាលោកធ្លាប់ត្រូវបានសម្ភាសដោយជនជាតិបារាំងម្នាក់ឈ្មោះ ហង់រី ឡូកា គឺនៅក្នុងឆ្នាំ១៩៨១ ខែកក្កដា នៅសណ្ឋាគារហ្គ្រង់អូតែលសៀមរាប តើលោកធ្លាប់ចាំថាលោកបានធ្លាប់ជួបជាមួយលោក ហង់រី ឡូកា នោះដែរឬទេ? គឺលោក ហង់រី ឡូកា។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា!

[១៣:៥២:៣០]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការជំទាស់ទាក់ទងទៅនឹងបច្ចេកទេស ប៉ុន្តែខ្ញុំគិតថាជាដំបូង

គឺយើងត្រូវតែសួរសាក្សី ថាសាក្សីធ្លាប់ឃើញឯកសារនេះក៏អត់? ប្រសិនបើសាក្សីឆ្លើយថា មិនធ្លាប់ឃើញទេ គឺយើងត្រូវដកឯកសារចេញពីសាក្សី និងដកពីលើអេក្រង់នេះ។ នេះគឺជាអ្វីដែលយើងបានយល់ស្រប ហើយយើងប្រើប្រាស់ជាយូរមកហើយ។ ហេតុដូច្នេះខ្ញុំស្នើសុំឱ្យយើងគោរពទៅតាមគោលការណ៍មួយនេះ។

**លោក ឌេល លីសាក់៖**

លោកប្រធាន នេះគឺជាការប្រកាសដែលមិនត្រឹមត្រូវ ទាក់ទងទៅការអនុវត្ត។ មានករណីជាច្រើនដែលយើងគិតថា វាមិនមែនជារឿងត្រឹមត្រូវ ដែលយើងអនុញ្ញាតឱ្យសាក្សីពិនិត្យទៅលើឯកសារដែលគាត់មិនធ្លាប់ឃើញពីមុនមក។ ស្ថានភាពមួយគឺថា គឺឯកសារដែលមានការសម្ភាសចំពោះសាក្សី។ ហេតុដូច្នេះខ្ញុំគិតថា ជាដំបូងគឺខ្ញុំធ្វើការសាកសួរទៅលើសាក្សីទៅលើបញ្ហាមួយចំនួន ដើម្បីបង្កើតជាមូលដ្ឋានគ្រប់គ្រាន់។ បន្ទាប់មកទៀត ដើម្បីបញ្ជាក់ថាតើការទាំងអស់នេះវាពិតជាបានកើតឡើងពីអតីតកាលឬមួយក៏អត់?

[១៣:៥៣:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ តាមខ្ញុំយល់គឺថា សាក្សីហ្នឹងគឺត្រូវបានទទួលនូវការផ្តល់ឯកសារក្នុងនាមជាសាក្សី។ ដូច្នេះទាំងអស់នេះវាកើតឡើងទៅលើស្ថានភាពមួយដែលថា ពាក់ព័ន្ធដូចគ្នានឹងករណីលោក ហ្វីលីព ស្បូត។ ដូច្នេះខ្ញុំគិតថាឥឡូវនេះយើងកំពុងតែត្រឡប់ទៅរកការប្រើប្រាស់ឯកសាររបស់សាក្សីមួយរូប ដែលនឹងត្រូវមកបង្ហាញ ប៉ុន្តែមិនទាន់មកបង្ហាញសក្ខីកម្មនោះឡើយទេ ហើយយើងយកមកប្រើប្រាស់ជាមួយសាក្សីរូបនេះ។ ប៉ុន្តែយើងចង់ឱ្យមានការបញ្ជាក់ច្បាស់ ថាតើយើងអាចប្រើប្រាស់ ឬក៏អត់ ទាក់ទងនឹងការជំទាស់កាលពីពេលលើកមុន ដែលអង្គជំនុំជម្រះបានសម្រេចរួចទៅហើយ។

[១៣:៥៤:៣៩]

**លោក ឌេល លីសាក់៖**

ដើម្បីបញ្ជាក់ឱ្យច្បាស់ ខ្ញុំនឹងមិនសួរសាក្សីអំពីមតិ ឬមួយក៏សង្កេតណាមួយរបស់លោក ហង់រី

ឡូកា នោះឡើយ។ ខ្ញុំគ្រាន់តែចង់លើកឡើងនូវចម្លើយមួយចំនួនដែលឆ្លើយ ដែលពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ។ គឺទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលយើងអាចបន្តដំណើរទៅមុខ ឧទាហរណ៍ដូចជាកាលមុនយើងសាកសួរជាមួយលោក ភី ភួន ដែលគាត់ត្រូវបានសម្ភាសន៍ដោយលោក ហ្វីលីព ស្បូត ហើយនិងសៀវភៅរបស់លោក ហ្វីលីព ស្បូត។ ដូច្នេះនៅក្នុងស្ថានភាពហ្នឹងគឺជាវាជាការត្រឹមត្រូវដែលយើងអាចសួរសាក្សីអំពីវិធីសាស្ត្រមួយចំនួន។ ដូច្នេះហើយ ខ្ញុំអាចថា ប្រសិនបើខ្ញុំសួរសាក្សីអំពីមតិ ឬក៏ការសន្និដ្ឋានរបស់អ្នកជំនាញ អាហ្នឹងជារឿងមួយផ្សេង។

[១៣:៥៥:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៨:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់លោកមេធាវីការពារក្តី ដែលបានជំទាស់ទៅនឹងការតាំងសំណួរដោយតំណាងសហព្រះរាជអាជ្ញាទៅសាក្សី ដែលការប្រើប្រាស់ឯកសារនេះ។ សេចក្តីជំទាស់ហ្នឹងមិនត្រឹមត្រូវទេ ដោយសារអង្គជំនុំជម្រះបានធ្លាប់សម្រេចរួចហើយករណីដូចគ្នានេះ គឺថាឯកសារនេះបានដកស្រង់នូវចម្លើយរបស់សាក្សីផ្ទាល់នៅក្នុងការធ្វើសម្ភាស។ ដូច្នេះ គឺភាគីអាចលើកយកឯកសាររបៀបនេះ មកសួរដេញដោលចំពោះសាក្សីបាន។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សំណួរទី១របស់ខ្ញុំគឺថា តើលោកចាំថាលោកធ្លាប់ត្រូវបានសម្ភាសន៍ដោយលោក ហង់រី ឡូកា គឺនៅក្នុងខែកក្កដា ឆ្នាំ១៩៩១ នៅក្នុងសណ្ឋាគារ ហ្គ្រង់អូតែល សៀមរាបដែរឬទេ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ខ្ញុំបាទជួបជាមួយលោក ហង់រីឡូកា ហើយសម្ភាសនៅក្នុងសណ្ឋាគារ ហ្គ្រង់អូតែល សៀមរាបមែន គឺថាខ្ញុំពេញចិត្តនឹងលោក ហង់រីឡូកា ណាស់ ដោយសារលោកបាន គឺថានិយាយឲ្យខ្ញុំហ្នឹង គឺរាប់អានលោក គឺហើយខ្ញុំក៏រាយការណ៍តាមសំណួរដែលលោកបានសួរហ្នឹង គឺថាខ្ញុំបានជួបពិតប្រាកដមែន។ ដូច្នេះ លោកព្រះរាជអាជ្ញាដែលថា ហ្នឹង គឺខ្ញុំ គឺថាពិតប្រាកដហើយ គឺមិនមែនក្លែងបន្លំ

អីទេ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ឲ្យលោកពិនិត្យជាដំបូងទៅលើចម្លើយដែលលោកបានឆ្លើយ នៅទំព័រជាភាសាខ្មែរ គឺមានលេខ 00812860, ហើយជាភាសាអង់គ្លេស មានលេខ 0064153, និងភាសាបារាំង គឺមានលេខ ERN 00779382។ ហើយចម្លើយហ្នឹង គឺមានដូចតទៅនេះ ខ្ញុំសូមធ្វើការដកស្រង់ "វៀតកុង ត្រូវបានតាមដានដោយខ្មែរក្រហម ហើយមកគ្រប់គ្រងទៅលើភូមិរបស់គាត់ នៅក្នុងឆ្នាំ១៩៧០។ វៀតកុង នៅជួរខាងមុខ ហើយខ្មែរក្រហមបានដើរតាមក្រោយ ដោយស្លៀកពាក់ខោអាវខ្មៅជាមួយវៀតកុង។ លោកបានឮការអំពាវនាវរបស់សម្តេច សីហនុ តាមវិទ្យុប៉េកាំង ក្នុងយុទ្ធនាការដើម្បីរណសិរ្សផ្សះផ្សាជាតិ ដោយសុំឲ្យប្រជាជនចូលរួមជាមួយព្រះអង្គ ចូលព្រៃម៉ាគី។ ដោយសារតែសម្តេច សីហនុ បានអំពាវនាវពីប៉េកាំង ហើយព្រះអង្គគឺជាប្រធានរណសិរ្សវាយប្រឆាំងពួកអាណានិគម និងពួកចក្រពត្តិអាមេរិក ទើបអ្នកស្រុកបានស្វាគមន៍ពួកបដិវត្តន៍។ ប្រជាជនបានប្រគល់កូនៗរបស់ពួកគេ។ លោកគឺជាកូនទី៥ នៅក្នុងគ្រួសារកូន៩នាក់ ហើយមានកូន២នាក់បានចូលរួមជាមួយនឹងជនបដិវត្តន៍។

[១៤:០២:១១]

ប្អូនប្រុសតូចរបស់លោក នៅពេលនោះ មានអាយុ៨ឆ្នាំ ហើយខ្លួន -- ហើយលោកខ្លួនឯងមានអាយុ១៦ឆ្នាំ បានចូលរួមនោះនៅពេលនេះ"។ ជាដំបូង ខ្ញុំចង់សួរថាតើនេះគឺជាព័ត៌មានត្រឹមត្រូវ ពិតប្រាកដដែលលោកបានផ្តល់ទៅឲ្យលោក ហង់រី ឡូកា នៅក្នុងខែកក្កដា ឆ្នាំ១៩៨១ តើមែនដែរឬទេ?

**ឆ៖** បាទ លោក ខ្ញុំបានផ្តល់ព័ត៌មានឲ្យលោក ហង់រី ឡូកា គឺថាពិតប្រាកដ គឺថាត្រឹមត្រូវមែនដែលលោកបានអត្ថាធិប្បាយអំមិញនេះ គឺថាត្រឹមត្រូវ ដូចខ្ញុំបាននិយាយជាមួយលោក ហង់រី ឡូកា មែន។

**ស៖** ហើយនៅក្នុងឯកសារដដែលនេះ បញ្ជាក់ថា "ប្អូនប្រុសរបស់លោក ចូលបដិវត្តន៍នៅអាយុ៨ឆ្នាំ"។ តើលោកអាចប្រាប់ដែរឬទេ ថាតើប្អូនលោកហ្នឹង គេតែងតាំងឲ្យធ្វើអ្វី នៅពេលដែលចូលបដិវត្តន៍ នៅពេលដែលប្អូនលោកនោះ អាយុទើបតែ៨ឆ្នាំនោះ?

**ឆ៖** បាទ កន្លែងដែលប្អូនប្រុសខ្ញុំអាយុ៨ឆ្នាំចូលហ្នឹង គឺកន្លែងហ្នឹង ប្រហែលជា ខ្ញុំសូមថាមិនមែនទេ អាហ្នឹង គឺព្រោះប្អូនខ្ញុំមិនបានចូលរួមជាមួយខ្មែរក្រហមទេ ក្នុងអាយុ៨ឆ្នាំហ្នឹង។ កន្លែងហ្នឹងប្រហែលជាខុស ពាក្យសម្តីហ្នឹង មិនត្រូវទេ។ បើខ្ញុំចូលរួមពិតប្រាកដមែន។ ហ្នឹងសូមលោកកែសម្រួលកន្លែងដែល -- កន្លែងហ្នឹង គឺមិនប្អូនខ្ញុំមិនបានចូលទេ។

[១៤:០៤:០៨]

**ស៖** តើប្អូនប្រុសរបស់លោកនេះ ចូលរួមជាមួយបដិវត្តន៍នាពេលក្រោយទៀតដែរឬទេ?

**ឆ៖** បាទ ប្អូនប្រុសខ្ញុំក្រោយមក វាចូលរួមជាមួយនឹងខ្មែរក្រហម ហើយនៅ -- ប៉ុន្តែមិនចូលរួមមុនឆ្នាំ៧៥ទេ គឺក្រោយឆ្នាំ៧៥ ប្រហែលជាក្នុងឆ្នាំ៧៦។ គឺប្អូនប្រុសខ្ញុំហ្នឹង គឺបានចូលរួមជាមួយខ្មែរក្រហម នៅឆ្នាំ -- អំអូ! មិនមែន៧៦ទេ គឺ៧៦ អូ! ៧៦ ៧៩ ដែរ ៧៦។ នៅឆ្នាំ៧៦ លោក ប្អូនប្រុសខ្ញុំហ្នឹង គឺបានចូលរួមជាមួយខ្មែរក្រហមនៅឆ្នាំ៧៦។ នេះគឺជាការពិត ដែលខ្ញុំប្រាប់ក្រោយហ្នឹង ជាការពិត។ ពីមុនហ្នឹង អាយុ៨ឆ្នាំហ្នឹង អានោះមិនពិតទេ ឬមួយក៏ខ្ញុំនិយាយប្រាប់លោកមិនសូវច្បាស់។ ចូលរួមនៅឆ្នាំ១៩៧៦ ប្អូនប្រុសខ្ញុំ។

**ស៖** សូមអរគុណ ដែលលោកបានកែចម្លើយត្រង់ចំណុចនេះ។ សំណួរបន្ទាប់របស់ខ្ញុំគឺ ពាក់ព័ន្ធនឹងករណីថាតើលោកនៅចាំថា មានមេដឹកនាំខ្មែរក្រហមបានមកស្រុករបស់លោក មកធ្វើសុន្ទរកថា នៅក្នុងចុងឆ្នាំ៧១ ដើមឆ្នាំ៧២ និងឆ្នាំ៧៣ ដែរឬទេ?

**ឆ៖** បាទ កន្លែងហ្នឹងវាបានមកមែន ពិតប្រាកដមែន។ លោកសរសេរហ្នឹងគឺត្រឹមត្រូវបាទ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹង ហង់រី ឡូកា គឺមានចំណុចមួយសរសេរអំពីករណីហ្នឹង ដែលខ្ញុំសូមសួរលោកខ្មែរ ERN គឺត្រង់លេខ 00812861, អង់គ្លេសគឺ 00164153, និងបារាំង ERN គឺ 00779382។ នៅត្រង់ផ្នែកកិច្ចសម្ភាសន៍នេះ គឺមានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "រហូតមកទល់ឆ្នាំ១៩៧៣ ហ៊ូ យន់ បានមកថ្លែងសុន្ទរកថា នៅក្នុងព្រៃនៅក្នុងភូមិព្រៃធំ ឃុំគោកធ្លកលើ ប៉េ.ជេ.ប.រ ជីបសែ មិនបាន -- បាទ ពាក្យថា ប៉េ.ជ.ប.រ ជីបសែ នេះគឺសំដៅលើឈ្មោះលោកមិនបានចូលរួមប្រជុំឡើយ ប៉ុន្តែប្រជាជនមូលដ្ឋានជាច្រើនមានវត្តមាន។ ហ៊ូ យន់ លើកទឹកចិត្តឲ្យប្រជាជនចូលរួមចំណែកក្នុងការតស៊ូយោធា ដើម្បីផ្ដួលរំលំ លន់ នល់។ យោងតាមពាក្យសម្ដីរបស់ ហ៊ូ យន់ ខ្មែរក្រហមចង់កាត់ផ្ដាច់ទំនាក់ទំនងជាមួយនឹងវៀតកុង"។ សូមបញ្ចប់ការដកស្រង់សម្ដីត្រឹមនេះ។ តើការសរសេរក្នុងនេះៗ គឺជាការសរសេរនូវចម្លើយ អ្វីដែលលោកឆ្លើយបានត្រឹមត្រូវប្រាប់ទៅលោក ហង់រី ឡូកា អំពីបញ្ហា ហ៊ូ យន់ និយាយអ៊ីចឹងដែរឬទេ?

[១៤:០៨:១៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់នឹងរបៀបសួរសំណួរដូច្នេះ។ យើងក៏បានមានបញ្ហា ជួប ប្រទះបញ្ហាហ្នឹងកាលពីសប្តាហ៍មុនផងដែរ។ សហព្រះរាជអាជ្ញាមានសេរីភាពក្នុងការជជីកសួរ អំពី បញ្ហាហ្នឹង ក៏ប៉ុន្តែវិធីដែលសួរសំណួរបែបនេះគឺ មិនគួរដឹកមុខសាក្សី និងបញ្ចូលព័ត៌មានឲ្យសាក្សីឆ្លើយ ថា គាត់ចាំ ឬមិនចាំនៅក្នុងថ្ងៃនេះ ឬយ៉ាងណានោះទេ។ សំណួរដែលសមស្របនោះគួរតែសួរថា តើ សាក្សីនៅចាំថា ហ៊ូ យន់ បានមកធ្វើទស្សនកិច្ចនៅកន្លែងណាមួយដែរឬទេ? តើគាត់ចាំដែរឬទេ? ហើយ តើ ហ៊ូ យន់ មាននិយាយអ្វីខ្លះដែរឬទេ? ហើយប្រសិនបើសួរដូច្នេះនោះគឺ អាចធ្វើទៅបាន។ បើសិនសួរ ដូចអម្បាញ់មិញ គឺវាប្រឡាក់ប្រឡូសទៅនឹងភស្តុតាងរបស់សាក្សី ដែលនឹងឆ្លើយ។ ដូច្នេះ គឺការដែលសួរ ដឹកមុខនោះគឺ មិនអាចធ្វើទៅបាននោះទេ។ ខ្ញុំដឹង អំពីការចង់ចោទសួរនេះដែលថា ចង់ឲ្យសាក្សីនេះ បញ្ជាក់ថាតើសាក្សីចាំដែរឬទេ នៅក្នុងពីសម័យកាលដែលបានកើតឡើងនោះ? ដូច្នេះ ខ្ញុំស្នើសុំឲ្យ សហព្រះរាជអាជ្ញានោះសួរសំណួរបិទបើកវិញ សំណួរជាលក្ខណៈចំហវិញ ដើម្បីឲ្យសាក្សីឆ្លើយ។

[១៤:០៩:៥៣]

**លោក ឌេល លីសាក់៖**

លោកប្រធាន គឺខ្ញុំអាចបន្តទៅមុខបានទៀត តាមឆន្ទៈ និងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។ ហើយប្រសិនបើយើងមានឯកសារណាមួយ ពាក់ព័ន្ធទៅនឹងសាក្សីនោះគឺថា យើងខ្ញុំអាចដាក់ឲ្យគាត់ មើលបាន។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយគឺយើងខ្ញុំគិតថា ការធ្វើក្រៅពីនេះវាអាចចំណាយពេលយូរ។ យើង ខ្ញុំនៅតែទទួលយកការណែនាំពីអង្គជំនុំជម្រះដដែល។ អនុស្សរណៈរបស់អង្គជំនុំជម្រះបានបញ្ជាក់ថា ភាគីមេធាវីទាំងអស់គឺត្រូវតែធ្វើយ៉ាងណាពន្លឿននីតិវិធីក្នុងការដេញដោលសំណួរ ដូចជាដាក់ឯកសារឲ្យ សាក្សីមើល រួចហើយសួរសំណួរបន្តតែម្តង។ នេះគឺជាការពន្លឿននីតិវិធី។ សូមអរគុណ។

[១៤:១០:៣៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១១:២៤]

**ប្រធានអង្គជំនុំ៖**

បាទ ទទួលយកនូវការកត់សម្គាល់របស់មេធាវីការពារក្តីលោក នួន ជា សូមលោកតំណាងសហ ព្រះរាជអាជ្ញាកែសម្រួលនូវសំណួររបស់ខ្លួនឡើងវិញ ដើម្បីឲ្យមានលក្ខណៈជាសំណួរបែបចំហ ឬក៏

សំណួរជាទូទៅ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** អម្បាញ់មិញនេះបន្តិចលោកសាក្សី លោកបានជម្រាបយើងខ្ញុំថា លោកចាំថាមានអ្នក -- មានមេដឹកនាំខ្មែរក្រហមមួយចំនួន បានមកធ្វើសុន្ទរកថានៅជីក្រែងមុនឆ្នាំ១៩៧៥ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ថាតើមេដឹកនាំណាខ្លះដែលមកធ្វើសុន្ទរកថា នៅតាមអ្វីដែលលោកចាំដូចដែលលោកបានឆ្លើយអម្បាញ់មិញនេះ?

[១៤:១២:២១]

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ដែលចំពោះចម្លើយខ្ញុំគឺថា ដែលខ្ញុំចាំគឺមានលោក ហ៊ូ យន់ នេះឯងដែលមកថ្លែងសុន្ទរកថានៅព្រៃធំ ដូចលោក ហង់រី ឡូកា លោកបានសរសេរហ្នឹងគឺ ខ្ញុំក៏បានឆ្លើយ លោកក៏បានសរសេរគឺ កន្លែងនុ៎ងគឺត្រឹមត្រូវទៅតាមការឆ្លើយរបស់ខ្ញុំ គឺថាបានមកភូមិព្រៃធំឃោសនា លោក ហ៊ូ យន់ នៅឆ្នាំ១៩៧៣ ហើយចំពោះខ្ញុំហ្នឹងគឺអត់បានទៅចូលរួមទេ គឺមានតែប្រជាជនមូលដ្ឋានបានវាឲ្យទៅចូលរួម។ ក្នុងមួយស្រុកទៅតែមួយកន្លែងទេគឺនៅក្នុងភូមិព្រៃធំហ្នឹង។ ហើយខ្ញុំដែលដឹងថា វានិយាយម៉េចៗគឺតាមតែប្រជាជនគេមកវិញ គេប្រាប់ខ្ញុំទេថា ដើម្បីវាបំផុសឲ្យមានការតស៊ូជាមួយនឹងវៀតកុងដើម្បីដេញពួកវៀតកុងចេញពីប្រទេសកម្ពុជា។ អាហ្នឹងគឺ -- កន្លែងហ្នឹងគឺ ជាចម្លើយត្រឹមត្រូវដែលខ្ញុំបានប្រាប់លោក ហង់រី ឡូកា ពិតប្រាកដមែន។

[១៤:១៣:៥៧]

**ស៖** តើលោកធ្លាប់ឃើញ នួន ជា, អៀង សារី ឬក៏ ខៀវ សំផន មកស្រុកជីក្រែងក្នុងពេលណាមួយដែរឬទេ?

**ឆ៖** បាទ ចំពោះ នួន ជា, អៀង សារី, ខៀវ សំផន គឺថាមិនដែលមកស្រុកជីក្រែងទេ។ នេះគឺថាខ្ញុំមិនដែលឃើញមកឃោសនា ឬមកប្រជុំអីនៅស្រុកជីក្រែងគឺអត់ទេ។ អត់មានទេបាទ។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ខ្មែរក្រហមរំដោះជីក្រែងហ្នឹងនៅក្នុងពេលណាដែរ ក្នុងឆ្នាំណាដែរ?

**ឆ៖** ខ្មែរក្រហមរំដោះនៅជីក្រែងក៏ដូចជាទូទាំងប្រទេសដែរ នៅថ្ងៃទី១៧ មេសា ១៩៧៥។ គឺថារំដោះចេញពី លន់ នល់ នៅៗថ្ងៃដែលខ្ញុំបានប្រាប់អម្បាញ់មិញ ១៧ មេសា ១៩៧៥។

**ស៖** សំណួររបស់ខ្ញុំនោះគឺសួរអំពីជីក្រែង ការរំដោះជីក្រែង តើកងកម្លាំងខ្មែរក្រហមនោះគ្រប់គ្រងជីក្រែងនោះក្នុងឆ្នាំណាដែរ?

**ឆ៖** អូ! សំណួរនេះគឺខ្ញុំសូមឆ្លើយថា ដែលវាគ្រប់គ្រងជីក្រែងនោះគឺតាំងពីឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារគឺទឹកដីហ្នឹងគឺនៅក្រោមខ្មែរក្រហមកាន់កាប់ នេះគឺក្រោយរដ្ឋប្រហារ។ គឺទឹកដីហ្នឹង ខ្មែរក្រហមកាន់កាប់បាទ។

**ស៖** តើលោកចាំដែរឬទេ តើសហករណ៍នៅក្នុងស្រុករបស់លោកនោះ បង្កើតជាលើកដំបូងក្នុងឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំសូមប្រាប់ សហករណ៍ដែលវាបង្កើតនៅក្នុងភូមិរបស់ខ្ញុំហ្នឹងគឺនៅមួយពាន់ -- ឆ្នាំ ១៩៧២ គឺវាបង្កើតជាសហករណ៍នៅក្នុងភូមិ។ អានេះខ្ញុំដឹងតែនៅក្នុងភូមិរបស់ខ្លួនឯងទេ ប៉ុន្តែទូទាំងប្រទេសគឺខ្ញុំមិនបានដឹងទេ។

[១៤:១៧:២៧]

**ស៖** ត្រង់ចំណុចនេះដដែល គឺខ្ញុំសូមឲ្យលោកពិនិត្យមើលការដកស្រង់ចេញមកពីកិច្ចសម្ភាសន៍របស់លោកជាមួយ ហង់រី ឡូកា។ គឺឯកសារ D83/0012 ដដែល ខ្មែរគឺ 00812861, អង់គ្លេស ERN គឺ 00164153, បារាំងមានលេខ ERN 00779382។ នៅក្នុងនោះគឺមានចម្លើយមួយឃ្លាដែលពាក់ព័ន្ធទៅនឹងអ្វីដែលលោកឆ្លើយ សូមដកស្រង់សម្ដី “ចាប់ពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៤ អ្នកស្រុករស់នៅជាមួយគ្រួសារដដែល”។ បញ្ចប់ការដកស្រង់សម្ដី។ ខ្ញុំសូមឲ្យលោកបញ្ជាក់ត្រង់ឃ្លានេះបន្តិច តើក្រោយឆ្នាំ១៩៧៤នោះ តើមានអ្វីកើតឡើងទៀត ស្ថានភាពហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** សូម -- ខ្ញុំសូមមិនឆ្លើយដោយសារសំណួរហ្នឹងគឺមិនយល់។ មិនយល់សំណួរតែម្ដង។ សូមលោកបញ្ជាក់ម្ដងទៀត។

**ស៖** តើនៅក្នុងស្រុករបស់លោកមានពេលណាមួយ ដែលអ្នកស្រុកនោះគេលែងឲ្យរស់នៅជាមួយគ្នាទៀតហើយដែរឬទេ?

**ឆ៖** បាទ គឺនៅឆ្នាំ១៩៧០ គឺអ្នកស្រុកគឺមិនទាន់បានរស់នៅបែកគ្នាទេ ដល់ទៅឆ្នាំដែលខ្មែរក្រហមមានជាការឲ្យមានដូចជាចលនាតស៊ូជាមួយនឹង នល់ នល់ គឺវាឲ្យប្រជាជននាំកូនចៅចូលជាកង

ទ័ពដើម្បីទៅវាយជាមួយ លន់ នល់ អាហ្នឹងគឺមានការបែកគ្នា។ ដូចថាកូនចៅចេញទៅសមរភូមិទៅ ម៉ែឪក៏នៅសមរភូមិក្រោយបង្កបង្កើនផល អាហ្នឹងគឺនៅឆ្នាំ១៩៧៣ ៧៤ ហ្នឹងគឺមានបែកគ្នា ដោយសារខ្មែរក្រហមរើសទ័ពដើម្បីបង្គ្រប់ទ័ពរបស់វាទៅវាយពួក លន់ នល់ បាទ។

[១៤:២០:៤២]

**ស៖** ចម្លើយដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតបានសរសេរនិងលើកឡើងថា លោកចាប់ផ្តើមនៅមន្ទីរ -- ធ្វើការងារនៅមន្ទីរសន្តិសុខពង្រ នៅអំឡុងឆ្នាំ១៩៧២។ តើលោកអាចជម្រាបជូនយើងខ្ញុំដែរឬទេ លោកមានតួនាទី មុខងារអ្វីដែរនៅពេលដែលលោកចាប់ធ្វើការងារនៅទីនោះជាលើកដំបូងក្នុងឆ្នាំ១៩៧២ នោះ?

**ឆ៖** បាទ ដែលចូលធ្វើបម្រើនៅឆ្នាំ១៩៧២ ខ្ញុំមានមុខងារជាអ្នកសរសេរឯកសារសម្រាប់ដែលថា មានអ្នកទោសប៉ុន្មាន ហើយអ្នកទោសនោះមានសំណុំរឿងយ៉ាងដូចម្តេច គឺថានិយាយទៅខ្ញុំជាអ្នកគ្រប់គ្រងនូវឯកសារអ្នកទោស គឺខ្ញុំនាទីជាស្មៀនក៏បានដែរ វាទទួលផ្នែកសំណុំឯកសារ។ នេះគឺនាទីរបស់ខ្ញុំ។

**ស៖** មន្ទីរសន្តិសុខពង្រ តើជាមន្ទីរសន្តិសុខនៅក្នុងតំបន់ ស្រុក ភូមិភាគ ឬក៏នៅកន្លែងណាដែរ?

**ឆ៖** បាទ មន្ទីរសន្តិសុខពង្រ គឺជាមន្ទីរសន្តិសុខស្រុករបស់ខ្មែរក្រហម មិនមែនជាសន្តិសុខតំបន់ ភូមិភាគអីទេ គឺជាមន្ទីរសន្តិសុខស្រុក ទទួលមួយស្រុកជីក្រែងតែម្តង។

[១៤:២២:៥៣]

**ស៖** នៅពេលដែលលោកចាប់ផ្តើមបម្រើការងារនៅមន្ទីរសន្តិសុខនោះ តើខ្មែរក្រហមមានបង្កើតឲ្យមានការលេខាស្រុក ឬក៏គណៈកម្មាធិការស្រុកនុ៎ងដែរឬទេ?

**ឆ៖** បាទ ដែលខ្ញុំនៅធ្វើការនៅកន្លែងនោះ គឺខ្មែរក្រហមវាបង្កើតឲ្យមានជាអ្នកដឹកនាំកន្លែងសន្តិសុខនោះ គឺលើកដំបូងគឺឈ្មោះ តាវ៉ន គឺជាអ្នកដឹកនាំ។ ក្រោយពីចាប់ តាវ៉ន ទៅគឺមានមេដឹកនាំមួយទៀតគឺឈ្មោះ តាគុណ ជាអ្នកដឹកនាំលើកក្រោយទៀត។ ប៉ុន្តែក្រោយមក តាគុណ នុ៎ងក៏ត្រូវគេថាក្បត់ក៏យកទៅសម្លាប់ទៀត។ ហើយរចនាសម្ព័ន្ធរបស់វា គឺវាបង្កើតឲ្យមានជាអង្គការសម្ងាត់។ អង្គការសម្ងាត់របស់ខ្មែរក្រហម គឺមានបក្ខជន មានសម្ព័ន្ធយុវកក។ ដូច្នេះគឺនៅក្នុងសន្តិសុខនោះវាមានបក្ខជនវានោះពីរនាក់ ប្រធាន អនុប្រធាន ហើយដែលដៃស្តាំរបស់វាមានសម្ព័ន្ធយុវកកនោះ ប្រហែលជា៦-៧នាក់ ខ្ញុំមិនចាំទេ គឺថាការប្រមូលអង្គការសម្ងាត់របស់វាហ្នឹង គឺវាមិនដែលឲ្យខ្ញុំបានទៅដឹងទេ។ ប៉ុន្តែខ្ញុំស្គាល់

តាមរយៈគ្នាវា ចេះតែសួរទៅ វាប្រាប់ទៅ ប្រហែលជា៤-៥ នាក់។ អាហ្នឹងគឺថាសម្ព័ន្ធយុវកកវា។ ហើយតួនាទីរបស់ខ្ញុំគ្រាន់តែថា ជាអ្នកកត់ត្រាមែន ប៉ុន្តែវាគ្មានចូលក្នុងអង្គការសម្ងាត់របស់វាទេ។ នេះគឺសូមរាយការណ៍ជូនលោកប្រធានជាការពិត មិនមែនថាមកក្លែងបន្លំទេ។

[១៤:២៤:៥៦]

**ស៖** សូមអរគុណ។ តើមេផ្ទាល់របស់លោកនៅមន្ទីរសន្តិសុខនេះ មានបានពន្យល់ហេតុផលដែរឬទេថា មន្ទីរសន្តិសុខនោះ គេបង្កើតឡើងក្នុងគោលបំណងអ្វីដែរនៅក្នុងឆ្នាំ១៩៧២ និង៧៣ នោះ?

**ឆ៖** បាទ គឺថាវាពន្យល់ណែនាំហ្នឹងគឺច្រើនលើកច្រើនសាដែរ គឺថាមន្ទីរសន្តិសុខហ្នឹង វាថាជាកន្លែងសម្រាប់យកអ្នកទោសមកកសាង ដើម្បីអប់រំឱ្យក្លាយជាមនុស្សល្អ ហើយប្រគល់ទៅឱ្យមូលដ្ឋានវិញ ប៉ុន្តែការនិយាយរបស់វាគឺមិនពិត។ មានខ្លះស្លាប់ យកមកសម្លាប់ មកអី។ ដូច្នេះល្អតែមាត់ ប៉ុន្តែចិត្តគំនិតវាគឺអាក្រក់។

**ស៖** នៅពេលនេះ ខ្ញុំចង់ឱ្យលោកមើលកិច្ចសម្ភាសន៍ កំណត់ហេតុកិច្ចសម្ភាសន៍របស់លោកជាមួយ ហង់រី ឡូកា ត្រង់ទំព័រជាភាសាខ្មែរ 00812862, អង់គ្លេស ERN គឺ 00164154, និងបារាំងមានលេខ ERN 00779383។ ការដកស្រង់សម្ដីដែល -- សម្រង់សម្ដីដែលខ្ញុំចង់អានជូនលោកនោះ គឺមានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី៖ "វាជាមន្ទីរសន្តិសុខរបស់មជ្ឈិមដែលជាអ្នកកាន់កាប់អំណាចរបស់អង្គការ។ វាគឺជាមន្ទីរសន្តិសុខដែលទុកសម្រាប់ដាក់ប្រជាជនទាំងអស់ ដើម្បីឱ្យខ្លាចអំណាចអង្គការ។ អង្គការបានប្រាប់ពេល ជ.ប.រ. ជីបសែ ថា អ្នកជាប់ឃុំទាំងអស់គឺជាពួកចក្រពត្តិ និងពួកនាយទុន។ អំណាចអង្គការនឹងធ្វើឱ្យពួកគេភ័យខ្លាច"។ តើនរណាដែលជាប្រាប់ ជាអ្នកប្រាប់លោកថាអ្នកដែលជាប់ឃុំនោះ គឺជាពួកចក្រពត្តិ និងពួកនាយទុននោះ?

[១៤:២៧:៣៨]

**ឆ៖** បាទ អ្នកដែលប្រាប់ខ្ញុំថា ពួកអ្នកទោសជាចក្រពត្តិ ជានាយទុនហ្នឹងគឺមេៗសន្តិសុខ និងបក្សពួកវាហ្នឹង គឺវាចាត់ទុកអ្នកទោស ហើយវាតែងឃោសនានិយាយថា ជាចក្រពត្តិ ជានាយទុន ជាពួកក្បត់ គឺច្រើនតែអ្នកដឹកនាំនៅមន្ទីរសុន្តិសុខពង្រហ្នឹង គឺបាននិយាយពិតប្រាកដមែន។

**ស៖** តំណាងសហព្រះរាជអាជ្ញាជាតិបានសួរអំពីទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ដែលត្រូវបានគេជម្លៀសពីខេត្តសៀមរាបភ្លាមៗក្រោយខែមេសា ឆ្នាំ១៩៧៥។ ត្រង់ចំណុចនេះ ខ្ញុំចង់សួរលោកតើទាហានរបស់ លន់ នល់ ដែលបានចាប់ខ្លួននោះ មានបានបញ្ជូនមកមន្ទីរសន្តិសុខពង្រ មុនឆ្នាំ១៩៧៥

ខែមេសា ដែរឬទេ?

**ឆ៖** បាទ ចំពោះទាហាន លន់ នល់ ដែលវាជម្លៀសមកនៅឆ្នាំ៧៥ នុ៎ង គឺអត់មានបានចូលទៅក្នុងសន្តិសុខពង្រទេ គឺវាយកទៅសម្លាប់ទាំងអស់។ ដូច្នេះ វាអត់មានចូលទៅក្នុងសន្តិសុខពង្រទេ គឺខ្ញុំរាយការណ៍ជូនលោកអ៊ីចឹង ហើយបើមុនឆ្នាំ៧៥ វាមានទាហានខ្លះដែលវា ដូចថារត់ចោលជួរពី លន់ នល់ មក គឺវាៗមានចាប់យកទៅដាក់មុនឆ្នាំ៧៥មានៗ មានចាប់ដោយទាហានហ្នឹង គឺថាមិនដឹងជាបាក់ទ័ព មិនដឹងជារត់ចោលជួរយ៉ាងម៉េចទេ គឺថាចូលមកតំបន់ខ្មែរក្រហមទៅ ក៏ខ្មែរក្រហម វាក៏ចាប់យកទៅដាក់កន្លែងហ្នឹងទៅ។ អាហ្នឹងគឺមាន។ បើថា ពួកមន្ត្រី ទាហាន ដែលជម្លៀសឆ្នាំ៧៥ហ្នឹង គឺអត់មានទេៗ។ វាយកទៅសម្លាប់អស់ហើយ។

**ស៖** តើទាហាន លន់ នល់ នោះ ដែលត្រូវបានគេយកទៅមន្ទីរសន្តិសុខពង្រនោះ តើមានអ្វីកើតឡើងចំពោះពួកគាត់ដែរ?

**ឆ៖** ចំពោះទាហានដែលខ្ញុំឃើញយកទៅដាក់ហ្នឹង គឺថាឃើញវាយកទៅសម្លាប់។ ប៉ុន្តែវាសម្លាប់ហ្នឹង គឺដោយសារអ៊ីចេះទេ គឺវាមានគ្នាទាំងអស់៤នាក់ ដែលមូលដ្ឋានគេរាយការណ៍មក ក៏ពួកសន្តិសុខហ្នឹង គឺគេចាប់យកមក៤នាក់។ ប៉ុន្តែដល់ពេលវាដែលសម្លាប់នោះ ដោយសារមានការរត់ រត់អស់បីនាក់ ហើយម្នាក់នោះ អត់បានរត់នឹងគេ ក៏ខ្មែរក្រហម ក៏ចាប់គ្នាយកទៅសម្លាប់ទៅ។ អានេះ គឺខ្ញុំបានដឹងប៉ុណ្ណឹង។ អានេះ មុនឆ្នាំ៧៥។

[១៤:៣១:៣៧]

**ស៖** ខ្ញុំចង់ឲ្យលោកពិនិត្យទៅលើការដកស្រង់មួយទៀត ដែលជាការសម្ភាសរបស់លោក ជាមួយលោក ហង់រី ឡូកា ដែរ។ គឺមាននៅត្រង់ភាសាខ្មែរ មានលេខ 00812863, ហើយភាសាអង់គ្លេស គឺមានលេខ 00164155, និងភាសាបារាំង មានលេខ 00779384។ ហើយនៅត្រង់ទំព័រនេះ គឺមានការនិយាយអំពីការសម្ភាសរបស់លោក ដែលខ្ញុំសូមដកស្រង់ “នៅពេលទាហាន លន់ នល់ ត្រូវបានចាប់ខ្លួន ទាហានទាំងនេះ ត្រូវបានគេសម្លាប់ចោលភ្លាមៗតែម្តង”។ តើលោកអាចប្រាប់បានដែរឬទេ តើទាហាន លន់ នល់ ហ្នឹង គឺជាទាហាន លន់ នល់ បែបណាដែរ? ឬក៏ជាអ្នកដែរ នៅពេលដែលលោកនិយាយទៅលោក ហង់រី ឡូកា នោះ?

**ឆ៖** បាទ ក្នុងចំណុចដែលខ្ញុំប្រាប់ទៅលោក ហង់រី ឡូកា ខ្ញុំចង់និយាយថា ទាហាន លន់ នល់ ដែលបានជម្លៀសមកពីសៀមរាប នៅក្នុងឆ្នាំ ថ្ងៃ១៧ មេសា ៧៥ ហ្នឹង គឺមកដល់កំពង់ក្តី គឺក្រោយពីវា

មិនដឹងអង្គភាពណាទេ គេទៅសម្អាសរួច គឺថាដឹកតាមឡាន យកទៅសម្លាប់។ អាហ្នឹង គឺខ្ញុំចង់និយាយចំណុចហ្នឹង ដើម្បីប្រាប់លោក ហង់រី ឡូកា បាទ។ គឺថាលោកក៏សរសេរ ដូចខ្ញុំបាននិយាយមែន បាទ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីជម្លៀសវិញម្តង សហការីរបស់ខ្ញុំបានសួរលោកបញ្ហាមួយចំនួនទាក់ទងទៅលើបញ្ហានេះ។ ឥឡូវនេះខ្ញុំមានចំណុចមួយទៀតដែលខ្ញុំចង់ឲ្យលោកធ្វើការបញ្ជាក់។ លោកបានបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតថា “មន្ត្រី និងទាហាន លន់ នល់ ត្រូវបានគេនាំយកទៅផ្សារជីក្រែង ហើយត្រូវបានគេបញ្ជូនចេញតាមឡានធំ ទៅក្រៅ”។ តើលោកបានឃើញថា មនុស្សទាំងអស់នេះ ត្រូវបានគេដឹកបញ្ជូនតាមឡានធំដែរឬទេ?

[១៤:៣៤:២៣]

**ឆ៖** បាទ ខ្ញុំចង់ប្រាប់លោកថា បញ្ហាដែលខ្ញុំបានឃើញនោះ គឺមិនបានឃើញ។ ប៉ុន្តែខ្ញុំបានស្តាប់តាមពួកដែលសន្តិសុខហ្នឹង ដែលវាទៅធ្វើការហ្នឹង វាមកដល់ ក៏វានិយាយប្រាប់ខ្ញុំថា “គេដឹកពួកអាទាហានដែលយកមកសៀមរាបហ្នឹង តាមឡានយកទៅទំនប់ម្កាក់ ហើយគេ អន្លង់អី គេធ្វើស្រេចហើយ គឺថាយកទៅ គេចងមុខ ហើយយកទៅសម្លាប់ ទាំងកូន ទាំងប្រពន្ធ”។ អាហ្នឹង គឺខ្ញុំមិនបាន ថាឃើញផ្ទាល់ភ្នែក ឬមួយក៏អីទេ គឺតាមតែរយៈពួកដែលបានទៅចូលរួមសម្លាប់ហ្នឹងឯង គឺថាស្តាប់គេនិយាយប្រាប់ខ្ញុំបាទ។

**ស៖** នៅពេលដែលលោកនិយាយថា ពួកគេហ្នឹង តើមានមនុស្សប៉ុន្មាននាក់ដែរ ដែលបានប្រាប់លោកអំពីហេតុការណ៍ទាំងអស់នេះ?

**ឆ៖** បាទ ចំពោះអ្នកដែលប្រាប់ខ្ញុំហ្នឹង គឺមានមនុស្សបីនាក់ ពីព្រោះគេគឺធ្លាប់នៅភូមិជាមួយគ្នា ទៅវាមិនសូវលាក់នឹងខ្ញុំទេ។ វានៅធ្វើការនៅកន្លែងសន្តិសុខពង្រហ្នឹងដែរ។

[១៤:៣៦:៣៣]

**ស៖** លោកបានបញ្ជាក់ថា បន្ថែមពីលើមន្ត្រី លន់ នល់ និងទាហាន លន់ នល់ ដែលត្រូវបានគេចាប់យកទៅដាក់នៅផ្សារជីក្រែង ហើយយកចេញទៅសម្លាប់ចោលនោះ ក៏មានជនស៊ីវិលដទៃទៀតដែលត្រូវបានគេជម្លៀសពីសៀមរាប យកមកដាក់នៅស្រុករបស់លោក។ តើលោកចាំដែរឬទេថា មានជនស៊ីវិលប្រហែលជាប៉ុន្មាននាក់ ដែលត្រូវបានគេជម្លៀសពីសៀមរាបមកស្រុកជីក្រែងនេះ? តើមានចំនួនមនុស្សប្រហែលប៉ុន្មាននាក់ គឺអ្នកដែលត្រូវបានជម្លៀសនៅថ្ងៃ១៧ មេសា ឬក៏ក្រោយថ្ងៃ១៧ មេសា បន្តិចបន្តួចនោះ?

**ឆ៖** បាទ ចំពោះចំនួនអ្នកជម្លៀសពីសៀមរាបមកស្រុកជីក្រែង គឺខ្ញុំមិនអាចចាំបានទេ ប៉ុន្តែខ្ញុំដឹងថា អ្នកដែលជម្លៀសមកចូលស្រុកជីក្រែង មិនថាតែអ្នកសៀមរាបទេ គឺអ្នកទៅពីភ្នំពេញក៏មានជម្លៀសទៅដល់កន្លែងស្រុកជីក្រែងដែរ ប៉ុន្តែចំនួនគឺ ខ្ញុំមិនចាំបានទេ ចំពោះប្រជាពលរដ្ឋ។ គឺថាបើពួកមេទាហាន ពួកអីអាហ្នឹងគឺថា ខ្មែរក្រហមសម្លាប់អស់ហើយ។

[១៤:៣៧:៣៥]

**ស៖** តើទីតាំងដទៃទៀត ដែលលោកនិយាយថា ប្រជាជនត្រូវបានគេជម្លៀសមកហ្នឹង តើទីតាំងហ្នឹងកន្លែងណាខ្លះដែរ ដែលគេជម្លៀសមកស្រុករបស់លោកនោះ?

**ឆ៖** បាទ ចំពោះទីតាំងគឺខ្ញុំដឹង គឺថាវាមិន -- វាឲ្យទៅនៅគឺថា ជនបទឆ្ងាយៗចុងកាត់មាត់ញកគឺថាវាយកអ្នកជម្លៀសពីភ្នំពេញក្តី សៀមរាបក្តី គឺយកទៅដាក់កន្លែងហ្នឹង ឲ្យប្រជាជនគឺថា ពួក១៧ វាហៅតែ១៧ ហ្នឹងឲ្យទៅនៅគឺថា កន្លែងដែលលំបាក គឺថាវាឲ្យទៅនៅហ្នឹង។ នេះគឺថា ខ្ញុំចាំ ប៉ុន្តែថា ទៅភូមិណាអី ភូមិឈ្មោះភូមិណាៗ អាហ្នឹង ខ្ញុំអត់ចាំទេ ប៉ុន្តែខ្ញុំឃើញថា អ្នក១៧ ហ្នឹងគឺគ្នាទៅនៅតែភូមិដែលពិបាករស់នៅតែម្តង ក្នុងព្រៃដាច់ស្រយាល គឺថាឲ្យទៅនៅហ្នឹង។ បាទ ដឹងប៉ុណ្ណឹង។

[១៤:៣៨:៥៧]

**ស៖** តើលោកដឹងដែរឬទេថា មានជនស៊ីវិល ដែលត្រូវបានគេ ជម្លៀសគឺប្រជាជន ១៧ មេសានោះ? តើប្រជាជន ១៧ មេសា ហ្នឹងត្រូវបានគេតម្រូវឲ្យធ្វើប្រវត្តិរូបដែរឬទេ នៅពេលដែលពួកគាត់ត្រូវបានជម្លៀសមកដល់ស្រុកជីក្រែងនោះ?

**ឆ៖** បាទ ចំពោះបញ្ហាហ្នឹងគឺ ខ្ញុំក៏បានដឹងខ្លះពីមូលដ្ឋានដែរ គឺថា ខ្ញុំមិនបាននេះទេ គឺមកដល់ដូចឧទាហរណ៍មកដល់ភូមិណាមួយ គឺគេឲ្យអ្នកជម្លៀសហ្នឹងទៅប្រាប់ប្រធានភូមិ ថាខ្ញុំនៅភ្នំពេញ ឬមួយក៏ខ្ញុំអ្នកជម្លៀសមកពីសៀមរាប ដើម្បីឲ្យអ្នកភូមិហ្នឹងគឺ -- អ៎! ដើម្បីឲ្យប្រធានហ្នឹងរកកន្លែងសម្រាប់ឲ្យស្នាក់នៅបណ្តោះអាសន្ន ឬមួយក៏នៅជាមួយអ្នកមូលដ្ឋានសិន ទម្រាំតែគេធ្វើជាផ្ទះតូចៗឲ្យរស់នៅដោយឡែកតាមគ្រួសារ។ អាហ្នឹងគឺ ចូលភូមិណាគឺឲ្យប្រធានភូមិដឹងឮផង។ អាហ្នឹងគឺ មានតែប៉ុណ្ណឹង។

**ស៖** តើលោកដឹងដែរឬទេ? តើមានការប្រឹងប្រែង ឬក៏ការខំខិតស្វែងរកជនស៊ីវិល ដើម្បីរកឲ្យឃើញថាមានប្រជាជនណាមួយមានទំនាក់ទំនងជាមួយនឹងរបប លន់ នល់ ដែរឬទេ? តើគេមានខំរកបែបនេះដែរឬទេ?

**ឆ៖** បាទ ក្នុងរបបខ្មែរក្រហមវាគឺពិតជាស្វែងរក ពីព្រោះវាមិនពេញចិត្តជាមួយអ្នក ១៧មេសា

ទេ។ គឺវាសួរនាំអំពីប្រវត្តិរូបដើម្បីឲ្យដឹងថា អ្នកឯងជាមន្ត្រីរដ្ឋការ ឬមួយក៏ជាទាហាន ដល់ពេលវាដឹងហើយគឺវាក៏ត្រូវនាំយកទៅសម្លាប់ទៀត។ ហ្នឹងគឺ របបហ្នឹងគឺវាមិនពេញចិត្តជាមួយអ្នក១៧ ប៉ុន្មានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណណាស់សាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ និងមេធាវីប្រឹក្សារបស់គាត់នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៦:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយអង្គជំនុំជម្រះចង់ដឹងផងដែរថា តើតំណាងសហព្រះរាជអាជ្ញាត្រូវការពេលវេលាប៉ុន្មានទៀត ក្នុងការតាំងសំណួរដេញដោលសាក្សីរូបនេះ?

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាននិយាយជាមួយនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាត់ត្រូវការប្រហែលជាកន្លះម៉ោង។ ដូច្នេះខ្ញុំនឹងព្យាយាមបញ្ចប់ត្រឹមម៉ោងបីសាមសិប បន្ទាប់មក គឺខ្ញុំនឹងផ្តល់វេទិកាទៅឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បី

សួរសំណួរបន្តដែលគាត់ចង់សួរ។ សូមអរគុណលោកប្រធាន។

[១៥:០៧:១៥]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ត្រឹមត្រូវហើយដូចលោកៗ ខេល បាននិយាយអម្បាញ់មិញ ហើយពេលវេលាអាចនឹងតិចជាងនេះបន្តិច ហើយមេធាវីដែលទទួលសិទ្ធិនោះគឺលោកមេធាវី វ៉េន ពៅ ហើយនិងមេធាវី នូស៊ីន សាកាវ៉ាទី សូមលោកប្រធានអនុញ្ញាត។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ចំណុចទូទៅដែលខ្ញុំចង់សុំសួរលោក នៅក្នុងថ្ងៃនេះលោកសាក្សីចំណុចទាំងអស់នោះគឺពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងនៅក្នុងស្រុកជីក្រែង ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៥:០៨:១៥]

លោកបានជម្រាបជូនយើងខ្ញុំ ហើយក៏បានលើកឡើងនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ហើយលោកក៏បានលើកឡើងកាលពីដើមរសៀលនេះផងដែរថា ប្រធានមន្ទីរសន្តិសុខពង្រ គឺមាន តាវ៉ន ក្រោយមកត្រូវបានចាប់ខ្លួន ក្រោយពីចាប់ខ្លួនគឺ តាគុណ ឡើងជាប្រធាន។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ តាវ៉ន និង តាគុណ នេះវាយការណ៍ឡើងទៅណាដែរ? អ្នកណាជាមេផ្ទាល់របស់ពួកគាត់ទាំងពីរ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ចំពោះសំណួរនេះគឺខ្ញុំសូមឆ្លើយថា តាវ៉ន និង តាគុណ មេរបស់គាត់គឺពួកស្រុក។ គឺថាគាត់ឡើងមកត្រឹមតែសួរត្រឹមតែថ្នាក់ស្រុកទេ គឺថាមិនឡើងដល់ទៅតំបន់ទៀតទេ។ ដូច្នេះកិច្ចការអីគឺគាត់ទទួលបញ្ជាពីប្រធានស្រុកទៅ បានគាត់ចាត់ចែងនៅក្នុងមន្ទីរសន្តិសុខហ្នឹង។ អាហ្នឹងគឺខ្ញុំឆ្លើយប៉ុណ្ណឹង។

**ស៖** តើគណៈកម្មាធិការស្រុកនេះគឺជានរណាដែរ ដែលពួកគេទាំងពីររាយការណ៍ទៅនោះ តើមាននរណាខ្លះដែរ?

**ឆ៖** បាទ ឯគណៈស្រុកហ្នឹង ខ្ញុំចាំថា ជំនាន់ តាវ៉ែន គឺឈ្មោះ តាស៊ុន។ តាស៊ុន គឺមេស្រុក។ ដល់ពេលក្រោយមកឈ្មោះ ក្រោយ តាស៊ុន មានតាសុខ ឈ្មោះ តាសុខ មេស្រុក។ ក្រោយដែល តាសុខ គាត់ឡើងជាមេស្រុក គាត់ត្រូវថាពួក តាស៊ុន និង តាវ៉ែន ហ្នឹងក្បត់។ ដូច្នេះហើយ តាវ៉ែន ហើយនិង តាស៊ុន ត្រូវស្លាប់ក្រោយពី តាសុខ ឡើងធ្វើជាមេស្រុក។ ដល់ទៅក្រោយមកគឺ តាសុខ បានឲ្យ តាគុណ នេះធ្វើជាមេសន្តិសុខម្តង។ ដូច្នេះអ្នកទាំងពីរហ្នឹង គឺមានទំនាក់ទំនងគ្នាជិតស្និទ្ធនៅក្នុងការសម្រេចផ្សេងៗ។

[១៥:១០:៥៧]

**ស៖** លោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតថា "តាសុខ មកពីខាងនិរតី"។ តើលោកអាចជម្រាបបានដែរឬទេ តាសុខ មកពីនិរតីហ្នឹងក្នុងឆ្នាំណាដែរ? ដែលពេលមកដល់នោះចាប់ខ្លួនអ្នកដែលធ្វើការមុនៗគាត់នោះ តើគាត់មកក្នុងឆ្នាំណាដែរ តាសុខ?

**ឆ៖** ចំពោះឆ្នាំហ្នឹងគឺខ្ញុំមិនអាចចាំបានទេ គឺចំពោះដែល តាសុខ។ តាសុខ នៅខាងនិរតី គឺថាបានន័យថានៅ គាត់បើនៅខេត្តតាកែវទេ គឺខេត្តកំពត។ តំបន់និរតីសម័យខ្មែរក្រហមហ្នឹង វាយកខេត្តកំពត តាកែវ ហ្នឹងថាជាហៅថា តំបន់ភូមិភាគនិរតី។ ហើយពួកហ្នឹងមកស្រុកជីក្រែង នៅពេលដែលវាចោទប្រកាន់អ្នកមុនថាក្បត់ ហ្នឹងគឺខ្ញុំអត់ចាំថានៅក្នុងឆ្នាំណាទេ។

**ស៖** មុនពេលឈប់សម្រាកអម្បាញ់មិញ យើងបាននិយាយអំពីជនស៊ីវិល ដែលត្រូវបានគេជម្លៀសនៅថ្ងៃ១៧ មេសា ហើយបញ្ជូនទៅស្រុកជីក្រែង។ តើលោកអាចជម្រាបជូនតុលាការដែរឬទេ តើប្រជាជន ១៧ មេសា ឆ្នាំ៧៥ នេះមានអ្វីកើតឡើងចំពោះគាត់ ក្រៅពីកម្មាភិបាល និងតាសុខ នោះមកដល់ជីក្រែងនោះ?

[១៥:១២:៤៦]

**ឆ៖** ចំពោះប្រជាជន ១៧មេសា គឺថាទោះជា តាសុខ ក្រោយឡើងជាមេស្រុកហើយក៏ដោយក៏គ្នានៅតែរងគ្រោះ។ គឺវានៅតែតាមដានយកទៅសម្លាប់ជាបន្តបន្ទាប់ ដោយវាចោទថាបានចូលដៃជាមួយចក្រពត្តិ ជាមួយ លន់ នល់។ ដូច្នេះខ្មែរក្រហមនៅតែតាមដាន ហើយឲ្យធ្វើការធ្ងន់ៗជាមួយអ្នកមូលដ្ឋាន គឺមិនបានសេចក្តីសុខប៉ុន្មានទេខាងអ្នកដែល ១៧មេសា ហ្នឹងគឺពិបាករស់នៅជាមួយខ្មែរក្រហម

ដោយវាប្រកាន់វណ្ណៈ។ នេះប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់សួរលោកឱ្យលោកបញ្ជាក់ការនឹកឃើញរបស់លោកឡើងវិញ គឺនៅពេលដែលលោកជួបសម្ភាសជាមួយនឹង ហង់រី ឡូកា ក្នុងឆ្នាំ១៩៩១។ លេខខ្មែរនោះគឺថា 00812868, អង់គ្លេសគឺមានលេខ 00164159, បារាំងមានលេខ ERN 00779387, ឯកសារ D83/0012។ នៅក្នុងឯកសារនេះគឺមានចំណុចមួយចំនួនដែលលោកបានឆ្លើយ។ សូមដកស្រង់សម្ដី "ក្រោយពីការចាប់ខ្លួន នៅក្នុងខែមេសា នោះគឺថាក្រោយពីនិរតីមកដល់ គឺមានការចាប់ខ្លួន។ យើងឃើញមានឡាន--" បាទ សូមដកស្រង់សម្ដី "ក្រោយពីសម្លាប់មេដឹកនាំមុនៗហើយនោះ ពួកនិរតីបានបន្តចាប់ខ្លួន និងសម្លាប់ពួក ១៧មេសា។ ប៉េ.ជ.រ.ប ជីបសែ តែមិនស្គាល់កន្លែងសម្លាប់នោះទេ ប៉ុន្តែបានឃើញក្របដោយស្លឹកត្នោតដឹកអ្នកស្រុកទៅសម្លាប់ចោលរៀងរាល់ថ្ងៃ ដោយយកពួកគេទៅគុកមួយទៀត។ ពួកនិរតីបានបង្កើតគុកស្រុកមួយទៀតនៅក្នុងវត្តកំពង់ក្ដី"។ ខ្ញុំសូមសួរលោក តើលោកបានឃើញឡានក្របដោយស្លឹកត្នោតមកដឹកអ្នក ១៧មេសា ចេញទៅនោះ នៅពេលណាដែរ?

**ឆ៖** ចំពោះសំណួរហ្នឹងគឺថា ពួកវាបានធ្វើ បានដឹកអ្នកទោសហ្នឹងទៅសម្លាប់នៅវត្តកំពង់ក្ដីពិតមែន។ ដោយវាចោទថាអ្នក១៧ មេសា ហ្នឹងបះបោរ សម្លាប់បក្សពួកវា សម្លាប់អាពួកខ្មែរក្រហមគ្នាវា។ ដូច្នេះហើយវាក៏មានជានយោបាយមួយដើម្បីចាប់ គឺថា "បងប្អូនណាដែលមានផ្កាក់ មានកាំបិតនៅនឹងដៃ គឺបងប្អូនមកជួបជុំគ្នាចុះ"។ ពេលនោះប្រជាជន ដែលបានសម្លាប់ខ្មែរក្រហមក៏បានមកជួបជុំ ហើយវាក៏ឱ្យទុកផ្កាក់ កាំបិតមួយកន្លែង។ ហើយវាក៏ចាប់ចងអ្នក១៧មេសា ដែល -- មិនមែនទាំងអស់ទេ គឺថាច្រើន -- ភាគច្រើនគឺច្រើនតែប្រុសៗ ហើយនិងក្មេងជំទង់។ ស្រីមិនសូវមានទេ ការបះបោរហ្នឹង ហើយវាយកឡានមក ចងរួចហើយបោះទៅលើឡាន ដឹកមកកន្លែងសន្តិសុខវា មិនមែនកន្លែងពង្រទេ គឺនៅវត្តកំពង់ក្ដី។ យកមកសម្លាប់នៅវត្តកំពង់ក្ដី។

[១៥:១៧:១៣]

**ស៖** សូមអរគុណ។ តំណាងសហព្រះរាជអាជ្ញាជាតិបានសួរលោក ហើយលោកបានឆ្លើយថា ស្រុកជីក្រែងគឺស្ថិតនៅក្នុងតំបន់ជាមួយ ស្ថិតនៅក្នុងតំបន់សៀមរាប។ តើលោកដឹងទេ នៅខាងជីក្រែងនេះ លេខាខាងជីក្រែងហ្នឹង គេរាយការណ៍ទៅខាងណាដែរ?

**ឆ៖** បាទ លេខាជីក្រែងហ្នឹងត្រូវរាយការណ៍ទៅឱ្យពួកតំបន់។ ពួកតំបន់វា ខ្ញុំក៏មិនស្គាល់ថាមេតំបន់អ្នកណាទេ ប៉ុន្តែថាត្រូវរាយការណ៍ទៅតំបន់សៀមរាប ឧត្តមានជ័យ។ វាដាក់តំបន់សៀមរាប

ឧត្តមានជ័យ។ ស្រុកជីក្រែងនៅក្រោមចំណុះតំបន់។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយ ហង់រី ឡូកា ក្នុងឆ្នាំ១៩៨១ លោកបានលើកឡើង តាសុត។ តើលោកនឹកឃើញទេ មានបុគ្គលម្នាក់លោកនិយាយថា ឈ្មោះ តាសុត នោះ តើគាត់ជានរណាដែរ?

**ឆ៖** បាទ ដល់ខ្ញុំក៏តាំងពីជាមួយ ហង់រី ឡូកា ក៏មានការភ្លេចដែរ ប៉ុន្តែថាដែលខ្ញុំទើបតែលោកសួរអំមិញគឺ តាសុត ហ្នឹងឯងគឺជាៗមេតំបន់។ គឺជាមេតំបន់សៀមរាប ឧត្តមានជ័យ។ ខ្ញុំ -- ប៉ុន្តែដល់ពេលនេះ ខ្ញុំក៏មានការភ្លេចភ្លាំងខ្លះ គឺ តាសុត ហ្នឹងឯងជាមេតំបន់សៀមរាប ឧត្តមានជ័យ។

**ស៖** តើលោកនៅចាំទេថា មានពេលមួយនោះដែលតំបន់សៀមរាបនោះ មិនមែនជាផ្នែកមួយនៃភូមិភាគទេ ក៏ប៉ុន្តែវាបែរទៅជាតំបន់ស្វ័យត ហើយត្រូវរាយការណ៍ទៅមជ្ឈិម។ តើលោកមានចាំនឹកឃើញអំឡុងពេលដែលមានស្ថានការណ៍អ៊ីចឹងកើតឡើងដែរឬទេ?

**ឆ៖** ចំពោះលោកសួរសំណួរនេះគឺខ្ញុំកន្លែងហ្នឹងមិនដឹងទេ ខ្ញុំមិនអាចឆ្លើយបាន។

[១៥:១៩:៥៨]

**ស៖** ខ្ញុំសូមសួរលោកអំពីប្រព័ន្ធទំនាក់ទំនង និងបញ្ជាអំណាច។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេត លោកបានលើកឡើងថា ចម្លើយសារភាពបានបញ្ជូនទៅគណៈកម្មាធិការស្រុកជីក្រែង ពីមន្ទីរសន្តិសុខរបស់លោក។ តើលោកអាចរៀបរាប់ទេ ឯកសារចម្លើយសារភាពនោះ គេរៀបចំដោយរបៀបខ្លះ? ដោយយ៉ាងម៉េចដែរ គេរៀបចំដោយយ៉ាងម៉េចដែរ? ហើយមានខ្លឹមសារយ៉ាងម៉េចដែរ នៅក្នុងចម្លើយសារភាពនោះ?

**ឆ៖** បាទ សូម ខ្ញុំសូមរាយការណ៍លម្អិតអំពីបញ្ហាដែលវាយករាយការណ៍ទៅកន្លែងស្រុក។ ដូច្នេះ គឺថាចំពោះអ្នកទោសដែលយកមកពីមូលដ្ឋាននានា មកកន្លែងសន្តិសុខស្រុកហ្នឹង គឺមេឃុំជាអ្នករាយការណ៍ ហើយក៏ចាត់កម្លាំងឲ្យទៅយក។ មានអ្នកទោសខាងផ្នែកសីលធម៌ក្តី អីក្តី។

[១៥:២១:០៤]

មកដល់ គឺវាដាក់ខ្នោះរួច ហើយដល់ថ្ងៃសួរចម្លើយ វាសួរកត់ត្រាបានជាចម្លើយហើយ អីហើយ បានវាបញ្ជូនឈ្មោះនោះ មកៗខាងស្រុក។ ហើយស្រុកគឺជាអ្នកសម្រេចថា តើបុគ្គលនេះ ត្រូវមានទោសកម្រិតណា? ដោះលែង ឬមួយក៏មានទោសរហូតដល់សម្លាប់? គឺថាខាង តាគុណ អី គឺមិនឃើញមានសម្រេចខ្លួនឯងទេ ឃើញថាមកសម្រេចពីកន្លែងស្រុក។ គឺការដែលយកមកហ្នឹង គឺមានតែប្រធានមួយ

ទេ ដែលយកមកកន្លែងស្រុក។ អានេះ គឺខ្ញុំដឹងច្បាស់។

**ស៖** ក្នុងពេលដែលលោកធ្វើការនៅទីនោះ នៅមន្ទីរសន្តិសុខ តើលោកជាអ្នករាយការណ៍អំពីចម្លើយសារភាពដែរឬទេ ដែលចម្លើយសារភាពនោះ ក្រោយគេបញ្ជូនទៅស្រុក?

**ឆ៖** អ្ហឺ! ចំពោះចម្លើយសារភាពហ្នឹង ខ្ញុំជាអ្នកកត់ត្រា ខ្ញុំមិនមែនសម្រេចខ្លួនឯងទេ គឺថាវាខាងមេសន្តិសុខហ្នឹង វាទៅឱ្យខ្ញុំសរសេរ ថាទោសយ៉ាងម៉េច គឺខ្ញុំជាអ្នកកត់ត្រា។ ដើម្បីបានជាឯកសារយកបញ្ជូនមកមេស្រុក។ ដូច្នេះ គឺសម្រេចនៅលើមេៗសន្តិសុខតែម្តង។

[១៥:២២:៥៩]

**ស៖** ខ្ញុំចង់ឲ្យលោកមើលកំណត់ហេតុសម្ភាសរបស់លោកជាមួយ ហង់រី ឡូកា នៅក្នុងឆ្នាំ១៩៩១ ដដែល។ ខ្មែរគឺលេខ 00812865, អង់គ្លេស ERN គឺ 00164156, បារាំងមានលេខ ERN 00779385។ តើលោកបាននិយាយចំណុចដូចខាងក្រោមនេះដែរឬទេ? សូមដកស្រង់សម្តី “របាយ-ការណ៍ត្រូវរាយការណ៍ទៅមេ បន្ទាប់មកពេលចូល ប.រ ជីបសែ ចម្លងរបាយការណ៍នោះចូលក្នុងសៀវភៅចេញចូល ដែលទុកនៅប្រធានកម្មាភិបាល”។ បន្ទាប់មកលោកឆ្លើយទៀតថា “អ្នកទោសមិនបានចុះហត្ថលេខាលើរបាយការណ៍នោះទេ ប៉ុន្តែអ្នកទោសផ្តិតមេដៃ”។ សំណួររបស់ខ្ញុំ សួរអំពីសៀវភៅចេញចូលដែលលោកបាននិយាយនៅក្នុងនេះ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ តើមានព័ត៌មានអ្វីខ្លះដែលសរសេរនៅក្នុងសៀវភៅចេញចូលនេះ? ហើយតើព័ត៌មាននៅក្នុងសៀវភៅចេញចូលនេះ បន្ទាប់មកបញ្ជូនទៅនរណាគេដែរ?

[១៥:២៤:២១]

**ឆ៖** បាទ ដូចខ្ញុំនិយាយហ្នឹង គឺថាចំពោះដែលសៀវភៅចេញចូលហ្នឹង គឺត្រូវយកមកឆ្លងកន្លែងស្រុក។ ឆ្លងហ្នឹង ដើម្បីអ្វី? ដើម្បីដឹងថាអ្នកនេះ ទោសស្រាល ឬធ្ងន់ ហើយដែលអ្នកសម្រេចចុងក្រោយគឺមេស្រុក។ ដូចខ្ញុំហ្នឹង គឺមេសន្តិសុខហ្នឹង គឺវាគ្រាន់តែរាយការណ៍ពីទោសកំហុស នៅក្នុងឯកសារថាអ្នកនេះ ទោសនេះ អ្នកនេះ ទោសនោះ ហើយត្រូវយកឯកសារដែលបានចម្លងហ្នឹង យកមកឲ្យស្រុកដើម្បីកំណត់ ថាត្រូវសម្លាប់ ឬមួយក៏ត្រូវដោះលែង? ឬមួយក៏កំណត់ថា ទុកប៉ុន្មានឆ្នាំ? ប៉ុន្មានខែ? ហើយបញ្ហាដែលថា រឿងផ្តិតមេដៃរឿងអីនោះ គឺខ្ញុំមកដល់ពេលនេះ គឺខ្ញុំភ្លេចហើយ។

**ស៖** តើលេខាស្រុក ដែលមានមកមន្ទីរសន្តិសុខរបស់លោកដែរឬទេ?

[១៥:២៥:៤៤]

**ឆ៖** បាទ មានគឺ ឈ្មោះ តាស៊ុន ពេលដែលគាត់មិនទាន់ចោទថា គាត់ក្បត់ហ្នឹង គាត់បានមកដល់កន្លែងសន្តិសុខ ជួបនិយាយជាមួយពួកសន្តិសុខ ហើយនិងពួកអ្នកទោសគឺថា គាត់បានមកហៅជុំគ្នាទាំងអ្នកទោសស្រី ប្រុសទាំងអស់ គាត់ចង់ជួបសម្ភាស។ ដូច្នេះឃើញម្តងនោះឯង ដែលខ្ញុំឃើញចៅហ្វាយស្រុកមកម្តង។

**ស៖** ពាក់ព័ន្ធទៅនឹងបញ្ហាអំណាចរបស់ខាងស្រុកវិញម្តង លោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេត ឯកសារលេខ D125/127 ខ្មែរត្រង់លេខ 00224053, អង់គ្លេសមានលេខ 00225212, បារាំងមានលេខ 00239979។ លោកបានឆ្លើយដូចតទៅ “មន្ទីរពង្រស្ថិតនៅក្រោមការក្តោបក្តាប់របស់ស្រុក ក្រោយពីមានបញ្ហាពីស្រុកគឺ មានការកាប់សម្លាប់ និងធ្វើ -- មានការកាប់សម្លាប់”។ ដូច្នេះ ខ្ញុំចង់សួរលោកតើគណៈកម្មាធិការស្រុកនោះ មានសេចក្តីសម្រេចឲ្យកាប់សម្លាប់ដោយពួកគាត់ហ្នឹង មានសេចក្តីសម្រេចអ៊ីចឹងតែម្តង ឬក៏ពួកគាត់ហ្នឹងចាំបាច់ទទួលបញ្ជាពីថ្នាក់លើមកទៀត ដែលត្រូវធ្វើការកាប់សម្លាប់នោះ គឺគាត់ទទួលបញ្ជាពីលើមកទៀត?

**ឆ៖** លោកសួរសំណួរនេះគឺថា ខ្ញុំក៏មិនដឹងថាគេហ្នឹងសម្រេចពីលើមកទៀត ឬយ៉ាងម៉េចទេ ប៉ុន្តែពេលដែល ឧទាហរណ៍ថា តាគុណ យកសំណុំរឿងមកឲ្យស្រុកហ្នឹង មកគឺខ្ញុំមិនដឹងថា គេសម្រេចយ៉ាងម៉េចអីយ៉ាងម៉េចទេ។ ប៉ុន្តែដល់ទៅពេលថា យកអ្នកទោសទៅសម្លាប់ហ្នឹង គឺវាមានអ្នកទោសខ្លះវាខ្វែងក្រហមៗ ហើយការខ្វែងក្រហមហ្នឹង ជួនកាលគឺអត់ឲ្យខ្ញុំដឹងទេ ពីព្រោះថាមានទោសដល់ស្លាប់ហើយ។ ហើយអ្នកទោសដែលមិនមានខ្វែងហ្នឹងគឺថា ត្រូវដោះលែង ឬមួយក៏ពន្យារឆ្នាំ អានោះគឺថា អាហ្នឹងវាច្រើនឲ្យខ្ញុំដឹង។ ដូច្នេះគឺថា ចំពោះស្រុកបញ្ជាពីលើទៀតគឺ អាហ្នឹងផុត ខ្ញុំមិនដឹងថាគេយ៉ាងម៉េចយ៉ាងម៉ាទេ។ ខ្ញុំដឹងថា ដល់ពេលឯកសារទៅដល់សន្តិសុខវិញ អានោះគឺ ខ្ញុំអាចរាយការណ៍ជូនលោកបាន ដឹងថាវាធ្វើម៉េចៗ។

[១៥:២៩:២២]

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេថា នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាមួយនឹងចៅក្រមស៊ើបអង្កេតលោកក៏បាននិយាយចំណុចហ្នឹងផងដែរថា ខាងស្រុកនោះមានបញ្ជូនឯកសារមកហើយឯកសារនោះគឺ មានលុបចោលជាអក្សរពណ៌ក្រហម ហើយមានចំណារផងដែរ។ តើឯកសារមកពីស្រុកគេបញ្ជូនមកហ្នឹង ឯកសារហ្នឹងជាឯកសារប្រភេទអ្វីដែរ?

**ឆ៖** អេ៎ ខ្ញុំសូមចង់ប្រាប់លោកថា ចំពោះស្រុកដូចជាគ្មានសរសេរជាឯកសារមកទេ គឺវាគួស

លើឈ្មោះដែលបញ្ជូនទៅតែម្តង។ ដូចឧទាហរណ៍ថា ឈ្មោះ ក ដែលបញ្ជូនទៅ បើថាឈ្មោះ ក ហ្នឹងត្រូវសម្លាប់វាគូសខ្វែងមក។ ហើយបើឈ្មោះ ខ ដែលថាត្រូវដោះលែងក៏វាអត់មានគូសអ្វីទេ។ ហ្នឹងគឺដែលខ្ញុំឃើញហ្នឹងគឺជាក់ស្តែងអ៊ីចឹង ត្រង់ថាចំណារ ថាយ៉ាងម៉េចគឺគ្មាន។ គឺថាគ្រាន់តែវា អ្នកដែលត្រូវវាសម្លាប់គឺវាគូសក្រហម ហើយអ្នកដែលដោះលែងវាអត់គូសអ្វីទាំងអស់។ អានេះគឺខ្ញុំបានឃើញជាក់ស្តែង។

**លោក ឌេល លីសាក់៖**

ខ្ញុំថ្លែងអំណរគុណ ដែលលោកចំណាយពេលឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំក្នុងថ្ងៃនេះ។ លោកប្រធានសំណួរទាំងអស់ ដែលយើងខ្ញុំបានសួរហ្នឹង គឺវាចប់សព្វគ្រប់រួចរាល់ហើយសម្រាប់ខាងយើងខ្ញុំ។ សូមអរគុណលោកប្រធាន។

[១៥:៣១:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកា ជូនទៅក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិមានឱកាស ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក វ៉ែន ពៅ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពតំណាងសហព្រះរាជអាជ្ញា និងសូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំបាទឈ្មោះ វ៉ែន ពៅ ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរពីរបីសំណួរទេ ដែលសួរលោកនៅពេលនេះ ដើម្បីបញ្ជាក់បន្ថែមនូវអ្វីដែលសហព្រះរាជអាជ្ញាបានសួរលោករួចហើយ។ ខ្ញុំសូមលើកកំណត់ហេតុស្តាប់របស់សាក្សី គឺកំណត់ហេតុដែលបានធ្វើឡើងកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ នៅ -- ដែលមានលេខឯកសារគឺ D125/127, ERN ជាភាសាខ្មែរគឺលេខ 00224051 និង ERN ជាភាសាអង់គ្លេស 00225210 និង ERN ជាភាសាបារាំង 00239976។ នៅក្នុងសំណួរចម្លើយនេះផងដែរ លោកសាក្សីបានបញ្ជាក់រួចហើយថា “ក្រោយថ្ងៃ១៧

មេសា ឆ្នាំ៧៥ ខ្ញុំបានឃើញគេជម្លៀសទាហាន និងអតីតអ្នករដ្ឋការ លន់ នល់ ពីខេត្តសៀមរាបមកដាក់តាមផ្ទះចាស់ៗនៅភូមិជីក្រែង"។ ហើយលោកសាក្សីក៏បានឆ្លើយតបនឹងសហព្រះរាជអាជ្ញាផងដែរថា "មិនត្រឹមតែបានឃើញការជម្លៀសទាហាន លន់ នល់ ក៏ដូចជាអតីតអ្នករដ្ឋការនៃរបបលន់ នល់ ទេ លោកថែមទាំងបានឃើញប្រជាជនធម្មតា ដែលត្រូវបានជម្លៀសចេញពីខេត្តសៀមរាបមកស្រុកជីក្រែងផងដែរ"។

[១៥:៣៣:០៦]

ក្នុងនោះលោកក៏បានបញ្ជាក់ទៀតដែរថា មិនត្រឹមតែមកពីខាងភាគខេត្តសៀមរាបទេ លោកបានដឹងថា មានប្រជាជនត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញមកតាមផ្លូវ -- បើតាមខ្ញុំយល់មិនច្រឡំគឺតាមផ្លូវខេត្តកំពង់ធំមកដូចគ្នាដែរ។ សំណួររបស់ខ្ញុំចង់សួរលោកថា តើក្រៅពីប្រជាជនធម្មតាដែលលោកបានឃើញ ដែលលោកបានរៀបរាប់រួចហើយ តើលោកមានសង្កេតឃើញ ឬក៏បានដឹង ឬក៏បានឮមានគេនិយាយប្រាប់លោកថា មានព្រះសង្ឃត្រូវបានគេនិមន្ត ឬក៏ជម្លៀសនៅពេលនោះដែរទេបាទ?

**លោក ប៉េជុយ ជីបសែះ**

**ឆ៖** បាទ ខ្ញុំជម្រាបសួរលោកមេធាវី គឺចំពោះមេ -- លោកមេធាវីសួរថា អ្នកជម្លៀសតើវាមានព្រះសង្ឃដែរឬទេ? ចំពោះរូបខ្ញុំហ្នឹងក៏វាដឹងគឺមិនបានជាខ្លាំងក្លាទេ ពីព្រោះថាក្នុងពេលនោះ គឺខ្ញុំវានៅជាមួយខ្មែរក្រហម ធ្វើការនៅកន្លែងសន្តិសុខពង្រហ្នឹង គឺបានដឹងតែត្រឹមតែថា ប្រជាជន ១៧មេសា ហើយនិងមន្ត្រីរដ្ឋការ ទាហាន ដែលវាយកមកពីសៀមរាប ប៉ុណ្ណឹងឯង។ គឺសូមលោកមេធាវី គឺថាខ្ញុំមិនអាចឆ្លើយរួចនឹងសំណួរនេះ ដោយសារអត់ដឹងតែម្តង។

[១៥:៣៤:៤៣]

**ស៖** បាទ សូមអរគុណ។ ភ្ជាប់ជាមួយសំណួរនេះផងដែរ ខ្ញុំក៏ចង់បញ្ជាក់ថាតើ -- ចុះលោកមានបានឮ ឬក៏បានឃើញ ឬក៏បានមានគេនិយាយប្រាប់ថា ក្រៅពីប្រជាជន ឬក៏អ្នកដែលលោកបានរៀបរាប់ហ្នឹង តើមានដូចជានៅការជម្លៀសទាំងពីរ ទាំងមកពីខាងសៀមរាប ទាំងមកពីខាងភ្នំពេញ តើមានចាស់ជរា ស្ត្រី កុមារ ឬក៏អ្នកពិការ ឬប្រភេទមនុស្សបែបណាខ្លះ? តើលោកមានបានឮ ឬបានសង្កេតឃើញប្រភេទមនុស្សទាំងអស់នោះខ្លះទេបាទ?

**ឆ៖** បាទ លោកមេធាវីត្រង់ចំណុចនេះគឺថា ខ្ញុំក៏ដឹងថាការៗជម្លៀសអ្នក១៧មេសា ពីសៀមរាបក្តី ពីភ្នំពេញក្តី គឺថាវាមានគ្រប់ទាំងអស់។ វាមានទាំងពីអ្នកពិការ មានទាំងពីស្ត្រី មានទាំងពី

ចាស់ជរាផ្សេងៗហ្នឹងគឺថា មិនខ្វះមួយណាទេ វានៅចន្លោះត្រង់ថារឿងព្រះសង្ឃហ្នឹងគឺក៏មិនបានដឹង។ ដូច្នេះគឺខ្ញុំដឹងថា តាមរយៈប្រយោលទេគឺថាវាមិនបានទូលំទូលាយទេ ដូចលោកមេធាវីសួរហ្នឹងគឺ បើត្រង់ថាក្មេងចាស់ ប្រុស ស្រី អ្នកពិការហ្នឹងគឺមានគ្រប់សព្វទាំងអស់ហើយ គឺខណៈចូលមកក្នុងទឹកដីស្រុកជីក្រែងហ្នឹងមាន ព្រោះអានេះគឺខ្ញុំដឹងតាមរយៈដូចថា គេប្រាប់ខ្ញុំទេ ពេលវាមិនបានដែលថាយើងឃើញឲ្យវាពិតប្រាកដអីទេបាទ។

[១៥:៣៦:២៨]

**ស៖** បាទ ពាក់ព័ន្ធនឹងការជម្លៀសទាំងពីរទិសដៅនេះដែរ ខ្ញុំចង់បញ្ជាក់បន្ថែមពីលោកផងដែរថា តើលោកបានឃើញ ឬក៏បានឮ ឬក៏មានអ្នកណានិយាយប្រាប់លោកថា តើមធ្យោបាយនៃការធ្វើដំណើរនៃការជម្លៀសទាំងពីរនេះ តើគេប្រើប្រាស់មធ្យោបាយអ្វីខ្លះទៅបាទ?

**ផ៖** បាទ លោកមេធាវី សំណួរនេះគឺខ្ញុំសូមឆ្លើយថា ការធ្វើដំណើរហ្នឹងគឺដោយថ្មើរជើងតែម្តង។ គឺអ្នកជម្លៀសគ្មានអ្វីទេ លំបាកណាស់ គឺមកដល់គឺខ្លះក៏មានការស្លាប់ប្រពន្ធ ស្លាប់ប្តី ទម្រាំតែមកដល់ ពីព្រោះចម្ងាយដូចលោកមេធាវីឃើញហើយពីភ្នំពេញទៅ ខ្លះក៏នៅជិតទៅ ខ្លះក៏គេឲ្យទៅដល់ទៅស្រុកជីក្រែង ពីនេះទៅវាប់រយគីឡូ បើមកពីសៀមរាបអានោះវាមិនសូវអីទេ។ ដូច្នេះហើយខ្ញុំបានដឹងតែប៉ុណ្ណឹងឯង។

**ស៖** បាទ សូមអរគុណ។ តើលោកមានសង្កេតទេ តើនៅពេលធ្វើដំណើរនៃការជម្លៀសរបស់ប្រជាជនទាំងនោះ តើលោកមានបានសង្កេតឃើញថាគេមានផ្តល់ជាស្បៀងអាហារ ឬក៏ថ្នាំសង្កូវអីទេនៅតាមផ្លូវ លោកបានឮ ឬក៏លោកបានឃើញដែរទេពីបញ្ហានេះបាទ?

[១៥:៣៨:១១]

**ផ៖** ខ្ញុំបានជួបនឹងអ្នកដែលជម្លៀសផ្ទាល់គឺថា អត់មានអ្នកផ្តល់អ្វីទាំងអស់ គឺថាមកហ្នឹងគឺលំបាកលំបិនមែនទែន គឺបើនិយាយពីថាតែងពីការលំបាកវេទនាហ្នឹង គឺរាប់មិនអស់ទេលោកមេធាវីគឺថាអ្នក១៧មេសាគ្នាស្លាប់ច្រើនណាស់ ដោយសារគ្នា -- ជាពិសេសគឺអត់អាហារ ហើយពេលឈឺអីគឺគ្មានថ្នាំព្យាបាលអីទេ អត់មានថ្នាំអីទេ។ កុំឲ្យតែគេចោទថាក្បត់ទៅទៀតចុះ គឺវេទនាណាស់ អានេះគឺខ្ញុំថ្លាថ្លែងមិនរួចទេ សូមលោកមេធាវីអនុគ្រោះគឺថា វាច្រើនណាស់ដែលលំបាកបាទ។

**ស៖** ខ្ញុំសូមបញ្ជាក់ផងដែរ ថាលោកបានជម្រាបមកសហព្រះរាជអាជ្ញារួចហើយកាលពីព្រឹកមិញថា ស្រុកជីក្រែងទាំងមូលនេះគឺជាតំបន់រំដោះដែលត្រូវបានរំដោះតាំងពីឆ្នាំ១៩៧២។ ខ្ញុំចង់សួរលោក

ថា មុន ១៧ មេសា ឆ្នាំ១៩៧៥ តើនៅមូលដ្ឋាន ឬក៏ដូចជានៅតាមសហករណ៍មានប្រជុំណែនាំ ឬក៏រៀបចំចាំទទួលប្រជាជនថ្មីដែរឬទេបាទ?

**ឆ៖** បាទ លោកកន្លែងដែលថា លោកថាចាំទទួលប្រជាជនថ្មីហ្នឹង គឺគ្មានទេ។ មានតែរឿងចោទប្រកាន់ថាក្បត់តែម្ដង គឺអត់មានទទួលស្វាគមន៍អី ប្រជុំអីទេ គឺ ពីព្រោះវា និយាយទៅគោលនយោបាយរបស់វាគឺវាមិនពេញចិត្តជាមួយអ្នកជម្លៀសតែម្ដង។ នេះគឺថាខ្ញុំមើលទៅស្រុកជីក្រែងគ្មានទេ គឺបែងចែកថាអ្នកជម្លៀសផ្សេង អ្នកមូលដ្ឋានផ្សេងហើយ អត់មានស្វាគមន៍បន្តិចទេ។ នេះគឺជាការពិត។

**ស៖** បាទ សូមអរគុណ។ សំណួរខ្ញុំមួយទៀតពាក់ព័ន្ធនឹងបញ្ហាស្ថានភាពប្រជាជនថ្មី ដែលលោកបញ្ជាក់រួចហើយថា គឺជាពួក១៧មេសា។ ខ្ញុំចង់សួរលោកឱ្យលោកបញ្ជាក់ឱ្យបានច្បាស់ថែមទៀតថាតើនៅពេលដែលប្រជាជនថ្មី ដែលត្រូវបានគេជម្លៀសយកទៅលោកបានបញ្ជាក់ហើយ ថាគេយកទៅដាក់នៅទីដាច់ស្រយាល កន្លែងតាមសហករណ៍ តាមមូលដ្ឋាន ផ្ទះមូលដ្ឋានចាស់ៗ។ ខ្ញុំចង់សួរថាតើការបែងចែកការងារ ក៏ដូចជារបបអាហារ មានភាពខុសប្លែកគ្នាទេរវាងមូលដ្ឋានចាស់ ហើយនិងពួក១៧មេសា បាទ?

[១៥:៤១:៤៧]

**ឆ៖** ចំពោះសំណួរនេះ គឺខ្ញុំចង់និយាយថា ពេលដែលអ្នក១៧មេសា ដែលវាជម្លៀសទៅនៅតាមតំបន់ដាច់ស្រយាលជនបទនោះ គឺវាបង្កើតជាសហករណ៍ទៅហើយ ឱ្យមានជាសហករណ៍ក្នុងការហូបរួម ទាំងមូលដ្ឋានទាំងអីទាំងអស់។ អាហ្នឹងគឺវាអត់មានបែងចែកទេ គឺថាតែញជួង គឺត្រូវតែកាន់ចានទៅកន្លែងសហករណ៍ហើយ គឺអត់មានបែងចែងទេ។ ប៉ុន្តែវាៗកន្លែងហ្នឹងវាធ្វើស្មើភាព ប៉ុន្តែអាកន្លែងដែលខ្ញុំចង់និយាយថា វាប្រកាន់ត្រង់ថា អ្នក១៧ហ្នឹង វាឱ្យគ្នាវាចាត់ទុកថាជាជនដែលៗធ្លាប់រស់នៅជាមួយ លន់ នល់។ ដូច្នេះហើយវាឱ្យធ្វើជាមួយទាំងទើសទាល់ វាឱ្យហូបទាំងមើលងាយមើលថោក អាហ្នឹងគឺខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បាទ ភ្ជាប់នឹងសំណួរនេះផងដែរ ខ្ញុំចង់សួរលោក ថាតើលោកអាចបញ្ជាក់បានទេរវាងសិទ្ធិសេរីភាពវិញ រវាងពួក១៧មេសា និងពួកមូលដ្ឋានចាស់ តើមានភាពខុសគ្នាប្លែកគ្នាយ៉ាងណាដែរបាទ?

[១៥:៤៣:២៧]

**ឆ៖** បាទ លោកគឺថាខុសប្លែកខ្លាំងណាស់ ពីព្រោះការងារធ្ងន់ គឺវាឱ្យអ្នក១៧ ទៅហើយ ហើយការងារណាស្រួល អាហ្នឹងពួកមូលដ្ឋាន។ ហើយនាទីគឺអ្នក១៧ គ្មាគ្មានទេ នៅក្រោមបញ្ជាពួក

មូលដ្ឋាន។ ដូច្នេះហើយគ្នាក៏អត់បាយក្រហាយទឹក អាហ្នឹងគឺថាវាហួសថ្លាថ្លែង ដូចខ្ញុំនិយាយ លោកមេធាវីដឹងហើយ។ ដូច្នេះគ្នាឈឺថ្កាត់ក៏មិនឱ្យគ្នាថ្នាំគ្នា។ ដូច្នេះ អ្នក១៧ គឺស្លាប់ច្រើនណាស់។ នេះគឺអស់ប៉ុណ្ណឹង។

**លោក វ៉េន ពៅ៖**

សូមគោរពលោកប្រធាន។ ខ្ញុំសូមអានឯកសារដដែលគឺ D125/127 ត្រង់ ERN ជាភាសាខ្មែរគឺ 00224052 និង ERN ជាភាសាអង់គ្លេស 00225211, ERN ជាភាសាបារាំង 00239977។

**សួរដោយលោក វ៉េន ពៅ៖**

**ស៖** នៅក្នុងនេះពាក់ព័ន្ធនឹងបញ្ហាខុសសីលធម៌ ក្នុងនេះខ្ញុំសូមអាន "អ្នកទោសដែលខ្ញុំបានដឹង គឺអ្នកប្រឆាំងអង្គការ ខ្លះទៀតជាសមាសភាពដែលត្រូវគេសង្ស័យថា ជាប់ទាក់ទងជាមួយវៀតណាម អ្នកខ្លះខុសសីលធម៌ជាដើម"។ សំណួររបស់ខ្ញុំដែលនឹងសួរលោក ថាតើលោកនៅក្នុងមន្ទីរសន្តិសុខកន្លែងដែលលោកធ្វើការនោះ នៅក្នុងក្រុមរបស់លោកនោះ តើគេមានប្រជុំអប់រំពីវគ្គខុសសីលធម៌បែបណាៗទេបាទ? លោកដែលធ្លាប់បានរៀនវគ្គ ថាប្រភេទ គេកំណត់អត្តសញ្ញាណថាប្រភេទណាជាប្រភេទខុសសីលធម៌ ហើយទោសទណ្ឌនឹងត្រូវទទួលដោយវិធីណា បែបណាទេបាទ?

**ឆ៖** ខ្ញុំចង់និយាយថាពាក្យដែលវាថា "ខុសសីលធម៌" គឺថាបានន័យថា យុវជន យុវនារី ដែលវាត្រូវធ្វើការនៅកងចល័តហ្នឹង គឺថាវាបានចាកប្រពៃណីមុន គឺថាយើងថាមុនពេលរៀបការណ៍។ ដូច្នេះហើយវាដឹងថាខុសអ៊ីចុះហើយ វាត្រូវជួនកាលវាយកទាំងពីរទៅ ជួនកាលវាយកតែប្រុសទៅទេ ដើម្បីយកទៅកសាង។ ប៉ុន្តែទោសខុសសីលធម៌ហ្នឹងវាៗភាគច្រើន ដែលវាចាត់ទុកហ្នឹងគឺខុសនឹងចំណុចហ្នឹង។ ហើយប្រជាជនចាស់ៗដែលខុសសីលធម៌ក៏ខុសអ៊ីចឹងដែរ ដូចថាទៅស្រលាញ់ប្រពន្ធគេលួចលាក់ស្រលាញ់ប្តីគេលួចលាក់អីទៅ។ ដល់មូលដ្ឋានគេដឹងទៅ គេនាំយកទៅដាក់នៅគុកសន្តិសុខពង្រហ្នឹងទៅ។ ប៉ុន្តែទោសហ្នឹងវាមិនដល់ស្លាប់ទេ គឺទោសស្រាលទេ។ នេះគឺខ្ញុំសូមប្រាប់លោកមេធាវី។

[១៥:៤៦:៤៥]

**ស៖** បាទ ពាក់ព័ន្ធនឹងការខុសសីលធម៌នេះផងដែរ ខ្ញុំចង់សួរលោកថាតើលោកដែលមានសង្កេតឃើញការខុសសីលធម៌តែរវាងមូលដ្ឋានចាស់ និងមូលដ្ឋានចាស់ តើមានការខុសសីលធម៌រវាងមូលចាស់ឬក៏កងឈ្លប ឬយោធាជាមួយនឹងពួក១៧ មេសា ហើយត្រូវបានគេបញ្ជូនមកមន្ទីរឃុំឃាំងលោកទេបាទ?

**ផ៖** ត្រង់ចំណុចដែលលោកមេធាវីសួរហ្នឹងគឺថាខ្ញុំឆ្លើយថា មាន ពីព្រោះការខុសហ្នឹងវាមិនៗ មែនថាបែងចែកថាមូលដ្ឋាន និងមូលដ្ឋានទេ វាមានជួនកាលអ្នកមូលដ្ឋានវាជាឈ្លបក្ដី វាខូចជាមួយនឹងអ្នក១៧មេសា ក៏មានដែរ។ វាច្រើនៗប្រភេទណាស់ អារឿងខុសហ្នឹង។ វាមានខ្លះប្ដីគេ ប្រពន្ធគេ ហើយ -- ប៉ុន្តែភាគច្រើនវា ភាគច្រើនបើខ្ញុំមើលទៅវាចាប់ទៅកន្លែងហ្នឹង វាច្រើនតែយុវនារីតែម្ដង ប៉ុន្តែថាវាមិនបានដឹងថា អ៎! វាមានអ្នកៗមូលដ្ឋានជាមួយនឹងអ្នក១៧ ដែរណ៎ា គឺថាមិនអត់ទេ គឺមាន ព្រោះវាច្រើនដែរ។ ហ្នឹងគឺឆ្លើយប៉ុណ្ណឹង។

[១៥:៤៨:០២]

**ស៖** បាទ សូមអរគុណ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់សួរលោកថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ក្នុងឋានៈលោកធ្លាប់ជាអ្នកបម្រើការមួយរូបដែរ ខ្ញុំចង់សួរថាតើលោកដែលធ្លាប់ឮសេចក្ដីថ្លែងការណ៍ ឬក៏ស្ដាប់វិទ្យុពាក់ព័ន្ធនឹងមេដឹកនាំខ្មែរក្រហមដែរទេបាទ?

**ផ៖** ត្រង់ចំណុចដែលលោកសួរថា ឲ្យដឹងអំពីហេតុការណ៍ សេចក្ដីថ្លែងការណ៍អីផ្សេងៗគឺកន្លែងហ្នឹងខ្សោយបំផុត ដូចជាមិនសូវមានៗ។ វាមានជាការដូចថាវាប្រជុំនៅក្នុងអង្គភាពអី អាហ្នឹងមាន។ ត្រង់ថាឲ្យស្ដាប់សេចក្ដីថ្លែងការណ៍ពីលើពីអីទៅ គឺដូចជាគ្មានទេ។ គ្រាន់តែមានការប្រជុំនៅក្នុងសន្តិសុខហ្នឹង ប្រជុំរវាងអ្នកធ្វើការផ្សេងទៅ ហើយជួនកាលបើមានហេតុអីមិនស្រួលវាប្រជុំអ្នកទោសទាំងអស់ ណែនាំពីបញ្ហាខំកសាងខ្លួនដើម្បីឲ្យបានឆាប់ចេញទៅមូលដ្ឋានវិញ គឺថាវាមាន គឺកន្លែងហ្នឹងគឺមាន បាទ។

[១៥:៤៩:២៨]

**ស៖** បាទ ខ្ញុំៗចង់បញ្ជាក់បន្ថែមទេ ថាតើលោកដែលធ្លាប់មានគេប្រាប់ ឬក៏មានថ្នាក់ដឹកនាំរបស់លោកប្រជុំប្រាប់ថាតើលោកដឹងពីតួនាទីរបស់ជនជាប់ចោទនៅទីនេះ ថាលោក នួន ជា គាត់មានតួនាទីអ្វី? លោក ខៀវ សំផន មានតួនាទីជាអ្វី? ឬក៏លោក អៀង សារី មានតួនាទីជាអ្វីដែរទេ? មានដែលគេប្រាប់លោកឬទេនៅក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យនោះបាទ?

**ផ៖** បញ្ហាហ្នឹង គឺថាក្នុងអង្គភាព គឺប្រាប់ទាំងអស់ លោក។ គឺថាចំពោះមេទំនងកំពូលហ្នឹង គេប្រាប់អំពីតួនាទី ដែលដូចជាថា ខៀវ សំផន ជាគណៈប្រធានរដ្ឋ, ប៉ុល ពត ជាមេបក្សកុម្មុយនីស្តកម្ពុជាអី គឺវាប្រាប់តួនាទី។ ប៉ុន្តែប្រាប់តួនាទីហ្នឹង វាច្រើនតែមាន ប៉ុល ពត, ខៀវ សំផន, អៀង សារី ដូចមិនសូវជាឮប៉ុន្មានទេ។ វាដូចជាមិនសូវឮសួរប្រាប់ទេ ដូច្នេះហើយវាចាំបានតែ ប៉ុល ពត, ខៀវ សំផន។

នាទីជាអ្វីៗ គឺវាតែងប្រាប់ដែរ។

[១៥:៥១:០៣]

**លោក វ៉ែន ពៅ៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ខ្ញុំសូមសហភាតាខ្ញុំ សួរបន្ត។ សូមអរគុណ បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបអស់លោក លោកស្រី ហើយសូមជម្រាបលោកសាក្សី។

**សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី៖**

**ស៖** ខ្ញុំចង់និយាយបន្ថែមអំពីកាជម្លៀសប្រជាជនស៊ីវិលពីសៀមរាប។ តើលោកដឹងដែរឬទេ ធ្លាប់មានប្រជាជនស៊ីវិលណាមួយ ដែលបដិសេធមិនចាកចេញពីទីក្រុងដែរទេ នៅពេលនោះ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ខ្ញុំសំណួរនេះ ខ្ញុំមិនអាចឆ្លើយបានទេ ពីព្រោះថា វាផុតភារកិច្ចរបស់ខ្ញុំ មិនដឹងថាមានប្រជាជនណាដែលមិនបានចាកចេញពីសៀមរាប ពីព្រោះខ្ញុំមិនដឹងតែម្តង។ សូមឆ្លើយមិនរួចទេ។

**ស៖** សូមអរគុណលោក។ តើលោកដឹង ឬក៏លោកធ្លាប់ដឹងអំពីព្រឹត្តិការណ៍ណាមួយ ដែលទាហានខ្មែរក្រហមបង្ខំឲ្យប្រជាជនជម្លៀសចេញពីទីក្រុងដែរឬទេ?

**ឆ៖** ចំពោះសំណួរនេះ គឺខ្ញុំសូមនិយាយតាមការដឹងឮពីប្រជាជនទេ គឺថានៅពេលដែលវាជម្លៀសប្រជាជនពីខេត្តសៀមរាប គឺពួកវាប្រើអំណាច គឺបាញ់រះទៅលើ ដើម្បីបង្អើល។ បើប្រជាជនណាដែលមិនចាកចេញគឺត្រូវទទួលទោស គឺសម្លាប់ ឬមួយក៏យកទៅដាក់គុកជាដើម។ ដូច្នេះ អ្នកដែលៗវាត្រូវឲ្យជម្លៀសហ្នឹង គឺគ្នាមិនរឹងទទឹងបានទេ គឺត្រូវតែចាកចេញតែម្តង។

[១៥:៥៣:៣០]

**ស៖** មុននេះ លោកបានបញ្ជាក់ថា មានឃើញសាកសពនៅតាមផ្លូវ ក្នុងពេលដែលគេជម្លៀសប្រជាជន។ តើលោកដឹងទេថា ហេតុអីបានជាប្រជាជនហ្នឹងស្លាប់? ហើយគាត់ស្លាប់ហ្នឹង ដោយរបៀប

ណាដែរ?

**ឆ៖** បាទ ចំពោះប្រជាជនដែលជម្លៀសមកស្ដាប់ហ្នឹង គឺដោយសារ ទី១ គឺអត់បាយ។ ទី២ ជួនកាល គាត់មានជំងឺតាមផ្លូវ មិនដឹងជាពឹងពីណាទេ គឺត្រូវតែតាមយថាកម្ម គឺត្រូវស្លាប់តាមផ្លូវ។ ក្មេងគ្មានអ្វីនឹងទឹកដោះគោឲ្យផឹកអីទេ គឺន័យស្លាប់ហ្នឹង គឺវាអាណោចអាធ័មណាស់ ខ្ញុំរៀបរាប់ទៅ វាមិនអាចរៀបរាប់អស់ទេ។ សូមអស់ប៉ុណ្ណឹង។

**ស៖** សូមអរគុណលោក។ តើលោកមានទទួលបានបញ្ជាក្នុងការប្រព្រឹត្ត ឬក៏ក្នុងការធ្វើដាក់ប្រជាជន១៧មេសា ដែលគេយកមកស្រុកហ្នឹង តើលោកមានទទួលបានបញ្ជាថាត្រូវបែបណា អីបែបណានោះទេ?

**ឆ៖** បាទ ចំពោះបញ្ហាអ្នក១៧មេសា ហ្នឹង គឺខាងសន្តិសុខពង្រហ្នឹង គឺអត់មាន។ អាហ្នឹងនិយាយទៅ ពួកមូលដ្ឋានជាអ្នកទទួលតែម្ដង តាមឃុំ តាមអី ទទួល។ អាហ្នឹងវាផុតពីការទទួលរបស់សន្តិសុខពង្រហើយ។ ប៉ុន្តែដែលថាអ៊ីចេះ គឺត្រង់ថា បើពួកឃុំវាស្អប់វាអី វារាយការណ៍ថា អ្នក១៧ហ្នឹងវាមិនព្រមធ្វើការក្ដី វាគេចវេះសក្ដីអាហ្នឹងបានសន្តិសុខហ្នឹង គឺមកយកអ្នក១៧ ហ្នឹងទៅកសាងនៅមន្ទីរហ្នឹង។ អាហ្នឹងគឺមាន។ ត្រង់ថាដឹងថា ផ្សេងពីនោះទៀតគឺអត់ដឹងទេ ខាងសន្តិសុខនោះ អត់ដឹងទេ។

[១៥:៥៥:៥៨]

**ស៖** ប្រជានជន ១៧មេសា -- តើមានប្រជាជន ១៧មេសា ណាខ្លះដែលគេនាំយកមកមន្ទីរពង្រហ្នឹងដែរទេនៅពេលដែលលោកនៅទីនោះ?

**ឆ៖** ចំពោះសំណួរហ្នឹង គឺថាខ្ញុំមិនអាចចាំបានថា ចំនួនអីទេ គឺថាមានអ្នក១៧មេសា ជាច្រើនដែរ ដែលវា ដែលពួកមូលដ្ឋានបញ្ជូនទៅ។ មានខ្លះក៏ជាសីលធម៌ ដូចខ្ញុំនិយាយប្រាប់មុននោះ គឺមានជាសីលធម៌ មានជាការលួច ដោយសារស្រេកឃ្លានអីទៅ។ ទី២ គឺភាគច្រើនគឺដោយសារវាចាត់តាំងឲ្យទៅធ្វើការធ្ងន់ៗ គ្នាវាឈឺ វាអី ដូច្នេះហើយវាក៏យកលេសថា ឈឺខ្ជិល ឈឺអីទៅ វាគ្នាទៅយកទៅកសាងនៅកន្លែងសន្តិសុខពង្រទៅ។ អាហ្នឹងគឺថា ទោសរបស់អ្នក១៧ ហ្នឹងគឺថា មានច្រើនជាងនេះទៀត ប៉ុន្តែខ្ញុំចាំបានតែប៉ុណ្ណឹង។

**ស៖** សូមអរគុណលោក។ ដូច្នេះ ក្នុងតួនាទីលោកជាស្មៀនរបស់មន្ទីរឃុំឃាំងនោះ តើលោកអាចបញ្ជាក់ច្បាស់ថា មានការបែងចែកថា អ្នកណាជាអ្នក១៧មេសា ឬក៏អត់ទេ នៅពេលដែលលោកធ្វើការកត់ត្រានោះ?

**ឆ៖** បាទ គឺចំពោះសំណួរនេះគឺថា មានការបែងចែកច្បាស់ណាស់ ពីព្រោះនិយាយទៅរបប ហ្នឹងវាមិនស្រលាញ់អ្នក១៧មេសា ប៉ុន្មានទេ។ ហ្នឹងទិសដៅរបស់វា គឺចង់ថាឲ្យផុតពូជអ្នក១៧ តែម្តង។ ប៉ុន្តែមានអ្នកខ្លះដែលគេដឹងនូវបញ្ហាហ្នឹងក៏បានរួចរស់ជីវិតទៅ។ ខ្លះដែលមិនបានដឹង ធ្វើគធ្វើថ្លង់ទៅ ក៏គេយកទៅសម្លាប់ទៅ។ ដោយវានឹកឃើញថា ពួក១៧ ហ្នឹង ច្រើនជាអ្នករដ្ឋការ ជាទាហាន ជាអ្នកមន្ត្រីរាជការ គ្រូបង្រៀន។ ដូច្នេះហើយវាគឺបែងចែកទោះជានៅក្នុងនោះក៏វានៅតែបែងចែកឲ្យធ្វើការធ្ងន់ បើសិនជាអ្នក១៧ ទៅ។ នេះគឺខ្ញុំឆ្លើយប៉ុណ្ណេះ។

[១៥:៥៨:៥៣]

**ស៖** សំណួររបស់ខ្ញុំគឺ និយាយជាក់លាក់អំពីមន្ទីរសន្តិសុខពង្រ។ ខ្ញុំចង់សួរលោកថា ថាតើលោកទទួលបានបញ្ជាឲ្យធ្វើការកត់ត្រាថា អ្នកទោសហ្នឹងជាអ្នក១៧មេសា ឬក៏អត់ តើលោកមានទទួលការបញ្ជាឲ្យធ្វើបែបនេះដែរឬទេ?

**ឆ៖** បាទ គឺទទួលបញ្ជាបែបនេះ ពិតប្រាកដ។ គឺវាឲ្យថា ដឹងថា អ្នកទោសហ្នឹងជាប្រភេទមូលដ្ឋាន អ្នកដែលនៅក្នុងភូមិ ឬមួយក៏ជាអ្នក១៧។ ដូច្នេះ ពួកវាថ្នាក់លើគឺវាឲ្យខ្ញុំបែងចែកច្បាស់ មិនឲ្យដាក់ច្រឡូកច្រឡំគ្នាទេ។ បាទ គឺផ្សេងគ្នា។

**ស៖** តើអ្នកទោសដែលជាពួក១៧មេសា ហ្នឹងត្រូវបានគេប្រព្រឹត្តខុសពីអ្នកទោសមូលដ្ឋាន ឬក៏គេធ្វើដូចគ្នាទេ នៅមន្ទីរសន្តិសុខរបស់លោកនោះ?

**ឆ៖** បាទ គឺធ្វើខុសគ្នា គឺមិនធ្វើដូចគ្នាទេ។ ពួកវាគឺដាក់អ្នក១៧ គឺផ្សេង បើសិនជានៅជាមួយគឺនៅក្នុងដូចថា យើងជាកូនចៅគេ។ ឲ្យអ្នកមូលដ្ឋានទទួលជាមេ ហើយអ្នក១៧ គឺជាកូនចៅ ទៅណាមកណាវាអង្គុយមើលទៅ ហើយអ្នក១៧ អ្នកធ្វើការងារទៅចម្ការក្តី ស្ទូង ធ្វើស្រែភ្លឺក្តី លើកភ្លឺ គ្រប់មុខគឺអ្នក១៧ គឺទទួលរងនូវការលំបាកជាងអ្នកមូលដ្ឋាន។ ហ្នឹងគឺជាការពិត។

**ស៖** សូមអរគុណលោក។ តើលោកធ្លាប់ឃើញគេធ្វើបាប ឬក៏គេវាយអ្នកទោសដែរឬទេ នៅពេលដែលលោកនៅក្នុងមន្ទីរនោះ?

[១៦:០១:១៣]

**ឆ៖** បាទ គឺវា -- ខ្ញុំក៏ធ្លាប់ឃើញវាវាយធ្វើបាបហ្នឹងគឺច្បាស់ណាស់ ពីព្រោះថាពេលវាយកទៅសួរចម្លើយ បើអ្នកទោសនោះគឺថា វាសួរថាខុសអ្វីគឺត្រូវតែនិយាយតាមវាថា ខុសហ្នឹង។ បើសិនជាអ្នកទោសទន្ទឹងប្រកែក គឺថាវាវ៉ៃៗអ្នកទោសដោយដំបង ដោយរំពាត់ គឺថាគ្នាស្រែកយំ ហើយបើអ្នកទោសធ្ងន់

គឺថាវាអាចវាយរហូតដល់ទៅស្លាប់កន្លែងហ្នឹងក៏មានដែរ។ អានេះគឺជាការពិត។

**ស៖** តើអ្នកទោសត្រូវបានគេបង្ខំឲ្យសរសេរចម្លើយសារភាពដែរឬទេ?

**ឆ៖** អ្នកទោសមិនបានជាឲ្យសរសេរទេ ប៉ុន្តែគឺត្រូវជា ខ្ញុំមិនចាំមួយចំណុចពីព្រោះខ្ញុំវាខាននៅយូរហើយមិនដឹងជាវាឲ្យផ្តិតមេដៃដែរ ឬក៏អត់ ចំណុចហ្នឹងខ្ញុំមិនចាំ។ ប៉ុន្តែថាអ្នកទោសអត់មានសរសេរទេចម្លើយដោយខ្លួនឯងទេ គឺគ្រាន់តែឆ្លើយមកគឺអ្នកកត់ៗតែម្តង។ ហើយអ្នកសួរ គឺមេសន្តិសុខ ឬក៏បើវាអត់នៅគឺអនុប្រធាន អ្នកសួរសំណួរ។ អ្នកទោសគឺអ្នកឆ្លើយ ហើយអង្គុយឆ្លើយបត់ជើង ហើយក្រពាត់ដៃទៅក្រោយ ចំពោះអ្នកទោសបាទ។

[១៦:០៣:២៥]

**ស៖** តើចម្លើយសារភាពហ្នឹងលោកយកទៅណាដែរ? តើលោកបញ្ជូនទៅអ្នកណាដែរ ចម្លើយសារភាពរបស់អ្នកទោសនោះ?

**ឆ៖** បាទ ចំពោះចម្លើយសារភាពហ្នឹង គឺមេវានៅហ្នឹង គឺវាជាអ្នកកាន់សៀវភៅហ្នឹង ហើយសួរបានអ្នកទោសគ្រប់ចំនួន ហើយត្រូវយកទៅឆ្លងកន្លែងមេស្រុកគឺថា គឺប្រធានហ្នឹងឯងជាអ្នកយកឯកសារផ្ទាល់មក។ គឺខ្ញុំអត់ដឹងទេ គឺគ្រាន់តែជាអ្នកកត់ត្រាទេ។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេ ថាតើសេចក្តីសម្រេចចុងក្រោយហ្នឹង តើលោកចង់សំដៅលើអ្វីនៅពេលដែលលោកនិយាយថា សេចក្តីសម្រេចចុងក្រោយហ្នឹង? តើជាសេចក្តីសម្រេចរបស់អ្នកណា របស់ប្រធាន ឬមួយក៏យ៉ាងម៉េចដែរ?

[១៦:០៤:២៧]

**ឆ៖** ខ្ញុំចង់និយាយថា សេចក្តីសម្រេចចុងក្រោយ គឺវាមកខ្លួនវាអ៊ីចឹង មិនដឹងជាថា -- ប៉ុន្តែខ្ញុំមើលទៅវា ខ្ញុំថាបែបវាសម្រេចត្រឹមមេស្រុកទេ ព្រោះឯកសារដែលវាយកមកហ្នឹង វាឃើញតែ -- វាជិះកង់មក គឺខ្ញុំដឹងថា វាយកទៅឆ្លងស្រុក ឬខេត្តអាហ្នឹងគឺ អាហ្នឹងខ្ញុំមើលអត់ឃើញទេណា។ ប៉ុន្តែខ្ញុំដឹងថាវាប្រាប់នៅកន្លែងថា វាមកៗកន្លែងស្រុក ប្រាប់តែប៉ុណ្ណឹង។ ហើយទៅវិញសម្រេចយ៉ាងម៉េចៗអាហ្នឹងគឺដូចខ្ញុំបាននិយាយប្រាប់លើកមុនហើយ គឺថាអ្នកទោសធ្ងន់យ៉ាងម៉េច អ្នកទោសស្រាលយ៉ាងម៉េច។ បាទ អាហ្នឹងគឺខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ខ្ញុំគិតថាសំណួររបស់ខ្ញុំចង់ដឹងថា តើសេចក្តីសម្រេចហ្នឹង ថាតើសេចក្តីសម្រេចហ្នឹងពាក់ព័ន្ធនឹងអ្វី? ពាក់ព័ន្ធទៅនឹងការត្រូវធ្វើយ៉ាងណាចំពោះអ្នកទោស ឬមួយក៏យ៉ាងម៉េចដែរ?

**ឆៈ** បាទ ខ្ញុំចង់ដឹងថា តើលោកចង់និយាយសំណួរហ្នឹងយ៉ាងម៉េចទេ ប៉ុន្តែថា សេចក្ដីសម្រេចវាទៅតាមទោសទណ្ឌរបស់អ្នកទោស។ អាហ្នឹងខ្ញុំនិយាយបានរួចម្ដងហើយណា។ សំណួររបស់លោកស្រីថា ចង់និយាយសេចក្ដីសម្រេចអ្នកណាជាអ្នកកំណត់អារឿងទោសហ្នឹង ឬយ៉ាងម៉េច? គឺថាពេលនោះគឺបើខ្ញុំចោទ ខ្ញុំថាមកពីចៅហ្វាយស្រុកហ្នឹង ជាអ្នកសម្រេចថា ត្រូវទោសត្រូវស្លាប់ ឬមួយក៏ទោសត្រូវដោះលែង ឬមួយក៏ត្រូវពន្យារការឃុំឃាំងប៉ុណ្ណឹង។ នេះគឺថា ខ្ញុំដឹងតែប៉ុណ្ណឹង។ ហើយមេសន្តិសុខ វាប្រហែលជាមិនទាន់សម្រេចខ្លួនវាបានទេ អត់បានទេ វាត្រូវយកមកឆ្លងស្រុក បើតាមខ្ញុំមើលទៅការសម្រេចចំពោះអ្នកទោសហ្នឹង គឺមិនត្រឹមសន្តិសុខស្រុកទេ គឺមកដល់ចៅហ្វាយស្រុក អានេះគឺសូមបញ្ជាក់ជូនអ្នកស្រី។

[១៦:០៦:៥១]

**សៈ** សូមអរគុណលោក។ តើលោកដឹងថាមានអ្នកទោស ធ្លាប់មានអ្នកទោសស្លាប់ក្នុងមន្ទីរឃុំឃាំងនោះដែរឬទេ?

**ឆៈ** អ៊ុំ! ខ្ញុំគឺបានឃើញអ្នកទោសស្លាប់ច្រើន ដោយសារ គឺថាមិនមែនគឺថាវាយកទៅសម្លាប់ទេ គឺស្លាប់នៅក្នុងខ្នោះតែម្ដង។ ជាពិសេសគឺនៅរដូវរងា អ្នកទោសគ្នាគ្មានសម្លៀកបំពាក់អីគ្រប់គ្រាន់ទេ មានតែសម្លៀកបំពាក់មួយកំប្លេមកពីមូលដ្ឋានហ្នឹងឯង។ ដូច្នេះដាក់គ្នារាប់ខែ រាប់ថ្ងៃ ហើយរបបអាហារក៏បបររាវ ពីរពេលហ្នឹង មួយពេលមួយវែក ដូច្នេះហើយខែក្ដៅមិនសូវប៉ុន្មានទេ បើខែរងាហ្នឹងគឺឃើញថាស្លាប់នៅក្នុងគុកហ្នឹងច្រើន។ ហើយភាគច្រើនគឺច្រើនតែអ្នកទោសប្រុស បើអ្នកទោសស្រី គឺវាច្រើនថ្ងៃឡើងវាឲ្យដោះលែង ប៉ុន្តែយប់ត្រូវតែបញ្ចូលខ្នោះ។ ដូច្នេះ អ្នកទោសប្រុសគឺស្លាប់ច្រើន។ ហ្នឹងគឺខ្ញុំឆ្លើយប៉ុណ្ណឹង។

[១៦:០៨:២០]

**សៈ** តើសាកសពរបស់អ្នកទោសហ្នឹង គេយកទៅធ្វើអ្វីដែរ គេយកទៅកប់ ឬមួយក៏ -- តើ?

**ឆៈ** បាទ ចំពោះសាកសពហ្នឹង គឺវាយកទៅកប់។ បើសាកសពដែលវាយកទៅសម្លាប់នោះ គឺថាវានៅឆ្ងាយពីកន្លែងឃុំឃាំង ហើយបើសាកសពដែលស្លាប់ដូចថា ឧទាហរណ៍ថា ដោយឈឺ ឬមួយក៏ដោយស្លាប់នៅក្នុងខ្នោះហ្នឹងគឺឃើញតែសែងយកទៅកប់នៅជិតៗគុកនោះឯងតែម្ដង គ្រាន់តែបាំងតែព្រៃតិចតួចប៉ុណ្ណោះ។ គឺថាវាខែរងារហ្នឹង សឹងតែរាល់ថ្ងៃដែរ។ អានេះគឺខ្ញុំឃើញជាក់ស្ដែងអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី ពេលវេលាដូចជាអស់ហើយ ទី១។ ទី២ វិសាលភាពនៃការតាំងសំណួរហាក់ដូចជាចូលជ្រៅនឹងអង្គហេតុនៃមន្ទីរសន្តិសុខពង្រ ដែលមន្ទីរនេះមិនមែនស្ថិតនៅក្នុងដីកាដំណោះស្រាយនោះទេ អង្គជំនុំជម្រះបានជម្រាប រំឮកជូនភាគីពាក់ព័ន្ធរួចហើយ ថាគប្បីកម្រិតនូវការតាំងសំណួរនៅក្នុងវិសាលភាពនៃការអនុវត្តគោលនយោបាយទូទៅនៃការជម្លៀសដំណាក់កាលទី១ ហើយនិងពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន។ នេះទំនងជាសាក្សីនោះអាចៗដឹង ហើយនិងគាំទ្រដល់ដីកាដំណោះស្រាយដែលបានចោទប្រកាន់ពាក់ព័ន្ធទៅនឹងបញ្ហានេះ។ បញ្ហាលម្អិតនៃមន្ទីរសន្តិសុខនោះគឺមិនមែននៅក្នុងរបៀបវារៈនៃការដេញដោលនៅក្នុងនាពេលនេះទេ ព្រោះវាមិនមាននៅក្នុងដីកាដំណោះស្រាយ។

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

ខ្ញុំសូមអភ័យទោសលោកប្រធាន។ តើខ្ញុំអាចបន្តពីរបីសំណួរបន្ថែមទៀតបានទេ ប្រសិនបើលោកប្រធានអនុញ្ញាត?

[១៦:១០:៣៤]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត ប៉ុន្តែសូមឲ្យសួរទាក់ទងជាមួយនឹងវិសាលភាពនៃបញ្ហាដែលអង្គជំនុំជម្រះជម្រាបជូនរំឭកជូនភាគីតាំងពីលើកដំបូង ពាក់ព័ន្ធជាមួយនឹងគោលនយោបាយ ការអនុវត្តគោលនយោបាយក្នុងការជម្លៀសប្រជាជននៅដំណាក់កាលទី១ ហើយនិងព័ត៌មានដែលទំនងជាអាចដឹងពាក់ព័ន្ធជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន។ បើពុំដូច្នេះទេអង្គជំនុំជម្រះមិនឲ្យសាក្សីឆ្លើយទេ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យបីសំណួរទៀត ប្រសិនបើមាន។

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី៖**

**ស៖** ខ្ញុំចង់និយាយអំពីព័ត៌មាននៃការជម្លៀស ដែលយើងបានពិភាក្សាពីពេលកន្លងមក។ ក្នុងពេលដែលប្រជាជនត្រូវបានគេជម្លៀសចេញហ្នឹង តើមានការព្យាយាមជួយឲ្យប្រជាជនហ្នឹងគាត់បាននៅជួបជុំគ្រួសារគ្នា ឬក៏ឲ្យនៅជាមួយគ្នាអីដែរឬទេ?

[១៦:១១:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមលើកការជំទាស់ដោយសង្ខេប ព្រោះខ្ញុំគិតថាយើងមានពេលវេលាខ្លី។ ដូច្នេះ ខ្ញុំចង់ឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរអំពីអ្វីដែលសាក្សីគាត់ឃើញដោយផ្ទាល់ គាត់ដឹងដោយផ្ទាល់។ ព្រោះថាកន្លងមកនេះគឺសាក្សីភាគច្រើន គាត់និយាយអំពីការឮ អំពីការជម្លៀសនៃទីក្រុងសៀមរាប។ ដូច្នេះ ខ្ញុំស្នើសុំដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីឲ្យបញ្ជាក់ឲ្យច្បាស់ ថាតើអ្វីដែលគាត់បានឃើញ? ថាតើអ្វីដែលសាក្សីបានឃើញដោយផ្ទាល់នោះ?

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

ខ្ញុំអាចចោទសំណួរសាជាថ្មីឡើងវិញ។

[១៦:១២:៤០]

**សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី៖**

**ស៖** ប្រជាជនដែលត្រូវបានគេនាំជម្លៀសយកមកស្រុកលោកហ្នឹង តើគេមាន -- តើមានការខិតខំ ឬក៏ការជួយសម្រួលបែបណាដើម្បីឲ្យប្រជាជនហ្នឹងគាត់បាននៅជាមួយគ្នា នៅជួបជុំគ្នាដែរឬទេ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** ចំពោះសំណួរនេះ គឺថាខ្ញុំក៏មិនបានជាដឹងដោយផ្ទាល់ទេ គឺថាទៅតាម បើតាមខ្ញុំមើលទៅស្ថានភាពអ្នក១៧ ហ្នឹងគឺ ឥឡូវឧទាហរណ៍ថាជម្លៀសពីសៀមរាបមក ដល់មូលដ្ឋានហើយ គឺថាការជួបហ្នឹងគឺមិនបានជួបជុំគ្នា។ ម្តាយចាស់នៅផ្ទះទៅ ហើយកូនដែលពេញកម្លាំងត្រូវពួកសហករណ៍ហ្នឹងមេសហករណ៍ហ្នឹងឲ្យទៅធ្វើការ ដូចទំនប់ ប្រឡាយ គឺវាមិនឲ្យទំនេរទេ គឺវាខ្លាចខាតកម្លាំង។ ហើយអ្នកដែលទៅធ្វើ គឺនៅក្រោមបង្គាប់របស់ពួកមូលដ្ឋាន បានន័យថា មិនមែនអ្នក១៧ ទេ គឺថាអ្នកភូមិ។ អាហ្នឹង បើជម្លៀសមកពីសៀមរាប មកដល់ជួបជុំ បើថានៅរស់គឺថាជួបជុំគ្នាមែន ប៉ុន្តែជួបជុំបានតែមួយរយៈទេ។ គឺថាក្រោយពីមេសហករណ៍រៀបចំហើយ គឺមិនបាននៅជាមួយគ្នាទេ គឺកូនទៅផ្សេង ម៉ែទៅផ្សេង។ អាហ្នឹងគឺខ្ញុំដឹងច្បាស់អ៊ីចឹង បាទ។

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណ។ ខ្ញុំមិនមានសំណួរអ្វីបន្តទៅទៀតទេ។ សូមអរគុណ។

[១៦:១៤:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៥:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណដល់សាក្សីដែលបានខិតខំប្រឹងប្រែងក្នុងការផ្តល់សក្ខីកម្មដោយយកចិត្តទុកដាក់ និងអត់ធ្មត់។

សូមអញ្ជើញលោកមេធាវី ហ្សាស្តេ ប៉ោ!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមនិយាយដោយសង្ខេប ប៉ុន្តែខ្ញុំលើកអំពីសំណួរ អំពីសំណើដែលយើងលើកយកចម្លើយរបស់សាក្សីផ្តល់ទៅឲ្យលោក ហង់រី ឡូកា។ ដូច្នេះហើយដោយស្នើថាមិនឲ្យសាក្សីអាននូវចម្លើយដែលគាត់ផ្តល់ជាមួយលោក ហង់រី ឡូកា នៅថ្ងៃបន្ត ហើយដូច្នេះខ្ញុំគិតថាអ្វីដែលគាត់និយាយទាក់ទងទៅនឹងលោក ហង់រី ឡូកា ក៏ដូចជាការសង្កេត ក៏ដូចជាកត់សម្គាល់នានារបស់លោក ហង់រី ឡូកា ដើម្បីកុំឲ្យមានការប៉ះពាល់ កុំឲ្យមានការជ្រៀតជ្រែកទៅដល់ការយល់ឃើញ ការដឹងរបស់សាក្សីនៅក្នុងពេលនេះ។ ដូច្នេះ ខ្ញុំស្នើសុំថាយើងដកចេញឯកសាររបស់លោក ហង់រី ឡូកា ចេញពីសាក្សីដើម្បីឲ្យគាត់និយាយតែពីអ្វីដែលគាត់បានដឹងតែប៉ុណ្ណោះ។ សូមអរគុណ។

[១៦:១៦:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោក ម៉ខល កាណាវាស៖

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយសង្ខេប ខ្ញុំមិនចង់ធ្វើការរំខានទៅដល់កិច្ចដំណើរការនីតិវិធី ប៉ុន្តែខ្ញុំសង្កេតឃើញថាលោក ហង់រី ឡូកា ត្រូវបានគេកត់ត្រាទុក ហើយគាត់បាន -- ហើយគាត់អង្គុយមានការកត់កំណត់ហេតុទៅលើបញ្ហាទាំងអស់នេះ ហើយមានការបង្ហាញអំពីបញ្ហាទាំងអស់នេះ។ ដូច្នេះហើយគ្មានអ្នកណាដឹងច្បាស់ថា តើលោកសាក្សីហ្នឹងនឹងផ្តល់សក្ខីកម្មពីអ្វី ឬក៏អ្វីនោះទេ។ ដូច្នេះខ្ញុំសូមអរគុណ។

ដូច្នេះខ្ញុំគិតថា ប្រហែលជាអង្គជំនុំជម្រះអាចពិចារណាទៅលើបញ្ហាទាំងអស់នេះ គឺការស្វែងរក

ព័ត៌មានថាតើអ្វីដែលបានកត់ត្រាទុក ហើយនិងទទួល។

[១៦:១៧:៤៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

ក្រឡាបញ្ជីសវនាការជូនព័ត៌មានទៅខាងផ្នែកដឹកជញ្ជូនផង ថាអាចពន្យារពេលរហូតដល់កន្លះដល់១៥នាទីទៀត ទំនងម៉ោងបួនកន្លះទើបចប់។ អ៊ីចឹងសូមឲ្យខាងដឹកជញ្ជូនត្រៀមពន្យារពេលក្នុងការដឹកជញ្ជូនមន្ត្រីវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់នៅរសៀលនេះផង។

សូមអញ្ជើញបន្ត!

**លោក ឌេល លីសាក់៖**

ដោយសង្ខេបទេ លោកប្រធាន ដើម្បីឲ្យប្រតិចារឹកច្បាស់លាស់។ យើងខ្ញុំបានបញ្ជាក់យ៉ាងច្បាស់ហើយការិយាល័យសហព្រះរាជអាជ្ញាមិនបានធ្វើការទាក់ទងជាមួយនឹង ហាង់រី ឡូកា នោះទេ។ ខ្ញុំសូមជម្រាបផងដែរ គឺមិនមែនថាគាត់នៅក្នុងទីនេះ នៅផ្នែកនេះនោះទេ គឺខ្ញុំបានរកឃើញឯកសារនេះដែលឯកសារនេះវាមានកិច្ចសម្ភាសន៍ជាមួយនឹងសាក្សី។ ខ្ញុំមិនបានដឹងទេរហូតមកដល់ថ្ងៃព្រហស្បតិ៍នេះទើបដឹងថាគាត់បានសម្ភាសនៅក្នុងកំណត់ហេតុជាមួយនឹង ហាង់រី ឡូកា។ ដូច្នេះឯកសារនេះ ដែលថាវាមិនទំនងថាវាមានការកើតឡើងដូច្នេះនោះទេ។ ខ្ញុំគ្រាន់តែបញ្ជាក់ឲ្យបានច្បាស់ទៅលើចំណុចនេះ។ យើងខ្ញុំមិនមានធ្វើការទាក់ទងជាមួយនឹងបុគ្គលណាមួយ ឬបុគ្គលណាក្រៅតែពីសាក្សីនេះទេបាទ។

[១៦:១៩:៣១]

**ប្រធានអង្គជំនុំ៖**

មតិយោបល់អ្វីទៀតទេ?

ឡានពន្យារពេលហើយ រថយន្តអាចពន្យារពេលរួចហើយ។ កុំបារម្ភរឿងរថយន្តវិលត្រឡប់ទៅវិញអី។

បាទ បើមិនមានអីទៀតទេ អង្គជំនុំជម្រះសូម ឃើញថាកិច្ចដំណើរការសវនាការថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃខានស្អែក ថ្ងៃពុធ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ប៉េជុយ ជីបសែ និងដើម-

បណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-82 សូមភាគី និងសាធារណជនជ្រាប។

[១៦:២០:៤១]

លោក ជីបសែ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មរបស់លោក នៅថ្ងៃខានស្អែក គឺថ្ងៃពុធ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ទៀត។ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មទៀត នៅថ្ងៃខានស្អែកនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃពុធ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ នៅវេលាម៉ោងប្រាំបួនព្រឹក។ ហើយមេធាវីប្រឹក្សាសាក្សី សូមអញ្ជើញមកចូលរួម ដូចគ្នានឹងសាក្សីនេះដែរ។ ហើយនិងឲ្យជូនដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-82 ត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងបន្ទប់រង់ចាំ នៅជិតបន្ទប់សវនាកានេះវិញ នៅព្រឹកថ្ងៃពុធ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ជាការបម្រុងទុក។

សូមអញ្ជើញលោកមេធាវី!

[១៦:២១:៥៩]

**លោក ហ្សាស្តេី ប៉ោះ៖**

នៅពេលនេះ ឡានក្រុងកំពុងរង់ចាំ ខ្ញុំនិយាយខ្លីទេ។ លោកប្រធាន គឺមិនទាន់បានសម្រេចទៅលើ -- ការដកឯកសារហ្នឹង ចេញពីសាក្សីនៅឡើយទេ ចំពោះបញ្ហាហ្នឹង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះនឹងពិចារណាសម្រេច នៅព្រឹកថ្ងៃ១៤ ខែវិច្ឆិកា ឆ្នាំ២០១២ មុននឹងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីពិភាក្សាដេញដោល។ ពីព្រោះឯកសារនេះបានដាក់ ហើយបានសួរដេញដោលចប់សព្វគ្រប់ហើយនៅដំណើរការសវនាការនេះ។ ថាតើបញ្ហានេះ គឺគួរគប្បីដោះស្រាយយ៉ាងដូចម្តេច ដើម្បីឲ្យវាមានតម្លាភាពបំផុត តាមបំណងប្រាថ្នារបស់លោកមេធាវី។

[១៦:២២:៥០]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនគាត់ទាំងពីរនាក់ មកកាន់បន្ទប់

សវនាការនេះវិញ នៅថ្ងៃពុធ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:២៣ នាទី)*